## មាតិការឿង


១. បទសម្ភាសន៍របស់វិទ្យុខ្មែរប៉ុស្តិ៍............ ០២
២. បទសម្ភាសន៍លោក ខៀវ សំផន............ ០៣
៣. គ្រូ និងសិស្សនិយាយរឿងប្រលង............ ០៤
៤. របាយការណ៍លម្អិត ស្តីពីការបោះឆ្នោត...... ០៥
៥. អត្ថបទអង់គ្លេស ...................................... ០៦
៧. សុខភាព ................................................ ១០
៦.បាតុកម្មខ្មែរនៅមុខស្ថានទូតថៃ............ ២៤


# ខ្មែរប៉ុស្តិ៍ The Khmer Post







KHMER BILINGUAL BIWEEKLY NEWSPAPER

VOLUME 02 ISSUE 20 August 23th-09th 2008 ADVERTISING (267) 253-3947 WWW.THEKHMERPOST.COM


## នរណានឹងក្លាយជាប្រធានាធិបតី នៃសហរដ្ឋអាមេរិក

### បារ៉ាក់ អូបាម៉ា ឬ ចន ម៉ាកេន ?




•••ក្នុងរយៈពេល១ខែចុងក្រោយនេះ ចន ម៉ាកេន នៅក្រោយ អូបាម៉ា ចំនួន៥ពិន្ទុរហូត ។ នៅថ្មីៗនេះ លោក បារ៉ាក់ ប្រមូលប្រាក់ឃោសនា (តទៅទំព័រទី១៤)

## ហ៊ុន សែន ព្រមានយកអាសនៈសភាពី សម រង្ស៊ី



ជំនួបរវាង ហ៊ុន សែន និង សម រង្ស៊ី នៅចំណតយន្តហោះអន្តរជាតិភ្នំពេញ

**ភ្នំពេញ , ខ្មែរប៉ុស្តិ៍ : ចាន់ កុសល**

•••នៅពេលជួបគ្នាដោយចៃដន្យក្នុងឱកាសជូនដំណើរសម្តេចឪ សម្តេចម៉ែ និង (តទៅទំព័រទី១២)

## កីឡាអូឡាំពិក នៅបេយ៉ឹង




•••" បេយ៉ឹង ឬបេកាំង" នៃប្រទេសចិន បានធ្វើឱ្យពិភពលោកបើកភ្នែកមើលបេះដូងនៅមហាប្រទេសនេះ ដោយសារតែចិនជាម្ចាស់ផ្ទះសម្រាប់រៀបចំទទួលកីឡាអូឡាំពិក ២០០៨ នេះ ។

ពិភពលោក ជាពិសេសលោកសេរីបានឃើញការបើកចំហរជាសាធារណៈដំបូងបង្អស់នូវលំអតតខ្មោះនៃមហាប្រទេសចិន ដែលជាកុម្មុយនីស្តចុងក្រោយជំហររឹងមាំមិនងាយរលំដូច រុស្ស៊ី ។

ពិធីដ៏ធំជាងគេក្នុងពិភពលោកនេះ ត្រូវបានសម្ពោធថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨ រហូតដល់ថ្ងៃទី២៤ ខែសីហា ឆ្នាំដដែល ។

នៅហ្វីឡាដែលហ្វីយ៉ា នាកណ្តាលក្រុង ក្នុងតំបន់ "ឆាយណាថោន" សហគមន៍ចិន ក៏រៀបពិធីទទួលពិធីសម្ពោធកីឡាអូឡាំពិកបេយ៉ឹង ២០០៨ដែរ ដោយមានសមាគមចិន ពាណិជ្ជករ និងសហគមន៍ផ្សេងៗទៀត ក៏បានចូលរួមសម្តែងការអបអរសាទរជាពហុវប្បធមិ នាពេលនោះដែរ លោកអភិបាលក្រុង "ម៉ាយកឹល ណាទ័រ" ក៏មានវត្តមានជាគណធិបតីជាមួយពិធីរបស់សហគមន៍អាស៊ីដែរ ។

ពិធីដ៏អធិមអធមនេះ ត្រូវបានល្អក់ពណិខ្លះៗ ដោយសារទីភ្នាក់ងារ អេភី បានបរិយាយថា មានភាពក្លែងក្លាយមួយចំនួន ដូចជាកាំជ្រួចបាញ់យ៉ាងសន្ធឹកសន្ធាប់ ដែលឃើញក្នុងទូរទស្សន៍បែរជាមិនច្រើនដូចគ្នា (តទៅទំព័រទី២៣)

## ពិធីបុណ្យអុំទូកនៅឡូវែល



**ដោយ : អន យុង**

•••ឡូវែល ម៉ាសាឈូសែត គឺតំបន់ដែលសំបូរខ្មែររស់នៅច្រើនជាងគេ បន្ទាប់ពីឡុងប៊ិចមក ។ នាសប្តាហ៍កន្លងទៅនេះ ពិធីបុណ្យអុំទូក ដែលជាប្រពៃណីខ្មែរនោះ ត្រូវបានប្រារព្ធឡើងនៅថ្ងៃសៅរ៍ ទី១៦ សីហា នេះ យ៉ាងអធិកអធម តែលើកនេះ ពុំមានខ្មែរអុំទូកទេ ។ (តទៅទំព័រទី២៤)

## ការជួបជុំរំលឹកអតីតកាលនៃកងទ័ពនាវាខ្មែរ

**Garden Grove : វ៉ាន់ថា**

•••អតីតអនុសេនីយឯកកងនាវាខ្មែរម្នាក់បានរំលឹកពីអតីតកាលក្នុងវីរភាព និងបង្ហាញពីការមិនតក់ស្លុតរបស់ក្រុមកងទ័ពជើងទឹករបស់គាត់ក្នុងសមរភូមិសង្គ្រាម ជាមួយសត្រូវក្នុងរបបសាធារណរដ្ឋខ្មែរ ដែលគ្រប់គ្រងអំណាច ដោយសេនាប្រមុខ លន់ នល់ នាឆ្នាំ១៩៧០-១៩៧៥ ។ ដែលអំឡុងនោះ សត្រូវឈ្លានពាន គឺយួនយៀកកុង និងកងទ័ពឧទ្ទាមខ្មែរក្រហម ដែលរំខានញាំញីសង្គមសេនាប្រមុខ លន់ នល់ ឱ្យមានសភាពការរីករវរ និងវិទ្ធស្សនាទាំងទំនាក់ទំនងការទូតជួបការលំបាកដល់ទីបំផុតនៃការដួលរលំរបបសាធារណរដ្ឋខ្មែរ ។

ជា ភឹម ស័ក្តិបីទ័ពជើងទឹកឈរជើងនៅលើកប៉ាល់ចម្បាំង B111 ការពារនៅតាមតំបន់ឈូងសមុទ្រ និងកោះប៉ូលូវ៉ៃ បាននិយាយថា ក្រុមពួកគាត់មានគ្នា៦៤នាក់ បានតស៊ូយ៉ាងស្វិតស្វាញក្រាញនទៀលប្រយុទ្ធប្រឆាំងជាមួយខ្មាំងសត្រូវ គឺពួកខ្មែរក្រហម រហូតដល់ទីបញ្ចប់ ដែលមេបញ្ជាការទទួលខុសត្រូវបានរត់ចោលពួកខ្លួន ។



អតីតវរៈសេនីយ៍ត្រី យួន វណ្ណី (រូបថត ឯល វ៉ាន់ថា)

ចំណែកលោកស័ក្តិប្រាំទទួលបន្ទុកសេនាធិការកងទ័ពជើងទឹក (កងនាវាខ្មែរ) នៅតំបន់រាមសុំមិនបញ្ចេញឈ្មោះបាននិយាយថា វីរភាពរបស់ពួកយើងមិនតក់ស្លុតមិនខ្លាចស្លាប់ក្នុងមួយវិនាទីណាឡើយ (តទៅទំព័រទី០៨)

សូមអញ្ជើញស្តាប់វិទ្យុសម្លេងខ្មែរអាមេរិកាំង នៅ ហ្វីឡាដែលហ្វីយ៉ា FM/540 នៅរៀងរាល់ថ្ងៃសៅរ៍ ពីម៉ោង ៣ ដល់ ៤ រសៀល

# បទសម្ភាសន៍របស់ខ្មែរប៉ុស្តិ៍ជាមួយលោក ប៉ែន សុវណ្ណ (ត)

•••B68 អ្នកជំនាញការរបស់វៀតណាម គ្រប់ផ្នែកនៅហ្នឹងហើយកុំតែបាន B68 ធានារ៉ាប់រងជាមួយពួកលោក ហ៊ុន សែន នោះលោក ហ៊ុន សែន ក៏អត់ហ៊ានធ្វើដែរ ។

លោក សាយ ប៊ូថង លោក ហ៊ុន សែន ក៏អត់ហ៊ានធ្វើដែរ ពីព្រោះខ្ញុំកាន់កងកម្លាំងប្រដាប់អាវុធ ហើយខ្ញុំដឹកនាំប្រជាពលរដ្ឋ នយោបាយគេជឿជាក់ ប៉ុន្តែគាត់បានកម្លាំងយោធា និងកម្លាំងបច្ចេកទេសពី B68 ឬថា ពីមជ្ឈឹមបក្សកុម្មុយនីស្តវៀតណាម បាទ ។

**សំនួរ** : សំនួរចុងបញ្ចប់ ខ្ញុំបាទសុំសួរលោកអតីតនាយករដ្ឋមន្ត្រីថា : កាលពីសម័យយួនរំដោះថ្ងៃ៧ មករា ឆ្នាំ១៩៧៩ នោះ ប្រទេសវៀតណាមគេបានបង្ហាញនៅលើពិភពលោកថា : ការដែលវៀណាមចូលមកជួយរំដោះប្រជាពលរដ្ឋ ចេញពីរបបខ្មែរក្រហមហ្នឹង គឺដើម្បីជួយប្រជាពលរដ្ឋកុំឱ្យបនប្រល័យពូជសាសន៍ ផ្តាច់ផ្តិលជីវិតខ្មែរហ្នឹងឱ្យអស់ ប៉ុន្តែមានមតិអន្តរជាតិ និងមតិជាតិមួយចំនួនគេថា កាលដែលយួនចូលមក គឺឈ្លានពានប្រទេសខ្មែរ ដើម្បីសំម្លឹងឃើញផលរបយោជន៍ស្អីពីខ្មែរ ដើម្បីទាញយកកេរ្តិ៍ផលប្រយោជន៍នាំទៅប្រទេសគេវិញ ។ ហើយការដាក់សំនួរចោទសួរថា តើវៀតណាមពិតជាមកជួយខ្មែរ ឬក៏មកបំពានខ្មែរ ព្រោះកាលនោះគឺខ្មែរក្រហមស្ថិតនៅពីក្រោយខ្នងនយោបាយខ្មែរក្រហមនោះ គឺ ចិន ហើយយួនភ័យខ្លាចចិនហ្នឹងគាំទ្រខ្មែរក្រហម ដើម្បីវៃចូលទៅឈ្លានពានប្រទេសយួន ។ តើលោកយល់ឃើញដូចម្តេចដែរហ្នុង ដែលលោកជាមេដឹកនាំមួយរូប បាទ ?

**ចម្លើយលោក ប៉ែន សុវណ្ណ** : ខ្ញុំយល់ឃើញថា : មហិច្ឆិតារបស់វៀតណាម គេចង់យកដីខ្មែរនេះមិនមែនឆ្នាំ១៩៧៩ នេះទេ រឿងនេះវាមានតាំងពីយូរលង់ណាស់មកហើយ ជំនាន់ខ្ញុំចូលអង្គការចលនាខ្មែរឥស្សរៈ ឆ្នាំ១៩៥០ អាហ្នឹងរូបខ្ញុំឃើញ


លោក ប៉ែន សុវណ្ណ

គំនិតវៀតណាមអ៊ីចឹងដែរ ។ ហេតុនេះ គេតែងចិញ្ចឹមចិត្តមហិច្ឆិតារបស់គេ គេនឹងយកដីខ្មែរដាក់ក្រោមអាណានិគមរបស់គេ ប៉ុន្តែវាមានគំនិតតែវាគ្មានឱកាស មានឱកាស តែគ្មានពេលវេលា បើអ៊ីចឹងក្រោយថ្ងៃ១៧ មេសា ១៩៧៥ ហ្នឹង ហើយពេលខ្មែរប្រល័យជីវិតពលរដ្ឋខ្មែរ វៀត-ណាមគេធ្វើជាអ្នកមានបុណ្យជួយសង្គ្រោះវិញ ។ ប៉ុន្តែសង្គ្រោះមិនមែនថា ខ្ញុំមិនដឹងទេ ខ្ញុំដឹងថា វៀតណាមគេមានមហិច្ឆិតាចង់យកដីខ្មែរហ្នឹង មិនមែនត្រឹមឆ្នាំ១៩៧៩ ទេ តាំងពីអតីតកាល ។

ពេលណាគេមកជួយខ្មែរ ដូចជាជំនាន់ខ្ញុំចូលបំរើកងទ័ពខ្មែរឥស្សរៈ ប្រឆាំងពួកអាណានិគមនិយមបារាំង អាហ្នឹងដំណាក់កាលខ្ញុំឃើញច្បាស់ ពេលហ្នឹងគេថា អង្គការដឹកនាំនយោបាយរបស់រណសិរ្សខ្មែរឥស្សរៈ នៅឆ្នាំ១៩៥០-១៩៥១ នោះ ហ្អែ យើងក៏អត់មានម្ចាស់ការដែរ អ្វីជាប្រធានវៀត-ណាមគេកាន់កាប់ទាំងអស់ ខ្មែរយើងកាន់អនុប្រធានចៅហ្វាយស្រុក រហូតដល់ចៅហ្វាយឃុំ មួយចំនួនក៏ពួកវៀតណាមដែរ ។

ពីជំនាន់ពីឆ្នាំ១៩៥០-៥១ នោះ ហើយអំពីខាងមជ្ឈឹមរណសិរ្ស ខ្មែរឥស្សរៈ បើកបដិសន្ធិឡើង ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៥១ នេះ វៀតណាមគេត្រួតត្រាយើងតាំងពីឆ្នាំហ្នឹងមកម្លេះ ខ្មែរយើងអត់មានសិទ្ធិសម្រេចអ្វីមួយទេ អាហ្នឹង រហូតដល់ឆ្នាំ១៩៥៤ ។

ឆ្នាំ១៩៥៤ ពួកអាណានិគមបារាំង ត្រូវដកថយពីឥណ្ឌូចិន ក្នុងនោះមានប្រទេសខ្មែរ អ៊ីចឹងវៀតណាម គេបង្កប់ជំនាញការរបស់គេនៅគ្រប់ខេត្ត ពិសេសនៅទីក្រុងភ្នំពេញ គេបង្កប់ទៅធ្វើជាប្រជាជនសាមញ្ញនៅខេត្ត និយាយរួមមួយម៉ាត់ថា គ្រប់ខេត្ត ។ គេមានអ្នកបង្កប់រហូតមកហ្នឹង ពេលណាខ្មែរយើងនៅជាអព្យាក្រឹត្យអីហ្នឹង នៅឆ្នាំ១៩៥៥ មកដល់ឆ្នាំ១៩៧០ ហ្នឹង គឺវៀតណាម គឺវៀតណាមមានដាក់មន្ត្រីគេនៅក្នុងហ្នឹង រឿងហ្នឹងខ្ញុំដឹង ឈ្មោះអីក៏ខ្ញុំដឹងដែរ ប៉ុន្តែខ្ញុំមិនលើកទេ វាមានវែងឆ្ងាយ ។

បើអីចឹង គេចង់រកឱកាស គេមានពេលវេលាបង្កប់ ហើយគេចាំរកឱកាស ។ ពេលណាខ្មែរកាប់ចាក់គ្នា សម្លាប់ប្រជាពលរដ្ឋក្នុងជំនាន់ណាក៏ដោយវៀតណាមគេទះដៃអបអរសាទរ ហើយពេលហ្នឹង គេនឹងលូកដៃចូលទីមួយគេមានពេលវេលា គេមានឱកាស ឱកាសធំបំផុតពេលក្រោយដែលគេបានចូលដៃរំលំរបបខ្មែរក្រហមសង្គ្រោះជាតិ ប៉ុន្តែគេហ្នឹងហើយ គេធ្វើហើយ គេបញ្ជូននិគមជនវៀតណាមមកភ្លាមតែម្តង គេមករំលោភព្រពាក់ព្រពុននៅស្រុកខ្មែរតែម្តង យ៉ាងរហ័ស ហើយមួយទៀតគេសុំកាត់ដីខ្មែរ ដែលលយទៅស្រុកគេ ឱ្យគេត្រួតត្រាអាហ្នឹងវាអ៊ីចឹង ហើយអ្វីដែលយើងខ្ញុំដឹកនាំនយោបាយស្រុកខ្មែរនេះ គេអត់ឱ្យខ្ញុំសម្រេចអ្វីទេ គឺជំនាន់ការគេសរសេរឯកសារឱ្យខ្ញុំអាន ឱ្យខ្ញុំអនុវត្ត អាហ្នឹងហើយវាឃើញច្បាស់ណាស់ **(តនៅទំព័រទី០៦)**










# បទសម្ភាសន៍លោក ខៀវ សំផន ជាមួយនិង ពិន សំខុន

## ថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៩៨ នៅអន្លង់វែង តំបន់ស៊ូយត

•••លោក ខៀវ សំផន មេដឹកនាំចលនាប្រដាប់អាវុធខ្មែរក្រហម និងជាហត្ថលេខីនៃកិច្ចព្រមព្រៀងក្រុងប៉ារីស ឆ្នាំ១៩៩១ បានផ្តល់កិច្ចសម្ភាសន៍មួយនៅថ្ងៃដែលព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ត្រូវតុលាការក្រុងភ្នំពេញចោទប្រកាន់ពីប្រការដឹកអាវុធខុសច្បាប់ ហើយនិងពីបទបានលួចទាក់ទងជាមួយភាគីខ្មែរក្រហមនៅអន្លង់វែង ថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៩៨ ដែលយើងសូមជូនសេចក្តីរាយការណ៍ដូចតទៅ :

លោក ខៀវ សំផន ផ្តើមសេចក្តីថា : ខ្មែរគ្រប់រូបចាំបាច់ត្រូវរួមកំលាំងគ្នា ជំរុញឱ្យបានសំរេចនូវសំណូមពររបស់ជាតិ និងប្រជាជនយើងបញ្ចប់កុម្មុយនិស្តឈ្លានពាន ឱ្យមានភាពផ្សះផ្សាជាតិ ដើម្បីជាតិយើងទាំងអស់គ្រប់ ស្រទាប់ រួមគ្នាការពារប្រទេស និងកសាងប្រទេសកម្ពុជាយើងឡើងវិញ ។ ទោះសម្តេចក្រុមព្រះយើងខ្ញុំយល់ឃើញថា ទាំងជាតិគ្រប់ស្រទាប់សង្គម គ្រប់គណបក្ស ដែលខ្ញុំយល់ឃើញថា ទាំងសកលលោកដែលស្នេហាសន្តិភាព និងយុត្តិធម៌គួរយកមកត្រិះរិះពិចារណាធ្វើម៉េចកុំឱ្យពិសោធន៍ដ៏ជូរចត់ខ្លោចផ្សាដែលជាតិ និងប្រជាជនកម្ពុជាយើងបានឆ្លងកាត់រយៈពេលថ្មី១នេះសារដើមឡើងវិញគឺ :

**ទី១:** ខ្ញុំយល់ឃើញថា យ៉ាងម៉េចបានជាសភាពការណ៍មកដល់ថ្នាក់អញ្ចឹង ថ្ងៃហ្នឹង ? វាទៅជានាយករដ្ឋមន្ត្រីទី២ វាទៅជាគណបក្សដែលចាញ់ឆ្នោតមិនត្រឹមតែធ្វើរដ្ឋប្រហារ បណ្តេញនាយករដ្ឋមន្ត្រីទី១ ដែលចេញមកពីការបោះឆ្នោតរបស់អង្គការសហប្រជាជាតិនាឆ្នាំ ១៩៩៣ តាមកិច្ចព្រមព្រៀងក្រុងប៉ារីសទេ ទៅជាត្រូវគេកាត់ទោសទៅវិញ? នេះជាសំនួរមួយ ដែលសួរដើម្បីយើងចេះតែដេញទៅ ហើយយើងរកពិសោធន៍ ។ ចំពោះន័យបញ្ហាទី១ មកពីការបោះឆ្នោតពីជំនាន់អ៊ុនតាក់នាឆ្នាំ១៩៩៣ ក៏ដូចជាការបោះឆ្នោតដែលគេបំរុងរៀបចំលើកនេះ នៅខែ កក្កដា ១៩៩៨ គឺជាការបោះឆ្នោតក្នុងរបប ក្នុងរដ្ឋអំណាចយួនកុម្មុយនីស្ត ។ កិច្ចព្រមព្រៀងក្រុងប៉ារីសនាឆ្នាំ ១៩៩១ ពុំបានអនុញ្ញាតឱ្យរក្សារដ្ឋអំណាចនេះនៅកម្ពុជាទេ វាគ្រាន់តែធ្វើការប្តូរឈ្មោះ ដូរខោអាវ ក៏វាខ្មែរ មានការរស់នៅលាយឡំជាមួយនិងមនុស្សយួនជាង៥លាននាក់ នៅក្នុងប្រទេសកម្ពុជា ដូច្នោះកំលាំងឈ្លានពានរបស់យួនអត់បានដកតាមការ ដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងក្រុងប៉ារីសទេ ។



**ទី២:** ការផ្សះផ្សាជាតិ៤ភាគី តាមរូបភាពក្រុមប្រឹក្សាជាន់ខ្ពស់ ដែលមានព្រះមហាក្សត្រ នរោត្តម សីហនុ លោកជាព្រះប្រមុខរដ្ឋ និងជាព្រះប្រធានការផ្សះផ្សាជាតិនេះក៏អត់មាន ។

**ទី៣:** បរិយាកាសនយោបាយអព្យាក្រឹត្យក៏អត់មានស្រេចទៅលើរដ្ឋអំណាចអាយ៉ង ដែលយួនបន្ទុកឡើងតាំងពីឆ្នាំ១៩៧៩ ។

ឥឡូវបញ្ហាវានៅដដែល សុទ្ធតែពិសោធន៍ដែលយើងទាំងអស់គ្នាត្រូវត្រិះរិះពិចារណាគិតគូរ ។ ពិសោធន៍ឥឡូវវាបញ្ជាក់ច្បាស់ ច្បាប់ដែលដាក់ "អ្នកតស៊ូស្នេហាជាតិឱ្យនៅក្រៅច្បាប់" ដែលគេហៅថា "ខ្មែរក្រហម" វាមិនមែនសំដៅមកកំទេចខ្មែរក្រហមទេ ច្បាប់នេះ មកអនុវត្តន៍ចំពោះខ្មែរក្រហមិនបានទេ ! ក៏ប៉ុន្តែ ច្បាប់នេះសំរាប់អនុវត្តន៍ចំពោះនរណា ? នោះក៏ពិសោធន៍បញ្ជាក់ច្បាស់ ថ្ងៃហ្នឹងដែលគេកំពុងតែកាត់ទោសសម្តេចក្រុមព្រះ ហើយថ្ងៃទី១៧ទៀត ក៏គេត្រូវកាត់ទោសសម្តេចក្រុមព្រះថា ដោយមកពីការទាក់ទងជាមួយខ្មែរក្រហមក្រៅច្បាប់ តើច្បាប់ហ្នឹងសំរាប់កាត់កអ្នកណា? ពីមុនកាត់កឯកឧត្តម សម រង្ស៊ី ដេញឯកឧត្តម សម រង្ស៊ី ចេញពីតួនាទីរដ្ឋាភិបាល និងពីសភា...ក្រោយមកទៀតកាត់ទោសស្តេចក្រុមឃុន នរោត្តម សេរីវុឌ្ឍ... ឥឡូវថ្ងៃនេះសំរាប់កាត់ទោសសម្តេចក្រុមព្រះវិញ ។

ពិសោធន៍ទាំងអស់នេះហើយដែលខ្ញុំយល់ឃើញថាទី១. សុំលើកចំពោះជាតិ និងប្រជាជនយើងទាំងអស់ដើម្បីពិនិត្យពិចារណា ហើយទី២. ក៏សុំលើកប្រទេសតូចធំទាំងអស់ដើម្បីនឹងពិនិត្យ ហើយដកពិសោធន៍ប្រទេសតូចធំដែលស្នេហាសន្តិភាព និងយុត្តិធម៌ ចង់បានឱ្យមាន សន្តិភាព ស្ថេរភាព ឱ្យមានសិទ្ធិប្រជាធិបតេយ្យ សេរីនៅកម្ពុជា សុំពិនិត្យឡើងវិញ ។

បទពិសោធន៍នេះច្បាស់ដោយឈាមស្រស់សាច់ស្រស់របស់ភូមិ នេះជាសំណូមពររបស់ខ្ញុំដែលឆ្លៀតក្នុងឱកាសនេះ សូមលើកបញ្ហាដើម្បីជនរួមជាតិយើងទាំងអស់គ្រប់ស្រទាប់សង្គម ហើយនិងដើម្បីមតិប្រទេសតូចធំទាំងអស់ដែលទាំងនៅក្នុងតំបន់ និងនៅក្នុងសកលលោក មហាសន្តិភាព និងយុត្តិធម៌ ដែលត្រូវការឱ្យកម្ពុជា មានសន្តិភាព ស្ថេរភាព ដែលជាផ្នែកមួយ នៃសន្តិភាព និងស្ថេរភាពនៅក្នុងតំបន់ពិនិត្យ និង ពិចារណាឱ្យបានច្បាស់លាស់ ។ ពិចារណាដើម្បីអ្វី? ដើម្បីឱ្យឃើញថា ដោះស្រាយបញ្ហាកម្ពុជាសំខាន់បំផុតត្រូវដោះស្រាយឱ្យមានការផ្សះផ្សាជាតិជាមុនសិន ផ្សះផ្សាជាតិរវាងកំលាំងជាតិទាំងអស់ ដោយឥតមានប្រកាន់ពណ៌សំបុរ នយោបាយអតីតកាលនយោបាយអ្វីទាំងអស់ ហើយយ៉ាងនេះទើបបោះឆ្នោតបាន ។ បានរូបភាពនៃការចាត់តាំងរដ្ឋាភិបាលជាតិមួយ ដែលមានកំលាំងជាតិទាំងអស់គ្រប់ពណ៌សំបុរ នយោបាយ គ្រប់និន្នាការនយោបាយចូលរួម កុំឱ្យបដិសេធកំលាំងណាមួយ ទើបវាបញ្ចប់សង្គ្រាមទៅបាន ទើបវាមានសន្តិភាពស្ថេរភាពនៅកម្ពុជា ហើយទាំងអស់នេះវាជាលក្ខណៈសម្បត្តិសំរាប់មានការបោះឆ្នោតទៅដោយសេរី និងប្រជាធិបតេយ្យ ។

(មានតទៅលេខក្រោយ)


**ទូរស័ព្ទពាណិជ្ជកម្មខ្មែរប៉ុស្តិ៍ ហ្វីឡាដែលហ្វីយ៉ា**

❖សុបិន : (២៦៧) ២៥៣-៣៩៤៧
❖ទូរស័ព្ទ នៅរ៉ូដអាយឡិន
❖សេរី : (៤០១) ៩១៩-៩៩៥៤

**ទូរស៊ីវិទ្យុសម្លេងខ្មែរអាមេរិកាំង**
❖ស៊ីដន : (២១៥) ២៨៤-១៣៤៣

Email : khmerpostec@gmail.com



**ការិយាល័យនិពន្ធ**

**កាសែត " ខ្មែរប៉ុស្តិ៍ " ប្រចាំសហរដ្ឋអាមេរិក**

**ឆ្នេរខាងលិច**

❖ មាជ សុវណ្ណារ៉ា
❖ គឹម សារឿន
❖ ម៉ៅ ចិត្រា
❖ រ៉ា នាថ
❖ សុភា ឫទ្ធិ
❖ ម៉ី សម្ផស្ស
❖ ចាន់ កុសល
❖ សុវណ្ណារិទ្ធ

**ឆ្នេរខាងកើត**

❖ ពិន សំខុន
❖ សួន សេរី
❖ ម៉ម យិន
❖ គឹម ភឿន
❖ ឆន យ៉ុង



**HIGH TECH AUTO REPAIR**

Foreign and Domestic

**"ហាយតិច"**

**ជួសជុលរថយន្ត**

**មានជំនាញដូចខាងក្រោម:**

- ធ្វើម៉ាស៊ីនឡាន
- ធ្វើភ្លើង "អេឡិចទ្រិច"
- ធ្វើបំពុងផ្សែង
- ធ្វើហ្វ្រាំង (BRAKE)
- ប្តូរប្រេង
- ធ្វើ "ការថ្លឹងភ្លើង" (TUNE UP)
- ត្រួតពិនិត្យ សុវត្ថិភាព នឹងផ្សែង (INSPECTION & EMISSION)







1601 Belfield Ave. Philadelphia, Pa 19141
Tel: 215-455-1344 Fax: 215-455-2085

ខុមហ្វ្រែល COMFREL

# របាយការណ៍លម្អិត ស្តីពីការបោះឆ្នោត

•••ថ្ងៃបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ អាណត្តិទី៤ ថ្ងៃទី២៧ កក្កដា ២០០៨ មានអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិជាង ១១000 នាក់ ។ អ្នកទាំងនោះសង្កេតការណ៍នៅ ៧0% នៃការិយាល័យបោះឆ្នោតទាំងអស់ គឺបានតែ ១៥ខេត្ត-ក្រុង និង ៥% នៃការិយាល័យខេត្ត-ក្រុងចំនួន៩ ទៀត ។ មានប្រជាពលរដ្ឋប្រមាណ ៧៤.៨% ត្រូវជា ៦លាននាក់ទៅបោះឆ្នោត ក្នុងចំណោមប្រជាពលរដ្ឋទាំងអស់ ៨.១២លាននាក់ ។

**ខាងក្រោមនេះជារបាយការណ៍លម្អិត :**

**១.** ភាពមិនប្រក្រតីនៅថ្ងៃស អំឡុងថ្ងៃបោះឆ្នោត រាប់សន្លឹកឆ្នោត និងបូកសរុបលទ្ធផល ។

ចំនួនភាពមិនប្រក្រតីក្នុងអំឡុងពេលថ្ងៃស និងដំណើរការបោះឆ្នោត ព្រមទាំងរាប់សន្លឹកឆ្នោត ដែលរួមមានប្រមាណ ២.០១២ ករណីដែលកើតមាននៅស្ទើរខេត្ត-ក្រុង ដូចជាក្រុងភ្នំពេញ ៦១៦ ករណី, បន្ទាយមានជ័យ ៣៥៤ករណី, កំពង់ចាម ១៧៧ករណី, កោះកុង ១១៦ករណី, តាកែវ ១០៧ករណី, កំពង់ឆ្នាំ ៩៣ករណី, ព្រៃវែង ៧៤ ករណី, កំពង់ធំ ៦៧ករណី, សៀមរាប ៦២ករណី កំពត ៥៩ករណី, ក្រចេះ ៥៩ករណី, ពោធិ៍សាត់ ៣៦ករណី, ស្វាយរៀង ៣០ករណី, បាត់ដំបង ២៩ករណី, កំពង់ស្ពឺ ២៧ករណី, ក្រុងព្រះសីហនុ ២៣ករណី, ព្រះវិហារ ២២ករណី, ក្រុងកែប ១០ករណី, កណ្តាល ៨ករណី, មណ្ឌលគិរី ៨ករណី, ឧត្តរមានជ័យ ៦ករណី, ប៉ៃលិន ៥ករណី និង ស្ទឹងត្រែង ៣ករណី ។ ករណីទាំងអស់នេះ ត្រូវបានអ្នកសង្កេតការណ៍រាយការណ៍មកក្នុងនោះរួមមាន :

**១.១ ថ្ងៃស (ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៨)**

. ខុមហ្វ្រែល បានសង្កេតឃើញថា វិទ្យុ និងទូរទស្សន៍ជាច្រើន បានខិតខំគោរពតាមបទបញ្ជា និងនិតិវិធី ក៏ដូចជាសេចក្តីណែនាំរបស់ គ.ជ.ប បានល្អ ដោយមិនផ្សាយឃោសនានយោបាយឱ្យគណបក្សណាមួយ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏មានការបិទការផ្សាយវិទ្យុមហានគរ FM 93.5 MHz ទាំងយប់ (វេលាម៉ោងប្រមាណ ១១យប់ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៨) ពីសំណាក់ក្រសួងព័ត៌មាន ដោយមូលហេតុកម្មវិធីវិទ្យុនេះ បានចាក់ផ្សាយប្រវត្តិរបស់លោក សម រង្ស៊ី ដែលមានការតិះទៀនដល់នាយករដ្ឋមន្ត្រី ហ៊ុន សែន ។វិទ្យុនេះត្រូវបានក្រសួងព័ត៌មានអនុញ្ញាតឱ្យផ្សាយឡើងវិញនៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៨ បន្ទាប់ពីម្ចាស់ស្ថានីយ៍វិទ្យុនេះ បានស្នើទៅក្រសួងព័ត៌មាន។

ការធ្វើសកម្មភាពឃោសនានាថ្ងៃស ដោយខុសច្បាប់កើតមានក្នុងខេត្តកំពង់ចាម កំពង់ឆ្នាំ កំពង់ស្ពឺ កំពត កោះកុង ព្រៃវែង ពោធិ៍សាត់ ក្រុងភ្នំពេញ សៀមរាប រតនៈគិរី និងតាកែវ យ៉ាងតិច ២៤ករណី ដូចជាការដើរចែកអំណោយដើម្បីទិញទឹកចិត្តអ្នកបោះឆ្នោតជាដើម ។ ករណីនេះ គណបក្សនយោបាយបានដាក់ពាក្យបណ្តឹងចំនួន២ ប៉ុន្តែមិនត្រូវបានដោះស្រាយទាំង២ករណី ។

បរិយាកាសដែលគ្មានសុវត្ថិភាពនៅក្នុងភូមិជុំវិញការិយាល័យបោះឆ្នោត ចំនួន២០ករណី ដូចជា នៅខេត្តបន្ទាយមានជ័យ កំពង់ចាម កំពង់ឆ្នាំង កំពត ព្រៃវែង ពោធិ៍សាត់ សៀមរាប ស្វាយរៀង តាកែវ និងក្រុងកែបជាដើម ។ ករណីនេះ គណបក្សនយោបាយបានដាក់ពាក្យបណ្តឹងចំនួន ៦ករណី ប៉ុន្តែមិនត្រូវបានដោះស្រាយចំនួន៥ករណី។

. ករណីខ្វះសម្ភារៈមួយចំនួនដែលនាំឱ្យមានការរាំងស្ទះ ឬយឺតយ៉ាវដល់ដំណើរការនៃការបើកការិយាល័យបោះឆ្នោតមាន ១៦ករណី នៅខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង ក្រចេះ សៀមរាប និងតាកែវ ។

**១.២.ថ្ងៃបោះឆ្នោត (ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨)**

. ការបាត់សិទ្ធិបោះឆ្នោតមានរហូតដល់ ៧០៣ ករណី ដែលកើតមាននៅខេត្ត-ក្រុង មួយចំនួនធំដូចជាក្រុងភ្នំពេញ ២៤៧ករណី, បន្ទាយមានជ័យ ១៦២ករណី, កំពង់ចាម ៤៨ករណី, តាកែវ ៣៣ ករណី, កំពត ២៧ករណី, កំពង់ធំ ២៤ករណី, សៀមរាប ២១ករណី, កំពង់ឆ្នាំង ១៨ករណី, ក្រុងព្រះសីហនុ ១៧ករណី, ព្រៃវែង ១៤ករណី, ព្រះវិហារ ១០ករណី,បាត់ដំបង ៨ករណី, កំពង់ស្ពឺ មណ្ឌលគិរី កោះកុង ក្រចេះ ព្រមទាំង ខេត្តស្វាយរៀង ។ គួរបញ្ជាក់ថា ករណីនេះ អ្នកបោះឆ្នោតដែលមានប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ឬមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែគ្មានឯកសារបញ្ជាក់អត្តសញ្ញាណ ឬអ្នកបោះឆ្នោត បានចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ឆ្នាំ២០០៧ តែមិនមានឈ្មោះបោះឆ្នោតឆ្នាំ២០០៨ នេះទេ ។ ករណីនេះ គណបក្សនយោបាយបានដាក់ពាក្យបណ្តឹងចំនួន៧១ ប៉ុន្តែមិនត្រូវបានដោះស្រាយចំនួន ២២ករណី ។

. អ្នកបោះឆ្នោតរកឈ្មោះមិនឃើញ មានប្រមាណ ៤៤៥ករណី ដែលកើតមាននៅខេត្តក្រុងមួយចំនួនដូចជា : ក្រុងភ្នំពេញ ២១៥ករណី, បន្ទាយមានជ័យ ១១០ករណី, កំពង់ចាម ២៩ ករណី, សៀមរាប ១៧ករណី, ក្រចេះ ១៦ករណី, តាកេវ ១៣ករណី, កំពត ១២ករណី, បាត់ដំបង កំពង់ធំ កំពង់ឆ្នាំង កោះកុង មណ្ឌលគិរី ព្រះវិហារ ព្រៃវែង ព្រមទាំងខេត្តស្វាយរៀង ។ ករណីនេះ គណបក្សនយោបាយបានដាក់ពាក្យប្តឹងចំនួន ៣៥ករណី, ប៉ុន្តែមិនត្រូវបានដោះស្រាយចំនួន ១៥ករណី ។

. មានសកម្មភាពដឹកជញ្ជូន ឬផ្តល់ជាលុយកាក់ដល់អ្នកបោះឆ្នោតក្នុងទ្រង់ទ្រាយធំទៅបោះឆ្នោត ពីសំណាក់សកម្មជនគណបក្សនយោបាយមួយចំនួន ជាពិសេសគណបក្សកាន់អំណាច (គណបក្សប្រជាជនកម្ពុជា) ។ ជាក់ស្តែងនៅឃុំសំពៅលូន ស្រុកសំពៅលូន ខេត្តបាត់ដំបង (ការិយាល័យលេខ ០៧២២) ស្រុកឡាបានសៀក ខេត្តរតនគិរី ខេត្តស្វាយរៀង ខេត្តឧត្តរមានជ័យ ខេត្តព្រៃវែង និងខេត្តកំពង់ចាមជាដើម ។

. ការឃោសនាតាមរយៈការចែកអំណោយ ឬឃោសនាដោយចែក បិទផ្ទាំងរូបភាព ឬខិតប័ណ្ណ ដើម្បីគាំទ្របេក្ខជនមួយចំនួនក្នុងខេត្តបន្ទាយមានជ័យ ព្រៃវែង កំពង់ធំ ភ្នំពេញ និងតាកែវ ។

. វត្តមានដោយខុសច្បាប់របស់អាជ្ញាធរមូលដ្ឋាន ជាពិសេស មេក្រុម មេភូមិ និងអាជ្ញាធរមូលដ្ឋានថិតនៅជុំវិញការិយាល័យបោះឆ្នោត ដើម្បីតាមឃ្លាំមើលអ្នកបោះឆ្នោត ដើម្បីណែនាំអ្នកបោះឆ្នោត ឱ្យគូសគណបក្សរបស់ខ្លួន ដែលជាហេតុបណ្តាល ឱ្យអ្នកបោះឆ្នោតមួយចំនួនមានអារម្មណ៍ភ័យខ្លាចចំនួន ១៤១ករណី ។ ករណីទាំងនេះ កើតឡើងនៅតាមការិយាល័យបោះឆ្នោតមួយចំនួន ក្នុងខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ កំពត កោះកុង ក្រចេះ ភ្នំពេញ ព្រៃវែង សៀមរាប ក្រុងព្រះសីហនុ ស្ទឹងត្រែង ស្វាយរៀង តាកែវ និងប៉ៃលិន ។

. មានការអនុញ្ញាតឱ្យកងកម្លាំងប្រដាប់អាវុធក្នុងឯកសណ្ឋាន និងការយកអាវុធជាតិផ្ទុះ ចូលទៅក្នុងការិយាល័យបោះឆ្នោត ១៣៣ករណី ក្នុងខេត្តកំពង់ចាម ភ្នំពេញ មណ្ឌលគិរី តាកែវ កំពង់ធំ ក្រចេះ និងសៀមរាប ។

. ការរារាំងអ្នកបោះឆ្នោតដោយផ្តល់ជាលុយកាក់ ឬសម្ភារៈផ្សេងៗ ដើម្បីកុំឱ្យទៅបោះឆ្នោះ មាន ៤ករណី នៅខេត្តកំពង់ចាម កំពង់ស្ពឺ សៀមរាប ។

. នីតិវិធីនៅការបោះឆ្នោត មិនត្រូវបានគោរពពេញលេញដោយមន្ត្រីការិយាល័យ ដែលនាំមកនូវភាពមិនប្រក្រតីចំនួន ២០៧ករណី នៅក្នុងការិយាល័យបោះឆ្នោត ។ ករណីភាគច្រើនកើតមាននៅទីក្រុងភ្នំពេញ កំពង់ចាម ព្រះវិហារ សៀមរាប តាកែវ កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ បាត់ដំបង ពោធិ៍សាត់ ស្វាយរៀង ឧត្តរមានជ័យ និងកោះកុង ។ ក្នុងនោះរួមមាន :

• មិនមានការបង្ហាញហិបឆ្នោតទទេ មុនពេលចាប់ផ្តើមដំណើរការបោះឆ្នោតមាន ២៥ករណី ។

• ការបើកការិយាល័យយឺតជាងម៉ោង ៧:00 ព្រឹក (បើកមិនតាមពេលកំណត់) មាន២៣ករណី ។

• ភាពមិនប្រក្រតីនានា ដែលនាំឱ្យបាត់ភាពសម្ងាត់នៃដំណើរការបោះឆ្នោតមាន ៨៩ករណី ។

• ការពិនិត្យមើលម្រាមដៃ ឬមិនជ្រលក់ទឹកខ្មៅលាងមិនជ្រះ ឬមិនពិនិត្យផ្ទៀងផ្ទាត់បញ្ជីឈ្មោះជាមួយឯកសារ ឬការឱ្យសន្លឹកឆ្នោតលើសពីមួយសន្លឹកមានចំនួន ៥០ករណី ។

• ការផ្អាក ឬបិទការិយាល័យនៅពេលកំពង់ដំណើរការបោះឆ្នោតមានចំនួន ២០ករណី កើតមានខេត្តកំពត់ បន្ទាយមានជ័យ ព្រៃវែង សៀមរាប តាកែវ និងក្រុងភ្នំពេញ ។

• មានអ្នកគ្មានសិទ្ធិបោះឆ្នោត ឬអ្នកមានស្នាមទឹកខ្មៅនៅម្រាមដៃសម្គាល់ថា បានបោះឆ្នោតរួចហើយ អនុញ្ញាតឱ្យបោះឆ្នោតម្តងទៀតមានចំនួន ១២ករណី កើតមាននៅខេត្តបន្ទាយមានជ័យ កំពង់ចាម ភ្នំពេញ ក្រចេះ និងខេត្តសៀមរាប ។

• មានអ្នកបោះឆ្នោតព្យាយាមយកសន្លឹកឆ្នោតចេញមកក្រៅ ដើម្បីឱ្យអ្នកបោះឆ្នោតផ្សេងៗទៀតគូសមាន ១ករណី កើតមាននៅខេត្តព្រះវិហារ ។

• ការបដិសេធ ឬមិនអើពើ ឬមិនប្រគល់ទម្រង់ប្តឹងតវ៉ា ឬជំទាស់ (ទម្រង់លេខ ១២០២) ទៅអ្នកបោះឆ្នោត ឬភ្នាក់ងារគណបក្សនយោបាយពីសំណាក់មន្ត្រីរៀបចំការបោះឆ្នោតមាន ១០ករណី

**(តទៅទំព័រទី០៩)**

ខ្មែរប៉ុស្តិ៍ មានសេចក្តីរីករាយ និងណែនាំដល់សហគមន៍ខ្មែរ




ឱសថស្ថានយើងនឹងជួយលោកអ្នកអំពីតម្លៃថ្នាំ ជាពិសេសដល់គ្រួសារដែលមានប្រាក់ចំណូលតិច

ឱសថស្ថានយើងខ្ញុំនឹងទូរស័ព្ទ ហើយធ្វើការជាមួយវេជ្ជបណ្ឌិត នឹងក្រុមហ៊ុនធានារ៉ាប់រងសុខភាព លោកអ្នកនឹងទទួលបានថ្នាំរបស់លោកអ្នកជាប្រាកដ

ឱសថស្ថាន Washington បានជួយអ្នកជំងឺរាប់ពាន់នាក់ នៅក្នុងសហគមន៍ ស្រាយបញ្ហាស្មុគស្មាញ ដើម្បីឱ្យបានឱសថដែលអ្នកទាំងនោះត្រូវការ ។

និយាយនឹងពន្យល់អំពីថ្នាំ ជាភាសាខ្មែរ

លឿនអស្ចារ្យ : ចាំ ១០ នាទី ឬយកទៅឱ្យដល់ផ្ទះ

600 Washington ave, Unit 18E Phila, PA - phone: 215-755-5100

## (តមកពីទំព័រទី០២) បទសម្ភាសន៍របស់ខ្មែរប៉ុស្តិ៍...

បើអ៊ីចឹងមហិច្ឆិតារបស់វៀតណាមអត់មានប្រែប្រួលទេ ។

ដោយសារអ្នកដឹកនាំសព្វថ្ងៃនេះ កាន់តែបើកដៃឱ្យវៀតណាមមកដាក់នឹមត្រួតត្រានៅស្រុកខ្មែរហ្នឹងឯង ។ បើកាលណាខ្មែរឈ្លោះប្រកែកគ្នា គណបក្សនេះ គណបក្សនោះប្រឈមមុខដាក់គ្នា បើអ៊ីចឹងហើយ គណបក្សកាន់អំណាច គេបំបាក់បំបែកខ្មែររវាងខ្មែរទៀត ហើយវៀតណាមគេឱ្យបំបះបំបែកពីរឿងខាងវៀតណាម ហើយនឹងគណបក្សខ្មែរ គណបក្សមួយ និងគណបក្សមួយ ។ ហើយគណបក្សកាន់អំណាចនេះ គេបំពាក់បំបែកខ្មែរ និងខ្មែរទៀត មិនឱ្យខ្មែរយើងសាមគ្គីគ្នាទេ អាហ្នឹងជាគំនិតរបស់វៀតណាម ហើយ និងអ្នកដឹកនាំ អ្នកកាន់អំណាចសព្វថ្ងៃនេះ សូមជំរាបអ៊ីចឹង ។

**សំនួរ** : តើលោកអតីតនាយករដ្ឋមន្ត្រី មានការអំពាវនាវចំនុចណាមួយ ធ្វើឱ្យប្រជាពលរដ្ឋខ្មែរភ្ញាក់រលឹក ខ្មែរសាមគ្គីគ្នា ដើម្បីទប់ស្កាត់នៃប្រទេសជិតខាង ដូចជាលោកអតីតនាយករដ្ឋមន្ត្រីលើកឡើងថា អាចយួនមានផែនការឈ្លានពានទឹកដីខ្មែរហ្នឹង ដើម្បីឱ្យមានការសាមគ្គីគ្នាឡើងវិញ កុំឱ្យខ្មែរឈ្លោះបែកបាក់ខ្មែរហ្នឹង បាទ ។

**ចម្លើយលោក ប៉ែន សុវណ្ណ** : ក្នុងឱកាសនេះតាមសារព័ត៌មានរបស់លោកនៅសហរដ្ឋអាមេរិក ហើយខ្ញុំមានឱកាសនេះ ខ្ញុំសូមអំពាវនាវដល់ប្រជាពលរដ្ឋកម្ពុជាទូទៅទាំងប្រទេសគ្រប់មជ្ឈដ្ឋាន និងព្រះថេរានុថេរៈ គ្រប់ព្រះអង្គទូទាំង ប្រទេស ឥឡូវហ្នឹងវាឃើញថា ប្រទេសខ្មែរយើងកំពុងធ្លាក់ក្នុងវិបត្តិយ៉ាងជ្រៅ **ទី១.** អ្នកកាន់អំណាចសព្វថ្ងៃនេះ កាន់តែបើកដៃឱ្យនិគមជនវៀតណាមមកតាំងទីលំនៅក្នុងស្រុកខ្មែរខុសច្បាប់ និងមានសិទ្ធិធ្វើអត្តសញ្ញាណប័ណ្ណ មានសិទ្ធិធ្វើប័ណ្ណគ្រួសារ ដើម្បីបានសិទ្ធិបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រគណបក្សកាន់អំណាច ហើយមួយទៀត គឺបូរណភាពទឹកដីកម្ពុជា ហើយនឹងអធិបតេយ្យភាពកម្ពុជាកាន់តែបាត់បង់ អ្នកកាន់អំណាចសព្វថ្ងៃ ដឹកនាំប្រទេសជាតិនេះ គឺធ្វើឱ្យប្រទេសឱ្យមានករីកចំរើនទេ គេអភិវឌ្ឍន៍តែអ្នកមាន ធ្វើឱ្យអ្នកក្រកាន់តែក្រ ទន្ទឹមនឹងនោះ គេផ្តល់សម្បទានដីស្រែ ដីចំការទៅឱ្យវៀតណាម ដោយខ្មែរកំពុងខ្វះដីធ្វើស្រែ ។ ហើយមួយទៀតឱ្យនិគមជនវៀតណាមមកតាំងទីលំនៅខុសច្បាប់នៅលើផ្នកទ្រូ ទន្លេសាបនេះ គេបំផ្លិចបំផ្លាញមច្ឆាជាតិយើង សព្វថ្ងៃហ្នឹងមាន ទឹកអត់ ត្រីមានព្រៃអត់ឈើ ហើយសព្វថ្ងៃប្រជាពលរដ្ឋខ្មែរយើងទាំងប្រទេសមានការក្តៅក្រហាយណាស់ អ្នកមានអំណាចបើកអានាធិបតេយ្យ **ទី១.** ឱ្យកាប់បំផ្លាញព្រៃឈើ ដោយអានាធិបតេយ្យ ។ បញ្ហា **ទី២.** រឿងដីធ្លី រំលោភបំពានមកលើកសិករក្រីក្រ គឺថារឹបអូសដីស្រែចំការ ហ្នឹងយ៉ាងកម្រោលឱ្យទៅឱ្យអ្នកមានអំណាច អ្នកមានលុយ ហើយនិងក្រុមហ៊ុនប្រទេសក្រៅ ដូចជាក្រុមហ៊ុនវៀតណាម គេបានយកដីខ្មែរអស់រាប់សែនហិតាអស់ទៅហើយ ហើយគេបញ្ចូល និគមន៍របស់គេមកត្រួតត្រានៅលើទឹកដីខ្មែរ ។ បើអ៊ីចឹងខ្ញុំឃើញថា យើងប្រទេសខ្មែរយើងបានបោះឆ្នោតពអាណត្តិ យើងខ្មែរយើងនៅតែជួបអភ័យ អ្នកក្រនៅតែក្រ អ្នកក្រអត់ច្បាប់ អ្នកមានច្បាប់ គឺអ្នកមានអំណាចច្បាប់នៅនឹងមាត់ គេអនុវត្តច្បាប់ព្រៃ ។

ក្នុងឱកាសនេះគណបក្សសិទ្ធិមនុស្ស បានយល់បរិយាកាសក្នុងសង្គម យល់នូវឆន្ទៈរបស់ប្រជាពលរដ្ឋ យល់នូវការទាមទាររបស់ប្រជាពលរដ្ឋ ហើយមានគណបក្សណាមួយ ជួយស្រោចស្រង់មាតុភូមិកម្ពុជា ឱ្យចាកផុតពីសភាពរស់នៅក្បែររណ្តៅមរណៈ ដោយសារតែគណបក្សកាន់អំណាចសព្វថ្ងៃ គេកំពុងបំពាន ។ បើអ៊ីចឹងក្នុងឱកាសនេះ គណបក្សសិទ្ធិមនុស្ស គឺបានបង្កើតឡើងហើយ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ ដើម្បីរួមចំណែកស្រោចស្រង់ជាតិ មាតុភូមិកម្ពុជាស្តាប្រទេសជាតិយើង ឱ្យទៅជាប្រទេសកម្ពុជាយើងមានលទ្ធិប្រជាធិបតេយ្យពិតប្រាកដ មានបូរណភាព និងអធិបតេយ្យភាពពេញលេញ ។ នេះខ្ញុំសូមបញ្ជាក់ដល់ជនរួមជាតិ ហើយមានតែគណបក្សសិទ្ធមនុស្សទេ ដែលអាចប្រឈមមុខ ហើយទទួលខុសត្រូវចំពោះឧប្បត្តិហេតុយុត្តិធម៌របស់ប្រជាពលរដ្ឋ គ្មានគណបក្សណាធ្វើបានទេ ពីព្រោះខ្ញុំឃើញក្នុងឱកាសនេះ គណបក្សសិទ្ធិមនុស្សនេះ កំពុងគោរពឆន្ទៈរបស់ប្រជាពលរដ្ឋ បំរើឆន្ទៈរបស់ប្រជាពលរដ្ឋ បំរើ និងគោរពអធិតេយ្យភាពជាតិខ្មែរ ។ ពេលនេះ បើខ្មែរយើងមិនរួបរួមគ្នាទេ មិនយកឆន្ទៈរបស់ប្រជាបលរដ្ឋមកធ្វើជាត្រីវិស័យរបស់យើងទេ ប្រទេសខ្មែរយើងនឹងធ្លាក់ទៅក្នុងវិបត្តិបី : **ទី១** ប្រទេសក្រៅគេមុខជាឈ្លានពានលើប្រទេសខ្មែរ ។ បញ្ហា **ទី២** របបផ្តាច់ការនៅកាន់កាប់ទឹកដីខ្មែរទៀត ។ បញ្ហា **ទី៣** រាល់អំពើពុករលួយនេះ កាន់តែធ្ងន់ធ្ងរៗឡើងៗនៅស្រុកខ្មែរ បើយើងសាមគ្គីគ្នាយើងស្រោចស្រង់ជាតិមាតុភូមិកម្ពុជាយើងឱ្យមានកិត្តិយសកថ្លៃថ្នូ ឱ្យប្រជាបលរដ្ឋខ្មែរយើងចាក់ផុតពីរបបផ្តាច់ការ ចាកផុតពីនឹកត្រួតត្រាពីប្រទេសក្រៅ ដើម្បីយើងស្រោចស្រង់ជាតិមាតុភូមិប្រទេសកម្ពុជា ព្រោះអ្នកកាន់អំណាចសព្វថ្ងៃ យកប្រទេសខ្មែរធ្វើកម្មសិទ្ធិ យកប្រជាពលរដ្ឋខ្មែរជាទាសករ មានការត្រួតត្រាពីបរទេស បើអ្នកមិនរួបរួមគ្នាទេនោះ គឺថា ប្រទេសខ្មែរថ្ងៃក្រោយនេះ ត្រូវក្លាយទៅដូចជា នគរចំប៉ាភាគតិច នៅក្នុងប្រទេសខ្លួនឯងហ្នឹងហើយ ។ តែបើយើងមិនទៅបោះឆ្នោត ក៏ពេលនោះ តែយើងត្រូវរងគ្រោះទៀតហើយ ពីព្រោះអ្នកកាន់អំណាចសព្វថ្ងៃផ្តាច់ការ កាន់តែផ្តាច់ការ ហើយគេមិនយល់អ្វីជាកិត្តិយសជាតិមាតុភូមិកម្ពុជាទេ ហើយនេះ ខ្ញុំសូមអំពាវនាវ និងសុំធ្វើបណ្តាំដោយយល់ឃើញថា ប្រទេសជាតិយើងសព្វថ្ងៃនេះ ត្រូវបោះឆ្នោតខែ៧ ត្រូវជាខែភ្លៀង បើអ៊ីចឹងប្រជាពលរដ្ឋ យើងត្រូវជំនះ យើងមានតែ១ថ្ងៃ ត្រូវទៅបោះឆ្នោត ទោះបីមានមេឃភ្លៀង មានព្យុះអ្វីក៏ដោយចុះ ។ សូមបងប្អូនជនរួមជាតិខ្មែរ នៅក្នុងស្រុកគ្រប់និន្នាកាគណបក្សនយោបាយ ដែលយើងជាជាតិខ្មែរសុទ្ធសារជាតិជាខ្មែរ យើងកើតនៅលើទឹកដីខ្មែរ យើងគោរពបូរណភាពខ្មែរយើងទៅបោះឆ្នោត ទោះបីមានធាតុអាកាសយ៉ាងណាក៏ដោយចុះ យើងសុំថា យើងត្រូវម្ចីម្នាទៅបោះឆ្នោតឱ្យគណបក្សសិទ្ធិមនុស្សមានលេខរៀងទី១១ មានរូបព្រះច័ន្ទពេញវង្សបូរមីបាទ ហើយជាទីបញ្ចប់នេះ ខ្ញុំសូមជូនពរប្រទានពរ និងជូនពរដល់ព្រះថេរានុថេរៈ ហើយជូនពរដល់ប្រជាពលរដ្ឋខ្មែរគ្រប់មជ្ឈដ្ឋាន និងបងប្អូន ពលទាហាន នាយទាហាន សូមបងប្អូនមានសុខភាពល្អ ហើយសូមបងប្អូនជំនះឱ្យបាន

(តទៅទំព័រទី២១)


# លោកមានសុខភាពរាល់ថ្ងៃ មិនប្រក្រតី សូមប្រើ reliv

## សក្ខីកម្ម

ខ្ញុំមានជំងឺ Cancer ខួរក្បាល ហើយបានវះក្បាលពីរដង ខ្ញុំ ស្ថិតក្នុងការព្យាបាល Chemotheraphy ១៨ ខែ ....ពីរ ឆ្នាំក្រោយមកខ្ញុំមានគ្រោះថ្នាក់រថយន្តទៀត ។

ពេលបានជួប Relive មួយ ឆ្នាំក្រោយមកការឈឺចុកចាប់ក៏បាត់ទៅអស់ ខ្ញុំប្រែមាន កម្លាំង ហើយអាចហាត់ប្រាណវិញបាន មិនតែប៉ុណ្ណោះចុះ ទម្ងន់ទៀតផង ។

Stephanis -Emmons **(817) 847-5476**

The Reliv scientists formulate the most recent nutrition research into products that scientifically advance, nutritionally complete, and is proven to restore the boby functions.

**របៀបប្រើ :** រៀងរាល់ព្រឹក ដួស RELIV មួយស្លាបព្រាវង្វាល់ពីកំប៉ុង A មួយស្លាបព្រាវង្វាល់ទៀត ពីកំប៉ុង B ដាក់ទៅក្នុងកែវមានទឹកធម្មតា ឬទឹកផ្លែ ឈើកូរលាយគ្នា រួចពិសារព្រឹកម្តង ល្ងាចម្តងទទួលលទ្ធផលទាន់ចិត្ត

□ **ទូរស័ព្ទសំរាប់ជាវ** (636) 537-9715

**ជាវ** ① RELIV CLASSIC : A
② RELIV INNERGIZE : B

**កុំភ្លេចឱ្យលេខ** Reliv Distributor :
(RNC.# 7070 438001)

□ **ទូរស័ព្ទ :** (267) 253-3947 **សំរាប់ហៅ**
**បើលោកអ្នកចង់ចែកចាយជូនមិត្តភក្តិបងប្អូនបន្ត**
**ទៅទៀតជា** Relive Distributor

**RCN# 7070438001 www.reliv.com**

នៅ **VIRGINIA CALL VANNDY 1-703 415-6257**

**Please Call : (267) 253-3947**

RELiV 20th anniversary
reliv



# ខេរី ផាត

ឆ្នាំនេះ នាងបានក្លាយជានិស្សិតសកលវិទ្យាល័យ "ផេន ស្តេត" (PENN STATES) បន្ទាប់ពីឆ្លងការសិក្សានៅវិទ្យាល័យ ប្រកបដោយជោគជ័យ និងប្រកបដោយការងារស្ម័គ្រចិត្តយ៉ាងច្រើនសន្ធឹក ។ គ្រួសារ ខេរី មានសំណាងណាស់ ដោយ ខេរី ក្តី អេមី ជាបងស្រីក្តីក៏បានទៅរៀនមហាវិទ្យាល័យ ដូចគ្នា ។ ជាគ្រួសារលោក ផាត និងអ្នកស្រី សៀម នៅក្នុងចំណោមគ្រួសារដ៏តិចតួចនៅសហគមន៍ខ្មែរ ដែលបានឆ្លងផុតកិរិតវិទ្យាល័យ ប្រកបដោយការគ្រោះថ្នាក់គ្រប់យ៉ាង ។



ខេរី ធ្វើការយុវជន (Junior Stakeholders) យ៉ាងព្យាយាម ហើយជួយដឹកនាំអ្នកឯទៀតឱ្យមានចរិតមាយាទល្អប្រសើរ ។

**Being a member of the South Philadelphia's Junior Stakeholder Group...**

By Carrie Phat

First of all, what is Junior Stakeholder? Junior Stakeholders are teens like myself who want to make a difference in our community. We are not afraid to voice our opinions and express how we feel. Not to mention, we value the opinions of others. Through education, training and workshops, Junior Stakeholders will develop leadership skills and become productive in our community.

From my perspective, I feel honored to be a junior stakeholder. I started this program with hesitation and second thoughts. However, as of now, the two years I've been involved in the program was amazing. The Youth Voice Project (YVP), a program only for the junior stakeholders, is a radio broad casting program that all the members are involved in. YVP is a collaboration between Cambodian-American Radio Network and Junior Stakeholders which incorporates radio broadcasting training, media literacy, and community activism. With skills we gained from Mr. Glenn Wrighten and Roger Pin, we create a one-hour broadcasting program on any topic we feel is important to our community and us. Through the radio broad casting process, we learn to view media, do critical research, and develop leadership and creative skills needed to be successful individuals.

My whole experience being a Junior Stakeholder has been exciting. I gained much knowledge that will create successful future outcomes. This program provides skills, equipment and the mentoring I need to be a star student. Our program meets twice a week and occasionally, we meet on Saturdays for certain events. We have discussions tackling the topic of truancy, crime, drug, diversity, and other issues we feel the affects our community. In addition, we also do field work. We do outreach in the community, provided services, and perform interviews. I can actually say that I've interviewed city councilmen and my peers interviewed the former major John Street. I'm proud to say that through this program, I am a youth activist. Our mission statement is, Junior Stakeholders will value the importance of an education and become active members in their members. On that note, I hope to achieve this goal and create a positive change in the future.

# នាទីអានសៀវភៅ

•••ជាថ្មីម្តងទៀត សុជាតា សិត បានអានសៀវភៅមួយឈ្មោះថា "**The Rice Mother**" ហើយធ្វើសេចក្តីសង្ខេបជូនជាភាសាអង់គ្លេសដូចតទៅ :




**The Rice Mother** - Manicka, Rani

Rani Manicka made an astonishing entrance as a first time novelist with this book. This historical fiction is a multigenerational Malaysian family saga set during the World War II's Japanese invasion. Lakshmi, at age 14, were married off to Ayah, a widower more than twice her age with two children barely younger than her. She was told that Ayah is wealthy yet in fact he's just a clerk with no ambitions in life what so ever. But Lakshmi, who went on to bear six children, decided to take control of her own destiny and turned the lemon into lemonade the best she could. The story is told from the point of views of different characters. There's a little mention of Cambodia, but I think what is said is completely false. Still this is a novel that is worth making into a movie some day. It's already translated into many languages. I think women would really enjoy reading this book, though I'm not sure about men.

If you liked this book you may also like Memoirs of a Geisha - Golden, Arthur.

**Socheata Seth, Librarian**

From :Philadelphia



ហាងខ្មែរជួសជុលរថយន្ត

បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ

**Rathe`s Auto Service**

State and Emission
Inspection General
Repairs and Maintenance

MON-SAT, 8:30AM -5:30PM
SUN. EMERGENCY ONLY




-ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
-មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
-មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ -មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : -ដូរប្រេងកិរិត ៥ ក្វាត $22. - INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ ពាក់-មានជូនប័ណ្ណពិសេស សំរាប់ដូរប្រេង ចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
-តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត
- ប្តេជ្ញាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ ។
ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL: (215) 329-2418
Fax: (215) 329-2419.Rath CELL: (215) 431-6376

(តមកពីទំព័រទី០១) **ការជួបជុំរំលឹកអតីតកាលនៃ...**

ដើម្បីបុព្វហេតុការពារជាតិមាតុភូមិប្រជាពលរដ្ឋ ។ ការសម្រេចចាកចោលពីមូលដ្ឋានកងទ័ពជើងទឹក មិនមែនមានន័យថា យើងបរាជ័យចាញ់ការវាយលុករបស់ខ្មាំងខ្មែរក្រហមឡើយ ។ គឺអ្វីដែលឧបសគ្គសំរាប់ក្នុងកងទ័ពនាវាយើង គឺគ្មានប្រេងសំរាប់បំរើការប្រយុទ្ធនេះបញ្ហាទី១ ចំណែកបញ្ហាទី២ ការចាកចេញពីសមរភូមិព្រោះតែការគិតឃើញថា មិនអាចចុះចូល ឬសារភាពនៅជាមួយខ្មែរក្រហមបាន ។ ហើយការសម្រេចចុងក្រោយរបស់កងនាវាខ្មែរ គឺ

រដ្ឋអាមេរិក, កាណាដា, បារាំង និងពីប្រទេសកម្ពុជាបានជួបជុំគ្នា ដើម្បីរំលឹកនូវអនុស្សាវរីយ៍ពីអតីតកាលនៃកងនាវារួមអាវុធជាមួយគ្នា ។

ថ្លែងទៅកាន់អតីតកងនាវាយុទ្ធមិត្តលោកវរៈសេនីយត្រី ឃួន វណ្ណឌី ប្រធានអតីតនាវាខ្មែរ ក្នុងពិធីរៀបចំ Re-Union ២០០៨ បានឱ្យដឹងថា ការធ្វើពិធីនេះឡើង គឺក្នុងន័យយើងទាំងអស់គ្នាធ្លាប់ជាមិត្តរួមអាវុធជាមួយគ្នា ជាអតីតកងទ័ពនាវាខ្មែរទាំងអស់ឱ្យរស់នៅក្នុងលក្ខណៈជាគ្រួសារតែមួយ ពុំអាចបំភ្លេចបាន

២លើកហើយ នៅឆ្នាំ២០០០-២០០៤ ដែលពិធីនេះប្រារព្ធធ្វើក្នុងអំឡុង៤ឆ្នាំម្តង ។

*វរៈសេនីយឯក ហែម ច័ន្ទត្រីស្នា នាយសេនាធិការកងនាវាខ្មែរប្រចាំតំបន់រាម បាននិយាយថា ក្រោយពីព្រឹត្តិការណ៍ស្រុកធ្លាក់ទៅលើកណ្តាប់ដៃខ្មែរក្រហម ក្នុងថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ គឺនៅថ្ងៃទី១៨ ខែមេសា ក្រោយមួយថ្ងៃនោះ ទាំងកងទ័ពនាវា និងក្រុមគ្រួសារ ប្រមាណជាង៥ពាន់នាក់ បានផ្ទុកនៅលើនាវាចំនួនជាង២០គ្រឿង ក្នុងការចាកចេញពីតំបន់កងទ័ពជើងទឹករាម ទៅកាន់ប្រទេសម៉ាឡេស៊ី ប៉ុន្តែ



អតីតភរិយារបស់លោកឧត្តមសេនីយ៍ទោ វង់ សារិនឌី មេបញ្ជាការកងទ័ពនាវាខ្មែរ ទទួលផ្លាកកិត្តិយសទីគោរពរបស់ប្តីដែលបានស្លាប់ក្នុងរបបខ្មែរក្រហម



ពិធីជួបជុំអតីតកងនាវាខ្មែរ៤ឆ្នាំម្តង (រូបថត ឯលទ៉ាន់ថា)

បណ្តាំរបស់មេបញ្ជាការកងនាវាខ្មែរលោកឧត្តមសេនីយទោ វង់ សារិនឌី បានប្រាប់សូមឱ្យកូនចៅទាំងអស់សម្រេចអនាគតវាសនាដោយខ្លួនឯងក្នុងនាទីចុងក្រោយ ។

ការអះអាងនៃអតីតវីរជនកងទ័ពជើងទឹកទាំងពីររូបនេះ បានប្រាប់កាសែតខ្មែរប៉ុស្តិ៍នៅក្នុងពិធីជួបជុំអតីតកងនាវាខ្មែរ ដែលបានធ្វើកាលពីថ្ងៃទី៩ ខែសីហា ឆ្នាំ២០០៨ នៅក្រុង Garden Grove រដ្ឋ California ដែលមានអតីតនាយទាហាន, ពលទាហាននៃកងទ័ពនាវាខ្មែរចំនួន៣៥០នាក់ មកពីបណ្តារដ្ឋនានានៃសហ-

ឡើយ ។ ដូច្នេះការនឹករលឹកដល់អនុស្សាវរីយ៍ចាស់ៗ ដែលយើងធ្លាប់មានមកជាមួយគ្នា ពិសេសនៅលើនាវាចម្បាំងនៅសមរភូមិតាមដងទន្លេសមុទ្រ និងនៅលើកោះទាំងឡាយក្នុងឈូងសមុទ្រខ្មែរ ឬនៅតាមមូលដ្ឋាននានានៃកងទ័ពនាវាខ្មែរ ដែលជាអនុស្សាវរីយ៍បានដៅជាប់នៅក្នុងបេះដូងរបស់យើងទាំងអស់គ្នាលុះអវសាន្ត ។

លោកសក្តិបួន ឃួន វណ្ណឌី បានបញ្ចប់នូវការថ្លែងឱ្យដឹងថា សូមឱ្យឥទ្ធិពលរាត្រីនេះជាចំណងសាមគ្គីរវាងយើងទាំងអស់គ្នាជានិរន្ត ។

ពិធីជួបជុំអតីតកងនាវាខ្មែរបានធ្វើកន្លងមក

ស្ថានការណ៍នោះបានប្រែត្រឡប់ ដោយមានកងទ័ពនាវាមួយចំនួនធំបានបើកកប៉ាល់ដឹក ទ័ព និងក្រុមគ្រួសារត្រឡប់ចូលប្រទេសកម្ពុជាវិញ ដោយនៅសល់តែកប៉ាល់ចំនួន៥គ្រឿងតែប៉ុណ្ណោះ ដែលផ្ទុកកងទ័ព និងក្រុមគ្រួសារជាង៧០០នាក់ បន្តទៅរស់នៅតំបន់មូលដ្ឋានកងទ័ពអាមេរិក នៅក្នុងប្រទេសហ្វីលីពីន (Subic Bay, Clark Air Field) រយៈពេល២៤ថ្ងៃ ទើបមកកាន់សហរដ្ឋអាមេរិកទាំងអស់គ្នា ។

របបសាធារណរដ្ឋខ្មែរ ដែលគ្រប់គ្រងដោយសេនាប្រមុខ លន់ នល់ ដែលដួលរំលំ តាមអ្នក

ប្រវត្តិសាស្ត្របានបង្ហាញឱ្យដឹងថា មានកត្តានយោបាយច្រើន ដែលធ្វើឱ្យបរាជ័យ ដែលការបរាជ័យនោះមិនកើតចេញពីក្រុមកងទ័ពទាំង៣ផ្នែកទន់ខ្សោយ, រត់ចោលសមរភូមិនោះទេ គឺវាកើតចេញពីផ្នត់នយោបាយធំៗ មានបញ្ហាប្តូរទិសចរន្តនយោបាយរបស់សហរដ្ឋអាមេរិកចំពោះសង្គ្រាមនៅវៀតណាមរបស់មន្ត្រីការបរទេសអាមេរិក Henry Kissinger និងប្រធានាធិបតី Richard Nixon ក្នុងខណៈស្របពេលអំឡុងនោះ មានការផ្លាស់ប្តូររបបដឹកនាំអាមេរិក ពីគណបក្សសាធារណរដ្ឋទៅគណបក្សប្រជាធិបតេយ្យនោះផង ។ ដែលធ្វើឱ្យអាមេរិកកាត់ផ្តាច់ជំនួយយោធា, ថវិការួមទាំងជំនួយកងទ័ពផងនោះ និងបញ្ហាការពុករលួយបែបអនាធិបតេយ្យរបស់ថ្នាក់ដឹកនាំធំៗមួយចំនួនរួមនឹងការឃុបឃិតនយោបាយត្រជាក់បែបប្រជាភិថុតរបស់ខ្មែរក្រហមតាមមូលដ្ឋានប្រជាជនបង្កើតការជឿជាក់តាមការយកលេសព្រះបន្ទូលប្រមុខរដ្ឋ សីហនុ អំពាវនាវឱ្យកូនចៅចូលព្រៃម៉ាគីរំដោះជាតិ ដែលឱកាសនោះស្តេច សីហនុកំពុងតែមានប្រជាប្រិយភាពពីសំណាក់ប្រជារាស្ត្រធ្វើឱ្យខ្មែរក្រហម មានកម្លាំងក្នុងការឃោសនា ដើម្បីពង្រឹងគោលជំហរនយោបាយប្រយុទ្ធប្រឆាំងជាមួយកងទ័ព លន់ នល់ រហូតដល់ឈានទៅរកការជោគជ័យនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ដែលជាថ្ងៃចុងក្រោយរបស់របបសាធារណរដ្ឋខ្មែរត្រូវដួលរលំទាំងស្រុង ។ ខ្មែរក្រហមក្តោបអំណាច៣ឆ្នាំ៨ខែ២០ថ្ងៃបានសម្លាប់ផ្តាច់ផ្តិលជីវិតខ្មែរអស់ប្រមាណ ១ លាន ៧សែននាក់ ។ នៅទីបំផុតសោកនាដកម្មសង្គ្រាមនៅកម្ពុជាពីមួយជំនាន់ ទៅមួយជំនាន់ ធ្វើឱ្យកម្ពុជាហិនហោច, អន់ថយ តើជាកំហុសអ្នកដឹកនាំមួយណា ? ៕


**Washington Wellness Care** មន្ទីរថែរក្សាខ្លួនប្រាណ "វ៉ាស៊ីនតុន"

Medical & Rehab.

ដោយវិជ្ជាពេទ្យ និងការបង្ហាត់រាងកាយឱ្យដើរឡើងវិញ

Medical & Rehab.
500 Washington Ave., 1st Fl.
Philadelphia, Pa 19147
Phone: 215.551.6838. Fax: 215.551.6718

**Dr. Scott C. Tran, D.C. Dr. Michael Barno, D.C. Dr. Zohar Stark, M.D.**

***We are specialized in treating:***

- Auto Accident Injuries - Work Related Injuries - Slip & Fall Injuries

**យើងមានជំនាញក្នុងការព្យាបាល :**

☞ របួសដោយគ្រោះថ្នាក់រថយន្ត ☞ របួសដោយទាក់ទងនឹងកន្លែងធ្វើការ ☞ របួសដោយរអិល ឬដួល

We have staffs who speaks Vietnamese, Chinese, and Cambodian
For Cambodian and Vietnamese Speaking Staff, please call Ricky Son at 215.380.1350
For English Speaking Staff, please call 215.551.6838

**យើងមានបុគ្គលិកដែលនិយាយភាសា វៀតណាម, ភាសាចិន , និងភាសាខ្មែរ**
ទាក់ទងជាមួយបុគ្គលិកខ្មែរ និងវៀតណាម សូមទូរស័ព្ទទៅ រីគី សុន **(215) 380-1350**
ទាក់ទងទៅបុគ្គលិកនិយាយភាសាអង់គ្លេស សូមទូរស័ព្ទទៅ **(215) 551-6838**

(តមកពីទំព័រទី០៥)

# របាយការណ៍លម្អិត ស្តីពីការ...

ដែលកើតមាននៅខេត្តបន្ទាយមានជ័យ កំពង់ឆ្នាំង ក្រុងភ្នំពេញ និងខេត្តស្វាយរៀង ។

ទន្ទឹមនឹងនេះ ខុមហ្វ្រែល ក៏បានរកឃើញនូវភាពមិនប្រក្រតីផ្សេងៗដែលកើតឡើងក្រៅពីភាពមិនប្រក្រតីដូចដែលបានរៀបរាប់ខាងលើ កើតមានរហូតដល់ទៅ ១៥៨ករណី បន្ថែមទៀតដែលកើតមាននៅស្ទើរតែគ្រប់ខេត្ត-ក្រុង ។

**១.៣. ភាពមិនប្រក្រតីក្នុងដំណើរការរាប់សន្លឹកឆ្នោត និងបូកសរុបលទ្ធផល**

**១.៣.១ ភាពមិនប្រក្រតីក្នុងការថែរក្សាសុវត្ថិភាពសន្លឹកឆ្នោត**

បន្ទាប់ពីដំណើរនៃការបោះឆ្នោតបានបញ្ចប់នៅម៉ោង ៣រសៀល ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០០៨ ខុមហ្វ្រែល នៅបន្តពិនិត្យលើការថែរក្សាសុវត្ថិភាពសន្លឹកឆ្នោតរបស់មន្ត្រីរៀបចំការបោះឆ្នោត ដែលក្នុងនោះ ខុមហ្វ្រែល បានរកឃើញនូវភាពមិនប្រក្រតីមួយចំនួនដូចជា :

. ការអនុញ្ញាតឱ្យមនុស្សគ្មានភារកិច្ចដើរចេញចូលការិយាល័យបោះឆ្នោត នៅពេលប្រកាសបិទការិយាល័យចំនួន ១៨ករណី កើតមាននៅខេត្តបន្ទាយមានជ័យ កំពង់ឆ្នាំង ភ្នំពេញ សៀមរាប និងខេត្តតាកែវ ។

. ករណីមិនមូលភ្ជិតសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោត និងមិនចាក់សោឃ្លុំហិបឆ្នោតមានចំនួន ៤ករណី មាននៅខេត្តបាត់ដំបង និងខេត្តព្រៃវែង ។

. ការរំខាន រាំង ដល់ដំណើរការរាប់សន្លឹកឆ្នោតមាន ២៣ករណី កើតមាននៅខេត្តបន្ទាយមានជ័យ កំពង់ឆ្នាំ ព្រៃវែង ភ្នំពេញ និងខេត្តតាកែវ ។

**១.៣.២ ភាពមិនប្រក្រតីក្នុងដំណើរការរាប់សន្លឹកឆ្នោតនិងការបូកសរុបលទ្ធផលនៅការិយាល័យរាប់សន្លឹកឆ្នោត**

នៅពេលរាប់សន្លឹកឆ្នោត កាសង្កេតឃើញថាមន្ត្រីការិយាល័យរាប់សន្លឹកឆ្នោតមិនបានគោរពតាមបទបញ្ជា និងនិតិវិធី ព្រមទាំងសេចក្តីណែនាំរបស់ គ.ជ.ប ដែលធ្វើឱ្យមានភាពមិនប្រក្រតីមួយចំនួនកើតឡើងដូចខាងក្រោម :

. ការពន្យាពេលរាប់សន្លឹកឆ្នោតក្នុងការិយាល័យរាប់សន្លឹកឆ្នោតមានចំនួន ១៣ករណី ដែលកើតមាននៅខេត្តបន្ទាយមានជ័យ កំពង់ចាម កំពង់ធំ ភ្នំពេញ ព្រៃវេង និងខេត្តតាកែវ ។

. ការមិនអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ចូលរួមសង្កេតការណ៍រាប់សន្លឹកឆ្នោត មានយ៉ាងហោចណាស់ ២ករណី នៅខេត្តបន្ទាយមានជ័យ ព្រៃវែង ។

. មិនបង្ហាញឱ្យអ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយចូលរួមពិនិត្យសោឃ្លុំមុននឹងបើកគំរបហិបឆ្នោតមានយ៉ាងណាស់ ២ករណី នៅខេត្តកំពង់ចាម ។

. ការអានញាប់ពេកមិនច្បាស់ ឬមិនបង្ហាញសន្លឹកឆ្នោតទៅដល់អ្នកសង្កេរការណ៍ ឬគណបក្សនយោបាយមានចំនួន ២៦ករណី កើតមាននៅខេត្តបន្ទាយមានជ័យ កំពង់ចាម ក្រចេះ ព្រះវិហារ ព្រៃវែង ស្វាយរៀង និងតាកែវ ។

. ភាពមិនត្រឹមត្រូវក្នុងការប្រកាសលទ្ធផលនៃការរាប់សន្លឹកឆ្នោតមានចំនួន ១៤ករណី ដែលកើតមានជាពិសេសនៅខេត្តតាកែវ ភ្នំពេញ និងខេត្តកំពង់ធំ ។

. ការទទួលស្គាល់សន្លឹកឆ្នោតបានការ និងការបដិសេធលើសន្លឹកឆ្នោតមិនបានការ ដោយមិនអនុញ្ញាតឱ្យអ្នកសង្កេតការណ៍ និងភ្នាក់ងារគណ-បក្សនយោបាយបានធ្វើការត្រួតពិនិត្យមាន ៥ករណី ដែលកើតមាននៅខេត្តកំពង់ឆ្នាំង និងក្រុងភ្នំពេញ ។

. បញ្ហាខ្វះខាតសម្ភារៈសំខាន់ៗ ធ្វើឱ្យរាំងស្ទះដល់ដំណើរការរាប់សន្លឹកឆ្នោតមានចំនួន ៣ករណី ដែលមាននៅខេត្តបន្ទាយមានជ័យ និងក្រុងភ្នំពេញ ។

**១.៣.៣ ការផ្ទៀងផ្ទាត់និងបូកសរុបលទ្ធផ លបោះឆ្នោតនៅ គឃ/សប និង គខ/កប**

ការសង្កេតខ្លះៗ រកឃើញក្នុងកំឡុងការបូកសរុបលទ្ធផលបោះឆ្នោត នៅគណៈកម្មាឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ/សប) មានភ្នាក់ងារសង្កេតការណ៍គណបក្សប្រជាជនកម្ពុជាគ្រប់កន្លែង និងភ្នាក់ងារសង្កេតការណ៍របស់គណបក្សសម រង្ស៊ី ខ្លះ ក្រៅពីនោះមានអ្នកសង្កេតការណ៍ និងភ្នាក់ងារសង្កេតការណ៍ណាផ្សេងទៀត បានចូលរួមត្រួតពិនិត្យដំណើរការនោះទេ ។ អ្នកសង្កេតការណ៍ ខុមហ្វ្រែល រកឃើញការផ្ទៀងផ្ទាត់ និង បូកសរុបលទ្ធផលបោះឆ្នោត ដែលស្ទើរគ្រប់គណៈកម្មការខេត្ត-ក្រុង រៀបចំការបោះឆ្នោត (គខ/ កប) មិនយកចិត្តទុកដាក់ផ្ទៀងផ្ទាត់លទ្ធ-ផលបូកសរុបសន្លឹកឆ្នោត គឃ/សប ជាមួយកំណត់ហេតុ លទ្ធផលបោះឆ្នោតរបស់គណៈកម្ម-ការការិយាល័យបោះឆ្នោត (គករ) នោះទេ ។

**១.៣.៤ ភាពមិនប្រក្រតីក្នុងការរៀបចំ និងការវេចខ្ចប់សម្ភារៈ**

. ការមិនបង្ហាញកំណត់ហេតុបោះឆ្នោត និងរាប់សន្លឹកឆ្នោតចំពោះអ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយមានចំនួន ៨ករណី ។

. ការមិនមិនអនុញ្ញាតឱ្យអ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយសង្កេតការណ៍មើលរាល់ដំណើរការនៃការរៀបចំ និងវេចខ្ចប់សម្ភារៈឯកសារបោះឆ្នោត សម្រាប់បញ្ជូនពីការិយា-ល័យរាប់សន្លឹកឆ្នោតទៅ គឃ/សប មានចំនួន ៩ករណី នៅខេត្តបន្ទាយមានជ័យ ភ្នំពេញ កំពង់ធំ និងខេត្តតាកែវ ។

. ការមិនផ្តល់ព័ត៌មានដល់អ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយ អំពីផ្ទះ ឬទីតាំងសុវត្ថិភាពដែលរក្សាទុកលទ្ធផលបោះឆ្នោតនៅ គករ មានចំនួន ៩ករណី ។

**២. បណ្តឹងថ្ងៃបោះឆ្នោត រាប់សន្លឹកឆ្នោត**

យោងតាមរបាយការណ៍របស់ គ.ជ.ប ទាក់ទិននឹងការទទួល និងការដោះស្រាយបណ្តឹងនេះ គឃ/សប គខ/កប និង គ.ជ.ប ក្នុងដំណាក់កាលបោះឆ្នោត គិតត្រឹមថ្ងៃទី ០៤ ខែសីហា ឆ្នាំ ២០០៨ មានបណ្តឹងចំនួន ១៤៣ករណី នៅការិយាល័យ សប បណ្តឹង ៨៤ករណីនៅ គខ/ កប និងបណ្តឹងចំនួន ២៤ករណីទៀតនៅ គ.ជ.ប ។

**២.១ ដំណើរការបណ្តឹងនៅ គឃ/សប**

បើទោះបីមានករណីខ្លះថា មន្ត្រីការិយាល័យមិនចង់ផ្តល់ទម្រង់បណ្តឹង និងភ្នាក់ងារគណបក្សមានការភ័យខ្លាច នៅពេលមានការប្តឹងផ្តល់ យ៉ាងណាក៏ដោយបណ្តឹងទាំងអស់ដែលបានដាក់ទៅ គឃ/សប ពីសំណាក់គណបក្សនយោបាយដែលផ្តោតលើបញ្ហាស្តីពីការចេញ និងដកហូតយកទម្រង់ ១០១៨ ពីសំណាក់អាជ្ញាធរភូមិ/ឃុំ វត្តមានមេភូមិ មេឃុំ នៅមុខការិយាល័យបោះឆ្នោត និងការបដិសេធលើលទ្ធផលបោះឆ្នោតនៅការិយាល័យបោះឆ្នោត ក្នុងនោះមានបណ្តឹងចំនួន៦០ ស្មើនឹង ៤២% នៃចំនួនបណ្តឹងសរុបខាងលើ ត្រូវបានចារបដិសេធដោយយោងលើមូលហេតុ បណ្តឹងគ្មានមូលដ្ឋានច្បាប់ច្បាស់លាស់ ។ ក្នុងចំណោមបណ្តឹងទាំងនោះ គណបក្ស សម រង្ស៊ី មានបណ្តឹងច្រើនជាងគេ រហូតដល់ ១១២ករណី ប៉ុន្តែបណ្តឹងរបស់គណបក្ស សម រង្ស៊ី ចំនួន ៥៤ ករណី ស្មើនឹងប្រមាណជាង ៤៨% ត្រូវបានចារបដិសេធរួមទាំងការផ្សះផ្សាសះជាចំនួន ៣៩ករណី ប្រជុំសម្រេចបដិសេធបណ្តឹងចំនួន ៨ករណី ដកពាក្យបណ្តឹងដោយសាមីខ្លួន ៤ករណី និងផ្សះផ្សាមិនសះជាចំនួន ៧ករណី ។ មិនមានបណ្តឹងរបស់គណបក្សប្រជាជនកម្ពុជាដែលត្រូវបានគណៈកម្មការឃុំ/សង្កាត់ រៀបចំការបោះឆ្នោតចារបដិសេធឡើយ (ទាំង១២ករណី) ហើយត្រូវបានលើកយកមកដោះស្រាយចំនួន ៧ករណី រួមមានការផ្សះផ្សាសះជាចំនួន ១ករណី ប្រជុំសម្រេចបដិសេធលើបណ្តឹងចំនួន ១ ករណី និងការផ្សះផ្សាមិនសះជាចំនួន ៣ករណី ។ បណ្តឹងរបស់គណបក្សនរោត្តម រណឫទ្ធិ មានចំនួន ១០ករណី ដែលមានការចរចារបដិសេធចំនួន ២ករណី ការដោះស្រាយចំនួន ២ករណី រួមមានការផ្សះផ្សាសះជា ១ករណី និងការផ្សះផ្សាមិនសះជាចំនួន ៤ករណី ។ បណ្តឹងរបស់គណបក្ស ហ៊្វុនស៊ិនប៉ិច មានចំនួន ២ករណី ដែលបានលើកយកមកដោះស្រាយចំនួន ១ករណី និងផ្សះផ្សាសះជាចំនួន១ករណី។ គណបក្សសិទ្ធិមនុស្ស មានបណ្តឹងចំនួន ៣ករណី ដែលត្រូវបានចារបដិសេធចំនួន ២ករណី និងលើកយកមកដោះស្រាយចំនួន ១ករណី ។

យោងតាមចំនុច ៨.១៧.២ នៃបទបញ្ជា និងនិតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទី៤ ការប្រើប្រាស់អំណាចបដិសេធដោយស្របច្បាប់មិនទទួលយកពាក្យបណ្តឹងយក មកដោះស្រាយ ដោយ គឃ/សប អាចធ្វើទៅបានតែក្នុងករណីហួសរយៈពេលនៃការទទួលពាក្យបណ្តឹងតែប៉ុណ្ណោះ (ហួសអាជ្ញាយុកាលនៃបណ្តឹងត្រឹមម៉ោង១១:៣០នាទី នាថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០០៨) ។ ហេតុដូច្នេះ គឃ/សប មិនមានអំណាចណាមួយក្នុងការចារបដិសេធពាក្យបណ្តឹង ឬមិនទទួលយកពាក្យបណ្តឹងមកដោះស្រាយនៅក្នុងដំណាក់កាលបោះឆ្នោត និង

(តនៅទំព័រទី១០)

ភោជនីយដ្ឋាន ណាម វ៉ាង (ភ្នំពេញ)
Nam Vang Restaurant
571 Unit # 1 Adams Avenue. Philadelphia, Pa 19120
(inside Hong Kong Market)
(215) 742-9488
Open 7 days a week from 9 a.m. – 9 p.m.
បើក 7 ថ្ងៃក្នុងមួយអាទិត្យពីម៉ោង 9 ព្រឹក ដល់ 9 ល្ងាច

១_មុខជំនាញខាងម្ហូបខ្មែរយ៉ាងចំណាន ដូចជា:
- គុយទាវភ្នំពេញ
- គុយទាវ ឬមី-ខគោ
- មីកន្ទាំង ឆារសាច់គោ
- មីកន្ទាំងឆារគ្រឿងសមុទ្រ
- បាយឆារគ្រប់មុខ
- សាច់គោអាំង ចង្កាក់ ជាមួយជ្រក់ល្ហុង

២_មុខជំនាញម្ហូបវៀតណាមឈ្ងុយឆ្ងាញ់ ដូចជា:
- នំបញ្ចុកទឹកត្រីពិសេស
- នំប៉ុងបាតេ ឬសាច់គោអាំង
- ខគោ នំប៉ុង ឬមី និងគុយទាវ
- បាយសរសាច់ជ្រូកអាំង ឬសាច់មាន់អាំង



រៀងរាល់ថ្ងៃលោកអ្នកអាចពិសាទឹកក្រឡុកគ្រប់រស់ជាតិផ្លែឈើ ដូចជា : ទុរេន ឬ អាវូកាដូ ហើយជាពិសេស មានទឹកអំពៅកិនស្រស់ៗ




# ៧ថ្ងៃឱ្យស្បែកភ្លឺរលោងជំរះជាតិពុល

ការលាងជំរះជាតិពុលក្នុងថ្ងៃ ដំបូងនឹងចាប់ផ្តើមឡើងក្នុងការអត់អាហារប្រចាំពេលទទួលទានតែទឹកផ្លែឈើ និងផ្លែឈើតែប៉ុណ្ណោះ ។ បន្ទាប់ពីនោះថ្ងៃដែលនៅសេសសល់ និងសង្កត់ធ្ងន់ទៅលើការទទួលទានបន្លែផ្លែឈើស្រស់ៗ ធញ្ញជាតិ ស៊ុត ត្រី និងប្រេងដែលមានគុណភាព ដូចជាប្រេងម្កាក់ ។ ក្នុងអំឡុងពេលដែលអ្នកលាងជាតិពុលនេះ សូមឱ្យអ្នកផ្អាកកាហ្វេ និងគ្រឿងញៀនជាដាច់ខាត ។ ក៏ប៉ុន្តែបន្ទាប់ពីថ្ងៃទីដំបូង អ្នកអាចទទួលទានទឹកតែខ្ទឹះដាក់ក្រូចឆ្មារនំប៉័ងលាបប៊ឺរ ដំឡូងបារាំងបំពង បបរអង្ករសំរូបបានបន្តិចបន្តួច ។ ក្រៅពីនេះនៅក្នុងចន្លោះ២-៣ថ្ងៃដំបូង អ្នកនឹងមានឧស្ម័ននៅក្នុងក្រពះអាហារ ឬក៏រោគ ។ ក៏ប៉ុន្តែនៅពេលលាងជាតិពុលរួចហើយ ប្រព័ន្ធរំលាយអាហារនឹងធម្មតាថែមទាំងស្បែកស្អាតភ្លឺរលោង និងបានស្រកទម្ងន់ទៀតផង ។



### អាហារថ្ងៃទី១ :

**ពេលព្រឹក** : ទឹកក្រឡុកទំពាំងបាយជូរលាយជាមួយទឹកផ្លែប៉ោមក្រឡុក កន្លះកែវ ទឹកឃ្មុំមួយស្លាបព្រាបាយ និងទំពាំងបាយជូរជាមួយផ្លែប៉ោមស្រស់ ។

**ពេលថ្ងៃ** : ទឹកទំពាំងបាយជូរលាយជាមួយទឹកក្រូចឆ្មារជាមួយ និងទំពាំងបាយជូរស្រស់ ។

**ពេលថ្ងៃត្រង់** : ទឹកបន្លែជាមួយ និងទឹកក្រូចឆ្មារក្រឡុកផ្លែឈើក្រៀម ដោយត្រាំទឹកទុកចោលមួយយប់ ។

**ពេលរសៀល** : ទឹកផ្លែប៉ោម

**ពេលល្ងាច** : បន្លែជាមួយនិងរូបមន្ត បន្លែពិសេសធ្វើដោយខ្លួនឯងដោយ ប្រើប្រេងម្កាក់ ទឹកក្រូចឆ្មារ អំបិល ខ្ទឹម និងរុក្ខជាតិថ្នាំបុរាណដទៃៗទៀត ។

### អាហារថ្ងៃទី២ :

ដូចជាថ្ងៃទី១ ក៏ប៉ុន្តែពេលល្ងាច ប្តូរទៅជាបន្លែសេឡឺរី បន្លែស្ពៃរំលំណាត់ ដំឡូងបារាំង ចំហុយសណ្តែក ដោយមិនដាក់ស្ករ ។

### អាហារថ្ងៃទី៣ :

**ពេលព្រឹក** : ស្រូវអូត២ស្លាបព្រាបាយត្រាំទឹកទុកចោល១យប់ បន្ទាប់មកថែមប្រេងដូងមួយស្លាបព្រាបាយទឹកសណ្តែកលឿងមួយស្លាបព្រា និងហាន់ចេកអំបូងតូចមួយលាយជាចុងក្រោយ ។

**ពេលថ្ងៃ** : ទឹកបន្លែស្រស់ក្រឡុក

**ពេលថ្ងៃត្រង់** : បន្លែស្ពៃក្តោប សាប់មើមការ៉ុត ម្ទេសដៃនាង មើមខ្ទឹមបារាំង ប្រើទឹកសាលាដ រូបមន្ត ពិសេសរោយដោយបន្លែជីរបារាំង និងល្ង ទទួលទានត្រីធូណា ម៉ាក់ខឺរ៉ែល ឬក៏សារឌីនកំប៉ុងតាមក្រោយដោយ ផ្លែឈើដូចជាទំពាំងបាយជូរ ស្ត្របឺរី និងផ្លែប៉ោម ។

**ពេលរសៀល** : សេឡឺរី ការ៉ុត ស្ពៃ ក្តោប ខ្ទឹមបារាំងនាំយកទៅស្ងោរជាមួយ និងអង្ករសំរូបបន្ថែមរសជាតិដោយម្រេចខ្មៅនឹងរោយដោយជីរបារាំង ។

### អាហារថ្ងៃទី៤ :

**ពេលព្រឹក** : ទំពាំងបាយជូរ ផ្លែ ប៉ោម ស៊ុតស្ងោរ ឬក៏ស៊ុតថែមប៊ឺរបន្តិចបន្តួច ។

**ពេលថ្ងៃ** : ទឹកការ៉ុត សេឡឺរីន និងផ្លែប៉ោមក្រឡុករួមគ្នា ឬក៏ទឹកប៉េងប៉ោះក្រឡុកដាក់ទឹកក្រូចឆ្មារ ។

**ពេលថ្ងៃត្រង់** : ស៊ុបដោយមានសាច់ថ្ងៃទី៣ ជាមួយនិងនំប៉័ងហូលវ៉ិត និងបន្លែបន្តិចបន្តួច ។

**ពេលល្ងាច** : ត្រីអាំង ឬក៏មាន់អាំងទទួលទានជាមួយបន្លែស្ពៃក្តោបពីប្រ៊ុកគូលី ថែមប៊ឺរ សណ្តែក និងទឹកក្រូចឆ្មារ ព្រមទាំងលាងមាត់តាមក្រោយដោយផ្លែឈើ ឬទឹកដោះគោជូរ ។

### អាហារថ្ងៃទី៥ :

**ពេលព្រឹក** : ដូចថ្ងៃទី៣

**ពេលថ្ងៃ** : ទឹកបន្លែក្រឡុក

**ពេលថ្ងៃត្រង់** : អាហារដែលមានបន្លែស្រស់ រោយមុខ

**ពេលរសៀល** : ទឹកផ្លែឈើ ឬក៏ទឹកបន្លែ ក្រឡុក ឬក៏ទឹកតែ

**ពេលល្ងាច** : បន្លែស្រស់ដាក់ល្ងលីងគ្រាប់ឈូករ័ត្ន មាន់ចំហុយទឹកឃ្មុំ អាល់ម៉ន ទឹកដោះគោជូររសជាតិធម្មជាតិកូរឱ្យចូលគ្នា ។

### អាហារថ្ងៃទី៦ :

**ពេលព្រឹក** : ផ្លែឈើដូចជាប៉ោម ក្រូច ទំពាំងបាយជូរ ស្ត្របឺរីលាយជាមួយទឹកដោះគោជូរ និងទឹកឃ្មុំ

**ពេលថ្ងៃ** : ទឹកបន្លែក្រឡុក

**ពេលថ្ងៃត្រង់** : ដំឡូងបារាំងចំហុយ ស៊ុតចៀន បន្លែស្រស់ និងផ្លែឈើ

**ពេលល្ងាច** : បាយអង្ករសំរូបទទួលទានជាមួយសម្លប្រហើរផ្សិតចំប៉ើង សារាយបុកទឹកគ្រឿងផ្ទាប់ជាមួយបន្លែស្រស់ និងទទួលក្នុងក្រោយចុងក្រោយដោយផ្លែឈើស្រស់ ។

### អាហារថ្ងៃទី៧ :

**ពេលព្រឹក** : បបរអង្ករសំរូប១កូនចាន ទទួលទានជាមួយនិងទឹកធម្មតា ។

**ពេលថ្ងៃ** : ទឹកក្រូចឆ្មារដាក់ទឹកឃ្មុំ

**ពេលថ្ងៃត្រង់** : បន្លែ និងផ្លែឈើ

**ពេលរសៀល** : បន្លែស្រស់

**ពេលល្ងាច** : បាយអង្ករសំរូបមួយកូនចានជាមួយនិងមាន់អាំងស្ងោរស្ងឹកបាស់ ឆាបន្លែត្រកួន និងផ្លែឈើស្រស់ ៕

## (តមកពីទំព័រទី០១) ហ៊ុន សែន ព្រមានយកអាសនៈ...

ព្រះមហាក្សត្រនរោត្តម សីហមុនី ឯព្រលានយន្តហោះអន្តរជាតិភ្នំពេញ កាលពីដើមខែ សីហា កន្លងមកនេះ ឥស្សរជននយោបាយជាច្រើនកំពុងតែជួបជុំគ្នា ។

មេដឹកនាំនយោបាយទាំងពីរ គឺ ហ៊ុន សែន និង សម រង្ស៊ី ក៏បានសន្ទនាគ្នាពីរឿងក្រុមហ៊ុនអាកាសចរណ៍ ហើយ ហ៊ុន សែន ក៏បានសំដែងពីអារម្មណ៍មិនសប្បាយចិត្តក្នុងយុទ្ធនាការឃោសនាបោះឆ្នោត ដែលលោក សម រង្ស៊ី បានធ្វើការវាយប្រហារទៅលើថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជាកន្លងមក ។

ជាការព្រមានលាយឡំនឹងកំហឹងផងនោះ ហ៊ុន សែន បានសង្កត់ធ្ងន់ៗថា បើគណបក្ស សម រង្ស៊ី ធ្វើពហិកាមិនព្រមចូលរួមប្រជុំសភាទេ អាសនៈ នេះយើងនឹងយកទៅបែងចែកឱ្យគណបក្សផ្សេងហើយ ។

ការព្រមាននេះ ធ្វើឡើងបន្ទាប់ពីព្រះទីនាំងរបស់សម្តេចឪ សម្តេចម៉ែ និងព្រះមហាក្សត្រនរោត្តម សីហមុនី ចេញដំណើរផុតពីដីសំដៅទៅក្រុងប៉េកាំងប្រទេសចិន ដើម្បីចូលរួមក្នុងពិធីប្រកួតកីឡាអូឡាំពិកពិភពលោក ។

សំដីព្រមានលាយឡំនឹងកំហឹងបានធ្វើឱ្យឥស្សរជននយោបាយគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សផ្សេងៗចាប់អារម្មណ៍យ៉ាងខ្លាំង ខណៈពេលដែលលោក សម រង្ស៊ី ចងសម្ព័ន្ធភាពច្រានចោលលទ្ធផលបោះឆ្នោតជាសាកលនៅថ្ងៃទី២៧ ខែកក្កដា កន្លងមក ។

ហ៊ុន សែន បានរំលឹកថា កាលពីឃោសនាកន្លងមក អ្នកឯងជេរយើងសុទ្ធតែអាចោរលក់ជាតិ ហើយអាកណ្តាលខូចជាងគេ គឺជេរនៅមុខផ្ទះរបស់ខ្ញុំទៅទៀត ជេរឱ្យជូរចេញទៅផ្ទះវានៅជិតនៅទេ ។ អ្នកដែលជេរខ្ញុំកាលពីឆ្នាំ២០០៣ ពេលនេះ រលាយអស់ហើយ ។

លោក សម រង្ស៊ី ហាក់ដូចជាមិនកោតញញើតនោះបានតបសំដីថា ខ្ញុំជេរតែកើនសំឡេងឡើងពី២៤អាសនៈមក២៦អាសនៈ ។

ដោយខឹងនឹងលោក សម រង្ស៊ី មិនទាន់បាត់ផងនោះ ហ៊ុន សែន បានសង្កត់ទៅវិញថា ឡើងប៉ុណ្ណឹងល្អហើយ ហើយត្រូវទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត និងកុំយកមាត្រា៧៦ នៃរដ្ឋធម្មនុញ្ញមកប្រើ ខ្ញុំមិនចាប់អារម្មណ៍ទេ ។ ចង់លោកឯងទទួលស្គាល់ ឬមិនទទួលស្គាល់ខ្ញុំមិនដឹងទេ តែប្រជុំនៅថ្ងៃទី២៤ ខែកញ្ញា ត្រូវតែចូលរួម បើមិនចូលរួមប្រជុំទេ យើងនឹងយកអាសនៈនេះទៅបែងចែកឱ្យគណបក្សផ្សេងៗ ។

លោក សម រង្ស៊ី ក្នុងទឹកមុខញញឹម បានឆ្លើយយ៉ាងលឿនតបទៅវិញថា គណបក្ស សម រង្ស៊ី មានសំលេងគាំទ្រជាង២លាននាក់ឯណោះ ។

ហ៊ុន សែន បញ្ជាក់ថា សំលេងជាង២លាននាក់មែនតែអ្នកឯងអត់ចូលរួមប្រជុំសភា ហើយយកបញ្ហានេះមករារាំងសភានឹងអស់សុពលភាព ហើយ ខ្ញុំនិយាយហើយចាំមើលចុះ ។

ទាក់ទិននឹងការព្រមានរបស់ ហ៊ុន សែន ចំពោះលោក សម រង្ស៊ី ក្នុងឱកាសជួបគ្នាដោយកំរកនោះ ត្រូវបានលោក សម រង្ស៊ី បញ្ជាក់ថា ពេលនេះយើងមិនទាន់គិតដល់ការប្រជុំសភានោះទេ គឺគណបក្សកំពុងរវល់ដោះស្រាយរឿងមិនប្រក្រតី ដែលកើតមានស្ទើរគ្រប់ខេត្ត-ក្រុង ឱ្យអស់លទ្ធភាពសិន ។

លោក សម រង្ស៊ី បន្តថា ប្រជាពលរដ្ឋភាគច្រើនមានអារម្មណ៍សោកស្តាយ និងឈឺចាប់ចំពោះការរំលោភបំពានបំបិទសិទ្ធិសេរីភាពរបស់ពួកគាត់មិនបានបញ្ចេញមតិសំរេចជោគវាសនាខ្លួន ហើយយើងកំពុងទាមទារឱ្យមានការបោះឆ្នោតជាសកលឡើងវិញ ឬយ៉ាងហោចណាស់ក៏ត្រូវមានការបោះឆ្នោតបន្ថែមដែរ ដែលមានគណបក្សសិទ្ធិមនុស្ស និងគណបក្សនរោត្តម រណឫទ្ធិ ។

បើតាមរដ្ឋធម្មនុញ្ញត្រង់មាត្រាទី៧៦ បានកំណត់ថា រដ្ឋសភាត្រូវមានសមាជិកយ៉ាងតិច ១២០រូប ក្នុងចំណោម១២៣រូប ទើបសភាអាចប្រកាសពីសុពលភាពថ្មីជាសាធារណៈបាន ។ បើសិនជាសម្ព័ន្ធភាពគណបក្សប្រឆាំងមិនចូលរួមប្រជុំនោះ សភានឹងជួបបញ្ហាក្នុងដំណើរការដឹកនាំប្រទេសជាតិ ។

ការប្រកាសលទ្ធផលបណ្តោះអាសន្នរបស់ គ.ជ.ប នឹងប្រកាសនៅថ្ងៃទី០៩ សីហា ចំណែកលទ្ធផលផ្លូវការ នៅថ្ងៃទី១៣ ខែសីហា ហើយសភានឹងត្រូវប្រជុំនៅថ្ងៃទី២៤ សីហា ខាងមុខ ។

លោកស្រី មូរ សុខហួរ ក៏ដូចជាក្រុមអ្នកច្បាប់ បានលើកឡើងប្រហាក់ប្រហែលគ្នាថា យើងមិនទាន់មានរដ្ឋធម្មនុញ្ញត្រង់មាត្រាណាមួយចែងថា អាសនៈដែលប្រជាពលរដ្ឋបោះឆ្នោតឱ្យហើយត្រូវបានគណបក្សដទៃយកទៅចែកគ្នាបាននោះទេ ។ អ្វីដែលយើងកំពុងតែគិត គឺការដោះស្រាយភាពមិនប្រក្រតីឱ្យស្រេចជាមុនសិន ទើបយើងគិតដល់បញ្ហាចូលប្រជុំបង្កើតសភា ។

កាលពីថ្ងៃទី៨ ខែសីហា កន្លងមកនេះ នៅទីស្នាក់ការគណបក្ស សម រង្ស៊ី មានធ្វើសន្និសីទកាសែតស្តីពីការបោះឆ្នោតមានភាពមិនប្រក្រតី ក្លែងបន្លំ និងបំបិទសិទ្ធិអ្នកបោះឆ្នោតរាប់សិបម៉ឺននាក់ ។

គណបក្ស សម រង្ស៊ី, គណបក្សសិទ្ធិមនុស្ស, និងគណបក្ស នរោត្តម រណឫទ្ធិ បានច្រានចោលលទ្ធផលបោះឆ្នោត ហើយសុំឱ្យបោះឆ្នោតឡើងវិញ ។ ជាពិសេសនោះ គណបក្សទាំងបីនឹងមិនចូលរួមប្រជុំសភានៅថ្ងៃដំបូងទេ ល្គឹកណាការទាមទាររបស់ពួកគេមិនត្រូវបានដោះស្រាយនោះ ។ លោក ឡៅ ម៉ុងហៃ អ្នកស្រាវជ្រាវជាន់ខ្ពស់សិទ្ធិមនុស្សអាស៊ី ដែលមានស្នាក់ការនៅទីក្រុងហុងកុងបានមានប្រសាសន៍ថា ការគំរាមកំហែងរបស់ ហ៊ុន សែន ថានឹងយកអាសនៈពី សម រង្ស៊ី នោះ គឺមិនអាចធ្វើទៅកើតនោះទេ ពីព្រោះគ្មានមាត្រាណានៃរដ្ឋធម្មនុញ្ញចែងឡើយ បើកាលណាប្រជាពលរដ្ឋបោះឆ្នោតឱ្យហើយ គឺត្រូវតែទទួលបាន ។

លោក ឡៅ ម៉ុងហៃ បន្តថា ការចូលប្រជុំគ្រាន់តែបង្ហាញសុពលភាពរបស់សមាជិកតែប៉ុណ្ណោះ ហើយការបោះឆ្នោតនោះវាត្រឹមត្រូវដែរ ឬទេ ? ការដោះស្រាយបណ្តឹងវារួចរាល់ហើយឬនៅ ? បើសិនជាការដោះស្រាយចប់ហើយសភានោះនឹងមានសុពលភាព ។ ប្រសិនបើ ហ៊ុន សែន យកអាសនៈរបស់គណបក្សប្រឆាំងទៅចែកគ្នាមែននោះ នឹងនាំឱ្យគាត់ខាតបង់នូវនិត្យានុកូលភាពអាសនៈសភាជាតិមួយក៏រិតថែមទៀតទៅវិញ ៕

# WOAR

## អង្គការស្ត្រី ប្រឆាំងនឹងការចាប់រំលោភ

1233 Locust Street
Suite 202
Philadelphia, PA 19107
(215) 985-3315
Fax: (215) 985-9111
Email: info@WOAR.org
មានទូរស័ព្ទជួយលោកអ្នក២៤ម៉ោង
(215) 985-3333
Web site: www.WOAR.org



### ការធ្វើបាបដែលធ្វើដោយអ្នកនៅជាមួយគ្នា

ការធ្វើបាបដោយអ្នករស់នៅជាមួយគ្នា គឺនៅពេលអ្នកណាម្នាក់ដែលរស់នៅផ្ទះជាមួយអ្នក ដូចជាប្តីប្រពន្ធ អ្នកស្រឡាញ់គ្នា ឬសមាជិកគ្រួសារ រួមទាំងសាច់ថ្លៃ ដែលប្រើអំណាចគ្រួតត្រាដើម្បីឲ្យនៅមានអំណាចលើអ្នក។

ការធ្វើបាប គឺជាលំនាំឥរិយារបស់មនុស្សម្នាក់ដើម្បីឲ្យមានអំណាចលើអ្នកដទៃទៀត។ វាអាចរាប់បញ្ចូលទាំងការធ្វើបាបខាងផ្លូវចិត្ត ខាងខួរក្បាល ខាងសេដ្ឋកិច្ច ខាងសេពមេថុន និងខាងរាងកាយ។ វាជាការសំខាន់ដែលត្រូវដឹងថាការធ្វើបាបដោយអ្នករស់នៅជាមួយគ្នាអាចចាប់ផ្តើមឡើងដោយ អំពើធ្វើឲ្យអាម៉ាស់មុខ ដោយការគំរាមគំហែង ទះ និង រុញ ប៉ុន្តែក្រោយមកអាចធ្វើឲ្យកាន់តែធ្ងន់ឡើង។

### មានហេតុការណ៍ថែមទៀតអំពីការធ្វើបាបដោយអ្នករស់នៅជាមួយគ្នា...

- ការធ្វើបាបដោយអ្នករស់នៅជាមួយគ្នាកើតមានឡើង ៥០ ទៅ៦០ភាគរយ តាមការរួមរះគ្នា។
- ការធ្វើបាបដោយអ្នករស់នៅជាមួយគ្នាគឺជាហេតុដែលនាំឲ្យស្ត្រីមានរបួសច្រើនជាងគេនៅសហរដ្ឋ។
- 25% ទៅ 45% នៃស្ត្រីដែលត្រូវគេវាយធ្វើបាបគឺបានវាយធ្វើបាបនៅពេលមានផ្ទៃពោះ- ជាទូទៅការវាយធ្វើបាបចាប់ផ្តើមនៅពេលស្ត្រីចាប់ផ្តើមមានផ្ទៃពោះ។
- មានចំនួន៧៥%នៃឧប្បត្តិហេតុដែលបានរាយការណ៍ គូរស្រករបាននៅបែកគ្នារួចហើយ ពេលមានការវាយដំ។
- ជនរងគ្រោះពីការធ្វើបាបដោយអ្នករស់នៅជាមួយគ្នាអាចមានការវាយដំម្តងទៀតជាទ្វេ ប្រសិនបើប៉ូលីសមិនចាប់។

### រឿងរបស់អ្នកនៅរស់

ស្ត្រីខ្មែរម្នាក់បាននិយាយថា ...

" ប្តីរបស់ខ្ញុំស្រឡាញ់ក្រុមគ្រួសារខ្ញុំណាស់មុនពេលយើងរៀបការ។ ខ្ញុំរៀបការគាត់ព្រោះខ្ញុំគិតថា ខ្ញុំអាចពឹងពាក់លើគាត់បាន។ នៅពេលនោះ ខ្ញុំនិយាយភាសាអង់គ្លេសបានតិចៗ ហើយខ្ញុំគិតថាគាត់អាចជួយខ្ញុំនិងក្រុមគ្រួសារជាមួយនឹងភាសា។ ខ្ញុំបានគិតថាគាត់ស្រឡាញ់ខ្ញុំ។ ប្រសិនបើខ្ញុំបានដឹងថាគាត់នឹងធ្វើបាបខ្ញុំ ខ្ញុំមិនបានរៀបការគាត់ទេ។ ខ្ញុំបានដឹងថាគាត់មិនមែនជាមនុស្សល្អណាស់ណាទេ។

ម្តាយខ្ញុំបានប្រាប់ខ្ញុំកុំឲ្យរៀបការគាត់ ប៉ុន្តែខ្ញុំចចេស។ ខ្ញុំបានសំរេចចិត្តខុសដោយរៀបការជាមួយគាត់។ ដូច្នេះខ្ញុំមានអារម្មណ៍ថា ខ្ញុំគួរទទួលការធ្វើបាប។ ខ្ញុំទទួលយកនូវការទទួលខុសត្រូវ។ គាត់បានវាយខ្ញុំបួនដងក្នុងពេលដែលយើងបានរៀបការ។ ខ្ញុំចេញឈាមពេលគាត់វាយខ្ញុំម្តងៗ។

ពេលគាត់វាយខ្ញុំម្តងៗ ខ្ញុំចង់ឲ្យអ្នកណាម្នាក់មកជួយខ្ញុំ ប៉ុន្តែខ្ញុំមិនដឹងថាត្រូវនិយាយជាមួយអ្នកណាឬទៅទីណាដើម្បីរកជំនួយ។ មានពេលមួយ ក្រោយពីប្តីខ្ញុំបានវាយខ្ញុំរួច ខ្ញុំបានសម្រេចចិត្តថាត្រូវលែងលះគាត់ ហើយបានប្រាប់គាត់ឲ្យចាកចេញពីផ្ទះខ្ញុំ។

ពាក្យណែនាំរបស់ខ្ញុំដល់អ្នកដែលមើលកាសែតកុននេះគឺកុំឲ្យធ្វើតាមជីវិតរងគ្រោះរបស់ខ្ញុំ។ ខ្ញុំមានអារម្មណ៍ថាបានសុខឥឡូវនេះ។ មិនជាសុខណាស់ណាទេ ប៉ុន្តែវាគ្រាន់បើជាងពីមុន។ "

### ការបង្ខំឲ្យរួមដំណេក

ការបង្ខំឲ្យរួមដំណេក គឺនៅពេលដែលអ្នកណាម្នាក់ប្រើកម្លាំងបន្ថែមបន្ថយ ប្រើល្បិច ឬដាក់ថ្នាំឲ្យអ្នកណាម្នាក់ដើម្បីឲ្យមានសម្រើបសេពមេថុនដោយគ្មានការយល់ព្រមពីអ្នកនោះ។ ការបង្ខំឲ្យរួមដំណេករាប់ទាំងការចាប់រំលោភ ការចាប់រំលោភក្មេងក្រោមអាយុ ប៉ះពាល់កន្លែងមានសម្រើបប និងអំពើឬនិយាយស្តីដែលទាក់ទងដល់ការសេពមេថុន។

### ការចាប់រំលោភ

ច្បាប់ចែងថាការចាប់រំលោភគឺនៅពេលអ្នកណាម្នាក់បង្ខំអ្នកឲ្យរួមដំណេកដោយគ្មានការយល់ព្រមពីអ្នក។ ទោះជាអ្នកធ្លាប់បានយល់ព្រមរួមដំណេកជាមួយអ្នកនោះពីមុនមកក៏ដោយ។ បើប្តីឬសង្សាររបស់អ្នកបង្ខំឲ្យអ្នករួមដំណេកដោយគ្មានការយល់ព្រមពីអ្នក គេហៅថាជាការចាប់រំលោភ ហើយវាជាការខុសច្បាប់។ នៅហ្វីឡាដែលហ្វ្យា អ្នកដែលត្រូវគេបង្ខំឲ្យរួមដំណេក 85% ដែលនៅរស់ ស្គាល់អ្នកដែលរំលោភពួកគេ។ ស្ថិតិបានបង្ហាញថាស្ត្រី ដែលត្រូវគេវាយដំចំនួន 85% គឺត្រូវបានរំលោភដោយដៃគូររបស់ពួកគេ។

### ការចាប់រំលោភក្មេងក្រោមអាយុ

ការចាប់រំលោភក្មេងក្រោមអាយុ គឺនៅពេលដែលក្មេងប្រុសឬស្រី ដែលមានអាយុរវាង១៣និង១៥ឆ្នាំរួមដំណេកជាមួយអ្នកណាម្នាក់ដែលមានអាយុ៤ឆ្នាំលើសពីក្មេងនោះឡើងទៅ។ ឧទាហរណ៍ ប្រសិនបើក្មេងស្រីអាយុ១៤ឆ្នាំដើរលេងជាមួយក្មេងប្រុសដែលមានអាយុ១៨ឆ្នាំ ហើយពួកគេរួមដំណេកជាមួយគ្នា ក្មេងប្រុសនោះអាចជាប់គុកទោះជាក្មេងស្រីបានយល់ព្រមក៏ដោយ។

### ការប៉ះពាល់កន្លែងមានសម្រើបនិង អំពើឬការនិយាយស្តីដែលប៉ះពាល់ដល់ការរួមដំណេក

អំពើឬការនិយាយស្តីដែលប៉ះពាល់ដល់ការរួមដំណេក គឺយោងទៅលើការប្រកាន់ប្រភេទនិងសេពមេថុននៅកន្លែងធ្វើការ។ ជាទូទៅមានន័យថា ការឈ្លានពានលើការសេពមេថុន ទាមទាសំណងដោយសុំរួមដំណេក និងការនិយាយស្តីឬធ្វើទៅលើរាងកាយដែលប៉ះពាល់ដល់ការសេពមេថុន ពេលដែល:

1. អ្នកដាក់ខ្លួនធ្វើអំពើនោះដើម្បីឲ្យនៅមានការងារធ្វើ។
2. ការធ្វើខ្លួនឬមិនធ្វើដែលមានឥទ្ធិពលលើការសម្រេចចិត្តអំពីរូបអ្នកលើការងារ។
3. ទង្វើដែលរំខានដល់ការងាររបស់អ្នកឬបង្កើតឲ្យមានការភ័យខ្លាច ជាសត្រូវ ឬអាក់អន់ចិត្ត នៅកន្លែងធ្វើការ។

### ប្រសិនបើដៃគូររបស់អ្នកធ្វើបាបអ្នក ដោយការបង្ខំឲ្យរួមដំណេកឬចាប់រំលោភ

- ប្រសិនបើអ្នកស្ថិតនៅក្នុងភាពគ្រោះថ្នាក់ សូមទូរសព្ទ័ទៅលេខ 911
- ទៅរកការព្យាបាលជាបន្ទាន់
- កុំងូតទឹក កុំញាំអាហារ ឬផ្លាស់សំលៀកបំពាក់
- ទូរស័ព្ទទៅ **WOAR Hotline 215-985-3333**
- ទៅរកការគាំទ្រផ្ទាល់ខ្លួនឬជាក្រុម
- ថែទាំខ្លួនរបស់អ្នក



កាសែតខ្មែរប៉ុស្ដិ៍ សូមធ្វើការអភ័យទោសដោយមិនបានចុះផ្សាយអត្ថបទ ស្ដីពីនារីប្រវត្តិសាស្ត្រ, នារីអរិយធម៌ខ្មែរ និងនារីព្រះពុទ្ធសាសនា នៅទំព័រទី ១៣ លេខ ២០ នេះ យើងខ្ញុំនឹងធ្វើការចុះបន្តនៅលេខទី ២១ សូមលោក លោកស្រីរង់ចាំអានដោយមេត្រីភាព ។

*សូមអរគុណ !*

# ខ្មែរចេះផលិតស្រាទំពាំងបាយជូរមានរសជាតិឆ្ងាញ់

**បាត់ដំបង ,ខ្មែរប៉ុស្តិ៍ : គឹម សារឿន**

•••សំរាប់ប្រជាកសិករខ្មែរដែលរស់នៅតាមតំបន់ចុងកាត់មាត់ញក មិនបានរៀនសូត្រជ្រៅជ្រះផងនោះ បែរជាចេះស្វែងយល់ពីតំរូវការចាំបាច់លើទីផ្សារ ហើយបានខិតខំស្រាវជ្រាវឯកសារផ្សេងៗ រហូតបែកគំនិតអាចដាំផ្លែទំពាំង


ផ្លែទំពាំងបាយជូរអើយយោង




អ្នកកាសែតខ្មែរប៉ុស្តិ៍ កំពុងធ្វើបទសម្ភាសន៍ជាមួយអ្នកផលិតស្រាទំពាំងបាយជូរ

បាយជូរបាន ។

បន្ទាប់ពីសិក្សាស៊ីជំរៅបច្ចេកទេសដាំផ្លែទំពាំងបាយជូរហើយ កសិកររូបនេះក៏ធ្វើការស្វែងយល់ពីរបៀបផលិតស្រាដូចបរទេស រហូតដល់ទទួលបានជោគជ័យ ហើយទទួលបានការគាំទ្រពីអតិថិជនកាន់តែច្រើននៅលើទីផ្សារ និងអូតសរសើរថា មានរស់ជាតិឆ្ងាញ់ជាប់មាត់មិនធ្វើឱ្យប៉ះពាល់ដល់សុខភាពឡើយ ។

*** ការស្វែងយល់ពីតំរូវការទីផ្សារ :**

ដោយសារតែដីតូចចង្អៀតដាំក្រូចបានផលតិច ហើយពិបាករកទីផ្សារសំរាប់លក់ផងនោះ កសិកររូបនោះក៏បានចាប់ផ្តើមដាំទំពាំងបាយជូរវិញម្តង នៅឆ្នាំ២០០១ លុះក្រោយមកក៏សាកល្បងផលិតចេញជាស្រាបាន៣ប្រភេទសំរាប់បំរើអតិថិជន ។ ចាប់តាំងពីដាំផ្លែទំពាំងបាយជូររហូតដល់សព្វថ្ងៃគ្រួសារគាត់ដាំបានជាង៨០០០គុម្ព ដែលក្នុង១គុម្ពទទួលបាន៣គីឡូក្រាមក្នុងមួយឆ្នាំ ហើយមួយគីឡូក្រាមលក់បាន៥ដុល្លារអាមេរិក ។

លោក ចាន់ ថៃឈឿង អាយុ៤២ឆ្នាំ រស់នៅភូមិបត់សាលា ឃុំឈើទាល ស្រុកបាណន់ ដែលជាអ្នកមានបច្ចេកទេសក្នុងការដាំផ្លែទំពាំងបាយជូរបានឱ្យដឹងថា មុនពេលដែលលោកធ្វើការសាក-ល្បងដាំផ្លែទំពាំងបាយជូរ គឺសិក្សារៀនសូត្រ តាមរយៈឯកសារ ហើយក្រោយមកក៏ឱ្យបងប្អូនរស់នៅក្រៅប្រទេសដែលមានចំណេះដឹងនេះជួយផ្ញើឯកសារ និងពន្យល់ពីបច្ចេកទេសលំអិត ។

លោក ចាន់ ថៃឈឿង បន្តថា បន្ទាប់ពីប្រមូលឯកសារទាក់ទិននឹងដំណាំទំពាំងបាយជូរនេះ ហើយគាត់ក៏ចាប់ផ្តើមធ្វើការដាំដុះ ហើយលេចចេញជាលទ្ធផលគួរជាទីពេញចិត្តជំរុញឱ្យក្រុមគ្រួសារគាត់កាន់តែមានកំលាំងចិត្តទ្វេរឡើងក្នុងរបរនេះ ។

កសិកររូបនេះបានបន្តថា កាលពីដាំលើកដំបូងមានតែ១០០០គុម្ពទេ ហើយសព្វថ្ងៃនេះ យើងដាំបាន៨០០០គុម្ព ហើយ ប៉ុន្តែយើងមិនទាន់ទាញយកផលប្រយោជន៍ទាំងអស់នោះទេ គឺក្នុងអំឡុងឆ្នាំ២០០៨នេះ ផលិតផលស្រាទំពាំងបាយជូរនឹងកើនទ្វេរដង ហើយ ។

លោក ចាន់ ថៃឈឿង ក៏បានឱ្យដឹងដែរថា ពេលនេះលោកបានផលិតស្រាទំពាំងបាយជូរ បាន៣ប្រភេទ គឺស្រាក្រហម ប្រេនឌី និងស្រា-ទំពាំងបាយជូរ ។ ស្រាទំពាំងបាយជូររបស់លោក ដែលផលិតចេញមកនេះ បើនិយាយពីគុណភាព គឺអ្នកស្រុកទទួលទាន ហើយអូតសរសើរថាឆ្ងាញ់គ្រប់ៗគ្នា ប៉ុន្តែបើប្រៀបធៀបជាមួយស្រាទំពាំងបាយជូរបរទេសនោះ គឺមានគុណ-ភាពខុសគ្នា ។

អ្នកផលិតស្រាទំពាំងបាយជូររូបនេះបានបញ្ជាក់ថា ផលិតផលរបស់លោកបាននាំយកទៅលក់នៅលើទីផ្សារ ក្រុងភ្នំពេញ សៀមរាប បាត់ដំបង និងបណ្តាខេត្តមួយចំនួនទៀតផងដែរ ។ អ្នកទទួលទានជាភ្ញៀវបរ-ទេសគេនិយមទទួលទាន និងអ្នកខ្លះទៀត ក៏មកពិនិត្យដល់កន្លែងដាំផ្លែទំពាំងបាយជូរ និងផលិតស្រាផ្ទាល់តែម្តង ។

លោក ចាន់ ថៃឈឿង ក៏បានបញ្ជាក់ផងដែរថា ទោះបីជាយើងនៅមានទីផ្សារតូច និងដើមទុនសំរាប់ផលិតយ៉ាងនេះក្តី ក៏ទៅថ្ងៃអនាគតយើងនឹងពង្រីកសង្វាក់ផលិតកម្មឱ្យធំជាងនេះ ។ ប៉ុន្តែអ្វីដែលយើងជួបការលំបាកនេះ គឺផលិតផលរបស់យើងនៅមានគុណភាពមិនទាន់មានលក្ខណ:ស្តង់ដា និងដើមទុនមានមិនទាន់គ្រប់គ្រាន់ដើម្បីបំរើតាមតំរូវការរបស់អតិថិជននៅឡើយ ។

ជាមួយគ្នានេះដែរ ទាក់ទិនទៅនឹងការផលិតស្រានេះ លោក ចាន់ ថៃឈឿង ថា ការលំបាករបស់គាត់ គឺសីតុណ្ហភាពឡើងខ្ពស់ទីផ្សារមានការប្រកួតប្រជែងផ្នែកធនធានការចែកចាយនៅលើទីផ្សារនៅមានកំរិតទាប ។

ចំណែកស្ត្រីជាប្រពន្ធឈ្មោះ ឡេង ចាន់ថុល បានឱ្យដឹងថា ផលិតផលរបស់គាត់មិនមានការ


ស្រាទំពាំងបាយជូ ដែលគេផលិតចេញជាដប

ផ្សព្វផ្សាយពាណិជ្ជកម្ម ឬសេវាកម្មចែកចាយនៅលើទីផ្សារនោះ គឺបានបងប្អូនជិតឆ្ងាយដឹងតៗគ្នាជួយគាំទ្រ និងលើកទឹកចិត្តជាបន្តបន្ទាប់ដែលធ្វើឱ្យពួកគាត់កាន់តែមានកំលាំងចិត្តទ្វេរថែមទៀត ។

អ្នកស្រី ឡេង ចាន់ថុល បន្តថា សព្វថ្ងៃគាត់បានធ្វើការទំនាក់ទំនងតាំងផលិតផលក្នុងពិធីធំៗដើម្បីឱ្យភ្ញៀវជាតិ-អន្តរជាតិបានឃើញស្គាល់ពីជាតិ ហើយទីផ្សារកាន់តែរីកចំរើន ពីព្រោះដំបូងពួកគាត់ទទួលទានសាកល្បង ហើយ ក្រោយមកក៏ទទួលទានជាប្រចាំដើម្បីថែទាំសុខភាព ។

អ្នកស្រី ឡេង ចាន់ថុល បានបញ្ជាក់ថា គាត់ចង់ពង្រីកទីផ្សារខ្លាំងណាស់ ប៉ុន្តែធ្វើទៅមិនរួច ដោយសារតែផលិតផលផ្លែទំពាំងបាយជូរនៅតិច ។ ម្យ៉ាងទៀតគាត់ក៏ចង់ពង្រីកការដាំដុះឱ្យធំ ប៉ុន្តែដីវាឡើងថ្លៃមិនបានពង្រីកចំការឱ្យបានឡើយ ។

ជាមួយគ្នានេះដែរ ក៏មានបងប្អូនស្រុកយើងនាំគ្នាដាំផ្លែទំពាំងបាយជូរនេះដែរ ហើយមានកុងត្រាគ្នា លុះបានផលគាត់ទទួលទិញទាំងអស់ និងលើកទឹកចិត្តដល់ពួកគាត់ ។

ប្តីប្រពន្ធទាំងពីរនាក់នេះ ក៏បាននិយាយទាំងមោទនភាពថា កាលពីជំនាន់មុន គឺមានតែស្រុកគេទេដែលចេះផលិតស្រាទំពាំងបាយជូរ ប៉ុន្តែ ពេលនេះខ្មែរក៏ធ្វើទំពាំងបាយជូរដែរ ហើយពួកគាត់ក៏សូមអំពាវនាវដល់បងប្អូនខ្មែរគ្រប់ទិសទីឱ្យជួយគាំទ្រផលិតផលរបស់គាត់ផង ។ ពួកគាត់សង្ឃឹមថា នៅពេលអនាគតគាត់នឹងផលស្រាទំពាំងបាយជូរឱ្យមានគុណភាពល្អ ហើយនាំយកទៅចែកចាយទាំងក្នុង និងក្រៅប្រទេស ៕

## (តមកពីទំព័រទី០១) នរណានឹងក្លាយជាប្រធានាធិបតី

បានចំនួន $៦២ លាន (៦២លានដុល្លារ) រីឯ-លោក ចន ម៉ាកេន វិញ រកបានតែ $២១លាន (២១លានដុល្លារ) តែប៉ុណ្ណោះ ។ ការប្រមូលប្រាក់បានច្រើននេះ ជាសញ្ញាសំខាន់មួយទៀតដែលអាចបញ្ជាក់ថា លោក បារ៉ាក់ មានប្រជាប្រិយ៍ភាពច្រើន ។

នៅមានលក្ខណ:សម្បត្តិមួយចំនួនទៀតដែលលោក ចន ម៉ាកេន មាន គឺលោកជាអតីតនាយទាហាន ហើយមានបទពិសោធន៍នៅសភាជាតិជាច្រើនឆ្នាំ ។

រីឯស្ថិតិស្ទង់ពីតំណាងអ្នកបោះឆ្នោតនៅជុំវិញសហរដ្ឋអាមេរិក គេសង្កេតឃើញអ្នកចូលចិត្តបោះឆ្នោតឱ្យ បារ៉ាក់ មាន **២២១នាក់** ទល់នឹង ម៉ាកេន បានតែ **១៨៩នាក់** ចំនួន ដែលត្រូវការ ដើម្បីឈ្នះ គឺ **២៧០នាក់ ។**

*សូមអញ្ជើញមកចូលរួម ទស្សនាខ្សែរភាពយន្តរបស់នាង សុជាតា*

*រឿង* **"ទារកនាកើត ក្នុងឱកាសចូលឆ្នាំថ្មី "** *ដែល នឹងបង្ហាញជូនជាមួយនិង កម្មវិធី:*

PEAK
Being Your Childs Best Advocate

បង្កើនថាមពល មាតាបិតា ដើម្បីណែនាំ តាមរយៈចំណេះដឹង សិក្ខាសាលាដោយឥត យកថ្លៃ ចំនួន ៨សប្តាហ៍ សំរាប់មាតាបិតា/អនាព្យាបាល ដែលចង់សិក្សា ពីវិធី ណែនាំកូនចៅ អោយបានប្រសើរបំផុត ដោយប្រើប្រព័ន្ធបំរើ កុមារ និង យុវជននៅហ្វីឡាដែលហ្វីញ

- អ្នកចូលរួម លោកអ្នក នឹងបានរៀនអំពីប្រធានបទ ដូចតទៅ:
- ប្រពន្ធ័ព្យាបាលសសៃបសាទ
- ប្រពន្ធ័របស់គ្រឿងញៀន និង សុរា
- ប្រពន្ធ័សិក្សាធិការ ពិសេស
- ប្រពន្ធ័តុលាការ កុមារ
- ប្រពន្ធ័កុមារភាព និង យុវជន

តើអ្នកត្រូវដឹងអ្វីខ្លះ សំរាប់ការណែនាំ អោយមានប្រសិទ្ធិភាព?

ផ្តើមនៅ : *ថ្ងៃព្រហស្បត៍ ទី០៤ ខែកញ្ញ ឆ្នាំ ២០០៨*
ទីកន្លែង : *នៅ នៅ មជ្ឈមណ្ឌល E-3 អាស័យដ្ឋានលេខ ៥២០១ ផ្លូវ* Old York Road *ហ្វីឡាដែលហ្វីញ* PA ១៩១៤១
ពេលវេលា : *ពីម៉ោង ៦ ដល់ ម៉ោង ៨ ល្ងាច*
តំលៃ: *សិក្ខាសាលា ដោយមិនយកកំរៃ និងមាន ជួយចេញថ្លៃអោយគេមើលកូន និងជួយចេញថ្លៃធ្វើដំណើរ ផង*

មានប្រាក់រង្វាន់ ៥០ដុល្លា សំរាប់ផ្តល់អោយសិស្ស ដែលមករៀនទៀងទាត់

MENTAL HEALTH ASSOCIATION OF SOUTHEASTERN PENNSYLVANIA
The Bell of Hope

សូមទាក់ទងទៅលោក ពិន សំខុន ហៅ Roger Pin និង MARY TILLERY ឬ MARY TILLE, Family Advocate តាមរយ: ទូរសព្ទ័លេខ ២៦៧-៧៥១-១៨០០ រួចចុចលេខ ២៤៦ រឺ ៥៥៨ រឺ ២៤៦

ឬអាចទាក់ទងទៅ មជ្ឈមណ្ឌល E-3 តាមរយ: ទូរសព្ទ័លេខ ២១៥-៣៣៩-០២៤០

# ជីវិតសច្ចុងក្រោយរបស់ទ្រង់ រណឫទ្ធិ ?

**ភ្នំពេញ ,ខ្មែរប៉ុស្តិ៍ : គីម សារឿន**

•••បន្ទាប់ពីសាលដីការបស់ក្រុមប្រឹក្សាជំនុំជម្រះ នៃតុលាការកំពូល សំរេចដំកលសាលដីការបស់សាលាឧទ្ធរណ៍ ករណីប្តឹងស្តីពីបទរំលោភទៅលើទំនុកចិត្តប្រឆាំងនឹងសម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ កាលពីថ្ងៃទី៣០ កក្កដា មក ។

សម្ព័ន្ធអង្គការ សមាគមក្រៅរដ្ឋាភិបាលចំនួន ២១ បានចេញសេចក្តីថ្លែងការណ៍សោកស្តាយយ៉ាងខ្លាំង ហើយគណបក្ស សម រង្ស៊ី និងគណបក្ស



សម្តេច ក្រុមព្រះនរោត្តម រណឫទ្ធិ



លោក ញ៉ឹក ប៊ុនឆៃ អគ្គលេខាធិការបក្ស



កែវ ពុទ្ធរស្មី ប្រធានគណបក្សហ្វ៊ុនស៊ិនប៉ិច

នរោត្តម រណឫទ្ធិ ក៏បានធ្វើលិខិតស្នើសុំការលើកលែងទោសពីព្រះមហាក្សត្រនរោត្តម សីហមុនី ដើម្បីឱ្យព្រះអង្គមានសិទ្ធិវិលត្រឡប់ក្នុងជីវភាពនយោបាយវិញ ។

គណៈកម្មាធិការប្រព្រឹត្តិកម្ម ដែលមានអង្គការសមាគមចំនួន ២១ នៅក្នុងប្រទេសកម្ពុជា បានបញ្ជាក់ថា ការសំរេចរបស់ក្រុមប្រឹក្សាជំនុំជម្រះរបស់តុលាការកំពូលទៅលើសម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ គឺមិនបានឈរលើមូលដ្ឋានឯករាជ្យ មិនអព្យាក្រឹត្យទេ ។

អង្គការសមាគមទាំងនោះបានបញ្ជាក់ថា ក្នុងអង្គសវនាការនោះ លោក សុក សំអឿន ជាមេធាវីការពារក្តីសម្តេចក្រុមព្រះ បានលើកពីមូលហេតុផ្លូវច្បាប់សំខាន់ៗជាច្រើន ដើម្បីឱ្យតុលាការកំពូលជ្រាប ។ ជាពិសេសដើមបណ្តឹងលោក កែវ ពុទ្ធរស្មី ប្រធានគណបក្សហ្វ៊ុនស៊ិនប៉ិច បានដកពាក្យបណ្តឹង ដោយយល់ឃើញថា នោះជារឿងភាន់ច្រឡំ កាលពីថ្ងៃទី២៩ កក្កដា ។

លោក កែវ ពុទ្ធរស្មី បានបញ្ជាក់ក្នុងលិខិតដកពាក្យបណ្តឹងរដ្ឋប្បវេណី និងព្រហ្មទណ្ឌថា សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ ពុំមានចេតនារំលោភបំពានយកដីកម្មសិទ្ធិរបស់គណបក្សហ្វ៊ុនស៊ិនប៉ិច ជាកម្មសិទ្ធិផ្ទាល់ខ្លួនទេ ។ ក្នុងលិខិតដដែលក៏បានទទួលស្គាល់ថា ដីនេះជាកម្មសិទ្ធិរបស់គណបក្សហ្វ៊ុនស៊ិនប៉ិច ជាកម្មសិទ្ធិនៃពាក្យបណ្តឹងអំពីបទរំលោភរលើទំនុកចិត្តប្រឆាំង និងសម្តេចក្រុមព្រះផងដែរ ។

លោក លីវ សុវណ្ណ មេធាវីការពារក្តីសម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ ដែរនោះ បានប្រាប់ក្រុមសារព័ត៌មានថា កាលពីថ្ងៃទី២៩ ខែកក្កដាកន្លងមក លោកបានទៅផ្ទះរបស់លោក កែវ ពុទ្ធរស្មី ដែលមានវត្តមានរបស់ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរីរ័ត្ន អនុប្រធានទី២ គណបក្ស និងលោក ញ៉ឹក ប៊ុនឆៃ អគ្គលេខាធិការបក្ស ហើយបានព្រមព្រៀងគ្នាធ្វើលិខិតដកពាក្យបណ្តឹងនេះ ។

លោកមេធាវី លីវ សុវណ្ណ បន្តថា ប្រធានគណបក្សហ្វ៊ុនស៊ិនប៉ិច លោក កែវ ពុទ្ធរស្មី បានចុះហត្ថលេខារួចហើយ ប៉ុន្តែនៅពេលនេះស្រាប់តែមេធាវីរបស់លោក ញ៉ឹក ប៊ុនឆៃ មកអះអាងរឿងផ្សេងៗទៅវិញ ។ ទង្វើនេះបង្ហាញឱ្យឃើញថា មេធាវីរបស់លោក ញ៉ឹក ប៊ុនឆៃ បានរំលោភលើក្រមសីលធម៌ដែលថាខ្លួនឈប់ប្តឹង ហើយបែរជាបន្តឱ្យជំរុញបណ្តឹងទៅវិញ ។

លោក មុត ចន្ថា អ្នកនាំពាក្យរបស់គណបក្សនរោត្តម រណឫទ្ធិ បានសំដែងអារម្មណ៍ក្រេវក្រោធរបស់ខ្លួនចំពោះតុលាការកំពូល ប្រាប់អ្នកសារព័ត៌មានថា ករណីសំនុំរឿងរបស់សម្តេចក្រុមព្រះនៅតុលាការនោះ ជារឿងនយោបាយសុទ្ធសាធ ដែលមាន ហ៊ុន សែន និង ញ៉ឹក ប៊ុនឆៃ ជាមេខ្លោងបញ្ជាតុលាការធ្វើបាបព្រះអង្គយ៉ាងអយុត្តិធម៌បំផុត ។

លោក មុត ចន្ថា បន្តថា សម្តេចក្រុមព្រះគ្មានកំហុសដូចការចោទប្រកាន់របស់តុលាការទេ ហើយតុលាការធ្វើការចោទប្រកាន់នេះ ពុំបានឈរលើមូលដ្ឋានអ្វីឡើយ ។ ករណីប្លង់កម្មសិទ្ធិនេះ ខាងគណបក្សលោកបានដាក់ជូនតុលាការក្រុងភ្នំពេញ និងជូនទៅគណបក្សហ្វ៊ុនស៊ិនប៉ិចដែរ តែគេមិនព្រមទទួល តើឱ្យលោកយកទៅបោះចោល ឬធ្វើយ៉ាងណា ?

ចំណែកលោក យូ ហុកគ្រី អគ្គលេខាធិការគណបក្សនរោត្តម រណឫទ្ធិ ក៏បានថ្លែងប្រាប់អ្នកសារព័ត៌មានថា វាជារឿងអយុត្តិធម៌ខ្លាំងណាស់ សម្តេចក្រុមព្រះ ដែលតុលាការកំពូលសំរេចដំកល់សាលក្រមទុកឱ្យជាប់គុក១៨ខែ ពិន័យជាប្រាក់ ១៥ម៉ឺនដុល្លារ ពីព្រោះព្រះអង្គគ្មានកំហុសដូចការចោទប្រកាន់ ហើយតុលាការពុំបានសួរទៅមេធាវីនិងពិនិត្យសំនុំរឿងឱ្យបានច្បាស់លាស់ ។

លោក សុក សំអឿន ស្នើសុំមិនធ្វើការអត្ថាធិប្បាយ ប៉ុន្តែលោកគ្រាន់តែបញ្ជាក់យ៉ាងខ្លីថា ប្រធានបក្សស្នើសុំដកពាក្យបណ្តឹង បែរជាគ្មានប្រសិទ្ធិភាព ហើយតុលាការថា ជារឿងរបស់លោក ញ៉ឹក ប៊ុនឆៃ ជាអ្នកសំរេចទៅវិញ ។

លោក សុក សំអឿន បន្តថា ករណីសម្តេចក្រុមព្រះទុកឱ្យប្រជាពលរដ្ឋមតិជាតិ អន្តរជាតិសំរេចចុះលោកដូចជាគ្មានអ្វីត្រូវនិយាយទេ ពីព្រោះវាអយុត្តិធម៌ខ្លាំងពេក ។

លោក ឃឹម ប៊ុន ប្រធានតុលាការកំពូល បានញាក់ថា បណ្តឹងនេះ លោក ញ៉ឹក ប៊ុនឆៃ ជាដើមចោទ ហើយលោក កែវ ពុទ្ធរស្មី ជាប្រធានគណបក្ស មកស្នើសុំដក គ្មានសុពលភាពទេ បើតាមផ្លូវច្បាប់ គឺត្រូវតែលោក ញ៉ឹក ប៊ុនឆៃ ទើបស្របតាមទំរង់នៃច្បាប់ ។

ករណីលោក ញ៉ឹក ប៊ុនឆៃ អគ្គលេខាធិការគណបក្សហ្វ៊ុនស៊ិនប៉ិច ប្តឹងសម្តេចក្រុមព្រះ ពីបទលក់ទីស្នាក់ការកណ្តាល នៅជិតគល់ស្ពានជ្រោយចង្វា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសព្រះអង្គតាមសាលក្រម និងសាលដីការបស់សាលាដំបូង និងសាលាឧទ្ធរណ៍ ដោយសំរេចឱ្យសម្តេចក្រុមព្រះ ជាប់គុក១៨ខែ និសងជំងឺចិត្ត១៥ម៉ឺនដុល្លារ ។

នៅដើមឆ្នាំ២០០៧ គណបក្សនរោត្តម រណឫទ្ធិ បានដើរប្រមូលស្នាមមេដៃប្រជាពលរដ្ឋ ដែលគាំទ្រសម្តេចក្រុមព្រះ ស្នើសុំឱ្យព្រះមហាក្សត្រលើកលែងទោសរាប់ម៉ឺននាក់ ប៉ុន្តែត្រូវ ហ៊ុន សែន ធ្វើការជំទាស់ករណីនេះ ដែលជាហេតុធ្វើឱ្យព្រះមហាក្សត្រមិនហ៊ានសំរេចព្រះទ័យ ។

ដោយមើលឃើញភាពអយុត្តិធម៌របស់តុលាការកំពូល លោក សម រង្ស៊ី ប្រធានគណបក្សប្រឆាំងដ៏ធំជាងគេក្នុងប្រទេស បានហៅការសំរេចរបស់តុលាការកំពូលនោះថា ជារឿងអយុត្តិធម៌ខ្លាំងណាស់ ពីព្រោះលោក កែវ ពុទ្ធរស្មីជាប្រធានគណបក្សហ្វ៊ុនស៊ិនប៉ិច ម្ចាស់ដើមបណ្តឹងបានសំរេចដកពាក្យបណ្តឹងរួចហើយ ។

លោក សម រង្ស៊ី ក្នុងនាមជាប្រធានគណបក្ស ក៏បានសំរេចធ្វើលិខិតថ្វាយព្រះមហាក្សត្រ ដើម្បីស្នើសុំការលើកលែងទោសចំពោះសម្តេចក្រុមព្រះពីការចោទប្រកាន់របស់តុលាការនោះ ។

លោក ម៉ម សូណង់ដូ ប្រធានស្ថានីយវិទ្យុសំបុកឃ្មុំ ក៏បានសរសេរលិខិតទូលថ្វាយទៅព្រះករុណា នរោត្តម សីហមុនី ឱ្យលើកលែងទោសចំពោះសម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ ដែលតុលាការកំពូលបានកាត់ទោសឱ្យព្រះអង្គជាប់គុក ១៨ខែ និងសងជំងឺចិត្ត១៥ម៉ឺនដុល្លារ ។

លោក ម៉ម សូណង់ដូ បានបន្តថា ការកាត់ទោសនេះអយុត្តិធម៌ ហើយលោកមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះវាសនារបស់ប្រជាពលរដ្ឋខ្មែរ ដែលអ្នកនយោបាយឈ្លោះគ្នាឈ្នានីសសងសឹកគ្នាមិនយកការរួបរួមគ្នា និងការអភិវឌ្ឍជាតិជាមួយគ្នាជាមូលដ្ឋាន ។ យោងតាមរដ្ឋធម្មនុញ្ញជំពូកទី២ មាត្រាទី៨ បានចែងថា ព្រះមហាក្សត្រ ព្រះអង្គទ្រង់ជានិមិត្តរូបនៃឯករាជ្យជាតិ និងនិរន្តរភាពជាតិធានាឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដីធានានូវសិទ្ធិរបស់ប្រជាពលរដ្ឋ ។

ក្នុងលិខិតរបស់លោក ម៉ម សូណង់ដូ បានទូលថ្វាយព្រះមហាក្សត្រថា លោកក៏ដូចជា ប្រជាពលរដ្ឋ ដែលជ្រកក្រោមម្លប់ព្រះករុណាអង្គម្ចាស់ជីវិតម្កល់លើត្បូងសង្ឃឹមលើព្រះអង្គ ដែលអាចប្រទានយុត្តិធម៌ដល់កូនចៅរបស់ព្រះអង្គ ។ ជាពិសេស សូមឱ្យទ្រង់លើកលែងទោស ចំពោះសម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ ជាដំណោះស្រាយមួយដ៏ល្អឈានទៅរកការផ្សះផ្សាជាតិរវាងអ្នកនយោបាយទាំងអស់ ដើម្បីទប់ទល់នឹងបរទេសឈ្លានពាន ។

(តទៅទំព័រទី២០)



Get Connect...Stay inform.

....Subscribe to the Khmer Post!

Please send me 1 year subscription of the Khmer Post newspaper 24 issues for $60.00

Name:

Address:

Payment method:

Money order Check Bill me

Please send your payment to US-Asia Media Group.
5730 Rising Sun Ave. Philadelphia, Pa 19120

## Searching for missing sister Nong Watana ,Uncle, and Grandmother



Nong Soponna



My name is Nong Soponna (srey Nang), and live in the United States with my family. I am searching for my younger sister, Nong Watana (srey Noech), born in Toul Kok, Phnom Penh , CAMBODIA . She liked to go to Wat Neaka Vorn with her grandma. She was separated and missing from my family since 1975, at age 3-4 years old, when the Khmer Rouge Regime took over our country, and we had to evacuate out of Phnom Penh, the capitol of CAMBODIA . We got separated at the Kilo #6, in front of the Coca Cola Factory, when our car got a flat tire. There were many people evacuated out of the country; since then, we have never seen each other. My sister Nong Watana (srey Noech) was with my grandma, Meas Kim Orn, (lok Ma), and her uncle, Kang Pirun (Bu Pbom), who has a broken wrist on the right hand side. Also, my sister was with our neighbors name (lok kru Sai), he was an Elementary School Principal at Neaka Vorn school. He had 6 children; 5 sons and 1 daughter; and my sister is about the same age as his daughter.

Family names:
Mother: Kang Konthea and Father: Nong Kiry
Sisters: Oldest, bong Dette; 2nd sister, bong Nette; 3rd sister, bong Nang;
4th sister, srey Noech; Youngest sister, srey Keo.
Grand father: Kang Lin (lok Kung)
Grand mother: Meas Kim Orn, (lok Ma)
Uncle: Kang Pirun (Bu Pbom)

If anyone has any information about my sister Nong Watana, (srey Noech), who is about 35 years old now, my uncle, Kang Pirun (bu Pbom) age about 50 years old, and my grandma, Meas Kim Orn, age about 80 years old, please contact Valerie immediately at:

Cell: (562) 208-3193
Valerie/Wendy
P.O. Box #551
Paramount, CA 90723

Email: valerie_n_us@yahoo.com

Thank you in advance for your help, and hope to hear from you soon.
Soporna & Family

*DNA Test will be given.
"With God Everything is Possible..." May God bless you.

## ពិធីជួបជុំបន្តវេនអ្នកដឹកនាំសេវាកម្មសង្គមសាធារណៈ



**Monterey Park : វិភាគ**

●●●មនុស្សរាប់រយនាក់ចម្រុះទៅដោយជាតិសាសន៍ ដែលក្នុងនោះមានជនជាតិខ្មែរជាបុគ្គលិក និងជាភ្ញៀវផង បានចូលរួមក្នុងពិធីលាងសាយភោជន៍ កាលពីថ្ងៃទី៣១ ខែកក្កដា កន្លងទៅនេះ ក្នុងបំណងបង្ហាញពីសកម្មភាពការងាររបស់សមាគមអាស៊ី-អាមេរិក ផ្នែកសេវាកម្មសង្គមសាធារណៈចំពោះកិច្ចបំរើសហគមន៍អាស៊ីនៅក្នុងតំបន់ L.A County ជុំវិញសេវាកម្មសិក្សាធិការ, ប្រព័ន្ធសុខមាលភាពទូទៅ, សង្គមកិច្ចជាដើម ។



នៅក្នុងពិធីនោះក៏បានផ្ទេរនូវតំណែងបន្តពីអ្នកដឹកនាំចាស់មកឱ្យអ្នកដឹកនាំថ្មីនៃអង្គការសមាគមបុគ្គលិកអាស៊ី-អាមេរិកាំង បន្ទុសកម្មភាពជាបន្តទៀតក្រោមជំនួយថវិការដ្ឋ និងសហព័ន្ធ ។



Steven Golightly អនុប្រធាននៃសមាគមមួយនេះ និយាយថា ក្នុងនាមអង្គការអាស៊ី-អាមេរិកាំង ធ្វើការជាមួយសហគមន៍អាស៊ីប៉ាស៊ីហ្វិក ដែលយើងជាបុគ្គលិក និងបន្តកិច្ចការងារបំរើសង្គមសាធារណៈ តាមគោលការណ៍រដ្ឋ ឬបណ្តាអង្គការនានា ។ ក្នុងពិធីនោះ គេសង្កេតឃើញមានភ្ញៀវជាកិត្តិយសចូលរួមមានសមាជិករដ្ឋសភាចៅហ្វាយក្រុងនានា និងថ្នាក់ដឹកនាំធំៗ នៅក្នុងក្រសួងសេវាកម្មសង្គមសាធារណៈរដ្ឋ California ផងដែរ ៕


FreeLife
The Himalayan Goji Company®




the World´s Most Powerful Anti-Aging Food

ចំណីដែលទប់ទល់ជរាភាពដ៏ខ្លាំងជាងគេក្នុងលោក
គឺទឹកផ្លែឈើ "គោជី" នៃព្រៃហេមពាន្ត

HIMALYAN GOJI
Juice



ការសម្ងាត់នៃសុខភាពល្អរបស់ពួកអាស៊ីបានត្រូវរកឃើញ នារជ្ជកាលស្តេចតាំងឆ្នាំ ៨០០ គ.ស ពលរដ្ឋនៃតំបន់មួយនៅព្រៃហេមពាន្តមិនព្រមចាស់-សក់ក៏មិនស-ធ្មេញក៏មិនបាក់-គេថា អ្នកស្រុកបានផឹកទឹកអណ្តូងមួយដែលមានដើម "គោជី "ដុះជុំវិញ គេស្មានថា មានវត្ថុសក្តិសិទ្ធអ្វីមួយជួយថែរក្សាពួកគេ ។ ទើបឥឡូវនេះ គេដឹកថា "គោជី " មានជីវជាតិពិសេសមួយឈ្មោះ POLYSACHARIDES ដែលពុំមាននៅផ្លែឈើឯណាទៀតសោះ ដែលជួយដល់ប្រព័ន្ធការពារខ្លួនរបស់មនុស្សបាន ។

បើចង់បាន Goji មកពិសារសូំជាវតាម www.forever.freelife.com
ឬក៏ទូរស័ព្ទលេខ : **(267) 253-3947**

SHARE THE SECRET

TIME Magazine wrote :

*" this year´s breakout (Superfruit ) was the Himalyan Goji Berry, said to be a source of energy and longevity ".* To order, please visit the website at : **www.forever.freelife.com**

**Or please call (267) 253-3947 to order**



# រាត្រីស៊ុបគោឆ្នាំងដី និង បបរស
# នៅ កោះឫស្សី





**ក្រុងខ្មែរ ៖ វ៉ាន់នាថ**

នៅតាមបណ្ដោយផ្លូវ Anaheim ដែលខ្មែរយើងទាំងអស់គ្នាមានកិត្តិយស និងមោទនភាពទទួលបាននូវមុខមាត់ថ្មី ក្នុងរយៈកាលមួយឆ្នាំមកនោះ គឺតំបន់អតីតជនភៀសខ្លួនខ្មែរមួយនេះបានប្រែឈ្មោះទៅជាក្រុងខ្មែរ ។ នៅក្នុងភោជនីយ-ដ្ឋានខ្មែរមួយ មានឈ្មោះកោះឫស្សី (Bamboo Island) នូវអ្វីដែលចម្លែក គឺត្រង់ម្ចាស់ហាងមួយនេះបានរៀបចំពីទិដ្ឋភាពកន្លែង ដើម្បីទាក់ទាញភ្ញៀវ ។ ភាពទាក់ទាញនោះបានលេចចេញឡើងនូវផ្ទាំងគំនូររូបភាព ដែលដក់ជាប់ក្នុងក្រអៅបេះដូងយើងជាខ្មែររាល់រូបមិនអាចប្រកែកបានដូចជាផ្ទាំងប្រាសាទអង្គរវត្ត ស្ត្រីខ្មែររបាំអប្សរាដ៏ទន់ភ្លន់គ្រប់លក្ខណ៍ ជានារីខ្មែរនាសម័យដើម ក្នុងរជ្ជកាលព្រះថោងនាងនាគ និងព្រះអង្គនាងលីវយីនោះ និងលើសពីនោះ ទៀតសោត យើងឃើញមានទូតាំងរូបចម្លាក់ នៃវត្តបុរាណខ្មែរធុងដាំដើមឫស្សី ដែលយើងនឹកឃើញដល់ម្ហូបខ្មែរសម្លប្រហើរទំពាំង គុម្ពដើម និងផ្លែសាម៉ាវសិប្បនិម្មិត ដែលនឹកគិតដល់អ្នកចំការក្នុងអតីតទឹកដីទៃត្បូងពេជ្រប៉ៃលិន ឃុំននារី ចៅចិត្រ នាខេត្តបាត់ដំបង និងគុម្ពចេកជានិមិត្តរូបនៃយើងជាខ្មែរតែងតែភ្ជាប់ជីវិតជាកសិករស្រែចំការដាំដើមចេកនៅក្បែរផ្ទះ ដែលសូម្បីបងប្អូនខ្មែរមួយចំនួន កំពុងរស់នៅតំបន់ឡុងប៊ិចនោះទៀតសោត ក៏មិនដែលផ្ដាច់មនោសញ្ចេតនាការដាំដុះដើមចេក នេះដែររហូតដល់មានពាក្យនិយាយតៗគ្នាថា "ផ្ទះណាមានដាំដើមចេក គឺផ្ទះខ្មែរហើយ" ។

ព្រោះគេយល់ថា ដើមចេកជាចំណីអាហារ និងបង្អែមចង្ហាបរបស់ពួកគេក្នុងជីវភាពរស់នៅ ដូចជា ការដាំស្លសម្លម្ជូរត្រយ៉ូងចេករបយនំបញ្ចុកបុកទឹកគ្រឿងជាដើមរួមនឹងធ្វើបង្អែមចេកខ្ទិះ នំអន្សមចេក ផ្លែចេកទុំសំរាប់ហូប និងផ្លែចេកខ្ចីជ្រលក់ប្រហុកឆៅទៀតផង ។

ការពិពណ៌នាទាំងអស់នេះហើយ ដែលយើងចង់បង្វែរអារម្មណ៍នឹងការចូលទៅ ហូបចុកផឹក ស៊ី ទទួលទានជាមួយទិដ្ឋភាពទាក់ទាញនេះ គឺ នៅត្រង់រាត្រីនារាល់ចុងសប្ដាហ៍ភោជនីយដ្ឋានកោះឫស្សីនេះ មានលក់នូវបបរស-ត្រីងៀតពោះគោ ខជ្រូក កំដរទៅដោយខារ៉ាអូខេ ដែលអាចច្រៀងផ្ទាល់ខ្លួនឯងបានទៀតផង ទោះបទបែបមនោសញ្ចេតនា ស៊ិន ស៊ីសាមុត, រស់ សេរីសុទ្ធា ឬ ព្រាប សុវត្ថិ, សាពូន មីដាដា, តារាទឹកភ្នែក ពេជ្រ ចិន្តា, កញ្ញា ទូច ស៊ុននិចក៏ដោយ ដោយរួមទាំងបទបរទេសទៀតផង ដើម្បីកំដរអារម្មណ៍សប្បាយក្នុងជីវិតយើងម្នាក់ៗ ដែលធ្វើការហត់នឿយនៅដើមសប្ដាហ៍ជាប្រចាំទៅហើយនោះ ។ នៅក្នុងភោជនីយដ្ឋានកោះឫស្សីនោះដែរក៏មានម្ហូបពិសេសប្រចាំត្រកូល សំរាប់ភ្ញៀវដែលកំពុងត្រូវការ និងពេញនិយមជាលក្ខណៈគ្រួសារ ឬគូស្នេហ៍ ដើម្បីទទួលទានជាមួយពេលវេលាផ្ដោះផ្ដងគ្នាក្នុងផ្លូវស្នេហា ឬការជជែកគ្នាពីជំនួញការងារជាដើមនោះ **គឺ ស៊ុបឆ្នាំងដី យ៉ាហ៊ាន និង សាច់គោទឹកប្រហុក** ។

យុវជនម្នាក់ឈ្មោះ រ័ត្ន ជាកូនមន្ត្រីជាន់ខ្ពស់ម្នាក់នៅឯប្រទេសកម្ពុជា និយាយប្រាប់ខ្មែរប៉ុស្តិ៍ថា ទិដ្ឋភាពនៃជីវភាពរស់នៅក្នុងក្រុងឡុងប៊ិចតំបន់ខ្មែរមិនខុសពីការរស់នៅដើរលេងសប្បាយដូចស្រុកខ្មែរប៉ុន្មានទេ ។ ដែលរូបគេអះអាងបែបនេះក្នុងន័យថា "ពេលដែលខ្ញុំចេញពីរាំលេងកំសាន្តតាមរង្គសាល (Night Club) មិនថានាគព័ន្ធ វិមានមាស ឋានសួគ៌ ព្រះច័ន្ទពេញ វង់ ឬហាក់ហ៊ាង ខ្ញុំតែងតែនាំមិត្តភ័ក្តិ ឬស្រីស្នេហ៍ទៅកាន់ភោជនីយដ្ឋានកោះឫស្សី ដើម្បីញ៉ាំបបរស ឬស៊ុបឆ្នាំដី និងសាច់គោទឹកប្រហុកក្លែមជាមួយស្រាក្រហម ឬប៊ីយ៉ែរ ទៅតាមចំណង់ចំណូលចិត្តជាមួយការច្រៀងឆ្លងឆ្លើយលេងកំសាន្តផ្ដោះផ្ដងស្នេហ៍ជាមួយគូកំណាន់ ឬមិត្តភ័ក្តិប្រុសស្រីក្នុងចំណីអារម្មណ៍ដ៏ស្រស់ត្រកាលនៃពេលរាត្រី ។

យុវជននេះបានបន្តថា "អនុស្សាវរីយ៍នេះបានធ្វើឱ្យខ្លួនខ្ញុំក៏ដូចមិត្តភ័ក្តិបាននឹកឃើញអតីតកាលនៃការរស់នៅដើរលេងសប្បាយនៅឯស្រុកខ្មែរ កាលណានាំគ្នាចេញពីផឹកស៊ីរាំកំសាន្តពីបារ (Night Club) គឺមិនដែលភ្លេចឡើយ បបរសពេទ្យចិន ឬតំបន់មិត្តភាពផ្លូវកម្ពុជាក្រោមទេ មុននឹងចូលនិទ្រា (ដេក) នេះ បើខ្ញុំនៅភ្នំ-ពេញ ។ ចំណែកដើរលេងនៅខេត្តបាត់ដំបងវិញ គឺមិនភ្លេចទេស៊ុបឆ្នាំង ដីនៅពន្លឺត្បូង ឬចំការល្មុត និងបបរសនៅម៉ុំរោង កុនហាប់ ឆុន ជិតសណ្ឋា-គារអង្គរ ឬតំបន់ប្រឫមាត់ស្ទឹងសង្កែក្បែរនាគបាញ់ទឹកក្រោមម្លប់ដូងទី១០ ក្នុងបទមនោ-សញ្ចេតនា ស៊ិន ស៊ីសាមុត នោះ មុននឹងនាំខ្លួនខ្ញុំទៅកាន់សណ្ឋាគារនោះ ។ បុរសអាយុប្រមាណជិត៣០ឆ្នាំ រូបនេះនិយាយថា នេះជាទឹកដីទី២នៃការដើរសប្បាយជាមួយការហូបចុកស៊ុបគោឆ្នាំដី សាច់គោទឹកប្រហុករួមនឹងបបរសនៅភោជនីយដ្ឋាន "កោះឫស្សី" ។

ចំណែកពីរនាក់ប្ដីប្រពន្ធមិនឱ្យបញ្ចេញឈ្មោះនិយាយថា ពួកគាត់ចូលចិត្តនាំគ្នាដើររាំលេងដើម្បីសប្បាយផ្លូវចិត្ត និងហាត់ប្រាណឱ្យបែកញើសនៅតាមរង្គសាល រួចហើយក៏ហួសនាំគ្នាទៅកាន់ក្រុងយូននៅ "សៃកន" ឯសាន់ តាអា-ណា ដើម្បីហូបស៊ុប ឬគុយទាវ បបរស ជាដើម ។ គាត់និយាយថា "បងប្អូនខ្មែរជាច្រើន បាននាំគ្នាទៅកាន់តំបន់ភោជនីយដ្ឋានយួន បន្ទាប់ចេញពីរាំនៅរង្គសាលខ្មែរនៅឡុងប៊ិច" ។ ប៉ុន្តែឥឡូវប្ដីប្រពន្ធគាត់បានងាកមករកភោជនីយដ្ឋានកោះឫស្សីនេះ ដើម្បីទទួលទាននូវបបរ.ស ពោះជ្រូក ឬត្រីខស៊ុបឆ្នាំងដីជាដើម ព្រោះនៅជិតផ្ទះមិនចំណាយពេលបើកឡានអស់សាំង ព្រោះចុងភៅធ្វើម្ហូបឆ្ងាញ់ ។ ពិសេសនោះគឺយើងជួយសេដ្ឋកិច្ចជាតិគេជាងជាតិខ្មែរគ្នាឯងទៅវិញ ដែលយើងភ្លេចគិតថា "ជួយខ្មែរគ្នាឯង" ក្នុងន័យនេះបុរសចំណាស់អាយុជាង៥០ផ្លាយនិយាយថា តាំងពីគាត់រស់នៅឡុងប៊ិច

( តទៅទំព័រទី១៩ )



(តមកពីទំព័រទី១៨)
## ភ្នំឧដុង្គអតីតរាជធានី និងកន្លែង...

បញ្ចុះព្រះបរមអដ្ឋិព្រះបាទអង្គឌួង និងចេតិយព្រះបាទស៊ីសុវត្ថិមុនីវង្ស ។

កាលពីឆ្នាំ២០០២ អតីតព្រះមហាវីរក្សត្រ សម្តេចនរោត្តម សីហនុ និងសម្តេចព្រះអគ្គមហេសី បានដង្ហែព្រះសារីរិកធាតុទៅតំកល់ នៅទីនោះថែមទៀត ។ រមណីដ្ឋានភ្នំឧដុង្គក្រៅពីមានអ្នកទេសចរទៅទស្សនាកំសាន្តសប្បាយ នៅថ្ងៃឈប់សំរាកក៏មានពុទ្ធបរិស័ទជិតឆ្ងាយ ទៅគោរពបូជាធ្វើការបន់ស្រន់ចំពោះបារមីវត្ថុស័ក្តិសិទ្ធខ្លះ ក៏បានសំរេចបំណង់ថែមទៀតផង ។

លើសពីនេះ ថ្ងៃបុណ្យសាសនា និងបុណ្យជាតិគេសង្កេតឃើញសែរាជវង្សមន្ត្រីអ្នកមុខអ្នកការប្រជារាស្ត្រស្តេចយាង និងអញ្ជើញទៅធ្វើបុណ្យជាញឹកញាប់ ដែលញ៉ាំងឱ្យទីនោះកាន់តែមានភាពអធិកអធមក្រៃលែង ។ ក្នុងចំណោមសមិទ្ធផលទាំងនេះ គេសង្កេតឃើញ កំពូលព្រះវិហារអដ្ឋរស្សបែរមុខទៅទិសខាងជើងសំដៅឆ្ពោះ ទៅប្រទេសចិន មានសភាពទ្រុឌទ្រោមបែកបាក់ស្ទើរអស់ដែលមានតំកល់ព្រះពុទ្ធចូលនិព្វានកំពស់១៨ហត្ថ តាមរចនាបថខ្មែរ ជាចំណងដៃរបស់ប្រទេសចិន តាំងពីសម័យមហានគរមកម្ល៉េះ ។

ទាក់ទិនទៅនឹងរឿងព្រះវិហារ ភ្នំអដ្ឋរស្សនេះ តាមប្រជុំរឿងព្រេងភាគ៥ បានបញ្ជាក់ថា នៅចុងសម័យមហានគរ ស្តេចក្រុងចិន បានបញ្ជាឱ្យបេសកជនជាច្រើន ដើរស៊ើបសួររកប្រទេសណាដែលមានអារ្យធម៌រុងរឿងយកមកផ្សព្វផ្សាយក្នុងប្រទេស ហើយចងជាមិត្ត ប៉ុន្តែបើប្រទេសណាអន់ថយនឹងជួយទំនុកបំរុង ។ នៅពេលនោះបេសកជនចិនក៏ពិនិត្យឃើញស្រុកខ្មែរមានភាពរុងរឿងតែអ្នកស្រុកមិនសូវស៊ីវិលនោះទេ ។

ក្នុងពេលជាមួយគ្នា នោះគេក៏បានរកឃើញភូមិសាស្ត្រល្អតាមក្បួនចិនសែ "ទីនោះអាចនឹងឱ្យផលល្អផ្សេងៗដល់ប្រទេស" នៅលើកំពូលភ្នំព្រះរាជទ្រព្យ ស្រុកពញាឮ ខេត្តកណ្តាល ដែលមានរាង ដូចសត្វមករ គឺខ្លួនមកនៅត្រង់ព្រះចេតិយត្រៃត្រឹងក្បាល និងពុកមាត់មកនៅត្រង់ចេតិយទន្ទឹមកន្ទុយត្រង់ព្រះពុទ្ធចូលនិព្វាន្ត ។ តាមក្បួនចិនសែ បើប្រទេសណាមានសត្វមករផុសឡើង ប្រទេសនោះនឹងមានឫទ្ធិអំណាចថ្កុំថ្កើងរុងរឿងពុំមានប្រទេសណាអាចតស៊ូបានទេ។

ពេលត្រលប់ទៅប្រទេសវិញ បេសកជនចិនបានយករឿងនេះទៅទូលថ្វាយព្រះរាជាឱ្យទ្រង់ជ្រាប ហើយរិះរកវិធីផ្សេងៗ ដើម្បីបង្ក្រាបប្រទេសខ្មែរ និងមិនឱ្យសត្វមករងើបឡើងបាន ។ នៅទីបំផុត ស្តេចចិនបានឱ្យមន្ត្រីចិនទៅសុំស្តេចខ្មែរ ដើម្បីកសាងព្រះវិហារបែរមុខទៅទិសខាងជើង តាមរចនាបថខ្មែរ ដើម្បីសន្ធាប់រូងនោះកុំឱ្យសត្វមករចេញរួច ដោយមានតំកល់ព្រះអង្គធំកំពស់១៨ហត្ថ ។

ក្រោយមកស្តេចចិនក៏ឱ្យមន្ត្រីរបស់ខ្លួនយកប្រស្នាឱ្យស្តេចខ្មែរដោះស្រាយ ដោយដាក់លក្ខខណ្ឌថា បើដោះប្រស្នានេះពុំរួចប្រទេសខ្មែរត្រូវជាចំណុះប្រទេសចិន ហើយនាំសួយសារអាករថ្វាយចិនរៀងរាល់ឆ្នាំ ។ ប្រស្នាទាំងពាខនេះស្តេចនាម៉ឺនមន្ត្រីខ្មែរពុំមាននរណាអាចដោះស្រាយបានឡើយ ហើយក៏បានដើរប៉ាវគងរកអ្នកមានបញ្ញាដើម្បីដោះស្រាយ ខណៈនោះមានអ្នកគង្វាលគោម្នាក់ធានាថាអាចដោះប្រស្នាបានក៏នាំទៅថ្វាយស្តេច ។

លុះដល់កំណត់៧ថ្ងៃ មន្ត្រីចិនក៏បានមកជួយជុំគ្នាដើម្បីស្តាប់ចំលើយ ហើយអ្នកគង្វាលគោនោះ ក៏ឆ្លើយដោះប្រស្នារួចចំណែកចិនក៏ទទួលស្គាល់សុំចងមេត្រីភាជាមួយខ្មែរ ចាប់តាំងពីពេលនោះរហូតមក ។ រីឯបុរសគង្វាលគោត្រូវព្រះរាជាខ្មែរទ្រង់ប្រោសប្រទានទ្រព្យសម្បត្តិជាច្រើន ហើយតាំងគោរម្យងារថា "ធនញ្ជ័យបណ្ឌិត" ដែលប្រជាពលរដ្ឋខ្មែរគ្រប់ទិសទីស្រឡាញ់យ៉ាងខ្លាំង ។

ក្រុងឧដុង្គនេះ កសាងក្នុងរជ្ជកាលព្រះបាទជ័យជេដ្ឋាទី២ គ្រិស្តសករាជ១៦២០ ខណៈពេលដែលព្រះអង្គយាងមកប្រពាត ព្រៃនៅតំបន់អូរ ខេត្តសំរោងទង ហើយទតឃើញទិដ្ឋភាពនៅទីនោះ មានទេសភាពភូមិសាស្ត្រល្អ ។ បន្ទាប់ពីសព្វព្រះទ័យ ព្រះអង្គក៏ឱ្យហោរាគន់គូរ និងឱ្យនាម៉ឺនសព្វ មន្ត្រីជួយឱ្យយោបល់ថា មានអំណោយផលល្អ ហើយព្រះអង្គបានសំរេចចិត្តលើរាជធានីពីល្វាឯមមកក្រុងឧដុង្គនេះចាប់ពី (គ.ស ១៦២០-១៨៦៦) ។

រមណីដ្ឋានភ្នំឧដុង្គមិនត្រឹមតែមានសំណង់ប្រវត្តិសាស្ត្រប្លែកៗគួរឱ្យទាក់ទាញភ្ញៀវទេសចរប៉ុណ្ណោះទេ តែថែមទាំងមានធម្មជាតិស្រស់បំព្រងចោលម្លប់ត្រជាក់បារមីស័ក្តិសិទ្ធ និងមានសំណង់វត្តអារាមនៅក្បែរជើងភ្នំរាប់សិបកន្លែងសំរាប់គោរពបូជា ។

លើសពីនេះទៀត នៅតំបន់អតីតរាជធានីនោះ មានកន្លែងបញ្ចុះព្រះបរមអដ្ឋិអតីតព្រះមហាក្សត្រជាច្រើន ដែលធ្វើឱ្យសែរាជវង្សានុវង្សយាងទៅធ្វើបុណ្យទានឧទ្ទិសកុសលផលបុណ្យដល់បុព្វការីជនជាញឹកញាប់ ៕

(តមកពីទំព័រទី១៨)
## បារមីព្រះអង្គចេកព្រះអង្គចម...

មកជួបយាយកណ្តុំស័ក្តិ (ប្រពន្ធក្រោយ ដាប ឈួន)។

ខណៈនោះ ដាប ឈួន បាននាំយាយ កណ្តុំស័ក្តិ


ស្ត្រីខ្មែរអាមេរិកាំង និងជំនឿក្នុងការបន់ស្រន់ (រូបថត ខ្មែរប៉ុស្តិ៍)

រត់ដល់ព្រៃស្អាក តែត្រូវគេតាមបាញ់បាក់ជើង ដាប ឈួន ហើយ យាយ កណ្តុំស័ក្តិ បានឈរពាំងមុខកុំឱ្យគេបាញ់ត្រូវប្តី ព្រោះយាយ កណ្តុំស័ក្តិនេះចេះវេទមន្ត បាញ់មិនត្រូវទេ ទោះជាគ្រាប់ ដូចទឹកភ្លៀងក៏ដោយ តែក្រោយមកគេក៏ចាប់បានដាប ឈួន សួររឿងរ៉ាវទៅមានពាក់ព័ន្ធមនុស្សគ្នាច្រើនពេក គេក៏បាញ់សម្លាប់តែ ដាប ឈួន ម្នាក់ដោយគេចងដាក់លើគារអូសពីក្រោយរថយន្ត ។

លោក ឌី សំបូរ បន្តថា ពេល ដាប ឈួន ស្លាប់ទៅគេក៏យកព្រះអង្គចេក ព្រះអង្គចម មកដាក់នៅវិហារសព្វថ្ងៃតែលើកពុំរួចទាល់តែសោះ លុះធ្វើពិធីបួងសួងនិមន្តមកគង់នៅទីនេះ ទើបលើកដាក់រថយន្តរួច ហើយក៏យកមកដាក់នៅព្រះវិហារនេះ ដើម្បីប្រារព្ធបូជានៅឆ្នាំ១៩៥៩ ។

លោកបន្តទៀតថា ក្នុងសម័យខ្មែរក្រហម គេបំរុងយកព្រះអង្គចេក ព្រះអង្គចមទៅកំទេចចោលតែកំទេចមិនកើត សូម្បីតែដាក់មីនក៏មិនផ្ទុះ គេលើកដាក់រថយន្តយកមកទំលាក់ពីលើស្ពានថ្មមុខរាជ្យដំណាក់សព្វថ្ងៃចូលទៅក្នុងទឹកបណ្តាលឱ្យបាក់ដៃម្ខាង ។ នៅឆ្នាំ១៩៧៩ អ្នកស្រុកក៏នាំគ្នាចុះរាវក្នុងទឹកមិនឃើញបាននាំគ្នាបួងសួងរាវម្តងទៀតក៏ប្រទះឃើញនាំគ្នាសែងមកដាក់នៅវត្តដំណាក់ ព្រោះជារបស់មានតំលៃ គេក៏ធ្វើពិធីបួងសួងសូមនិមន្តមកនៅវិហារចាស់ (បឹងគីឡូ) តែពេលដង្ហែមកមានសុទ្ធតែរថក្រោះមករកលើកដាក់ទៅទៀត តែត្រូវបានការពារពីមេទាហានពីចៅហ្វាយខេត្តជួយអន្តរាគមន៍កុំឱ្យបាត់ព្រះអង្គចេក ព្រះអង្គចម ។

ប្រភពដដែលបានបន្តទៀតថា មូលហេតុ ដែលមានរថក្រោះមកចង់លើកដាក់នេះ ព្រោះចង់យកទៅលក់ឱ្យសៀម រីឯដៃម្ខាងដែលបាក់បាត់នោះ ត្រូវគេបញ្ចូលរូបក៏រកឃើញមកវិញ តែតពុំជាប់ទេ ទាល់តែបួងសួងទើបបាន ។ សព្វថ្ងៃព្រះអង្គចេក ព្រះអង្គចម ត្រូវបានប្រជាពលរដ្ឋមកពីទីជិតឆ្ងាយទៅគោរពបូជា និងមានជំនឿយ៉ាងមុតមាំ ហើយបារមីរបស់ព្រះអង្គ នៅតែខ្លាំងក្លាដដែល ចំណែកពុទ្ធបរិស័ទជិតឆ្ងាយ អ្នកមុខ អ្នកការខ្លះដែលមានទុក្ខលំបាក បានមកធ្វើការបន់ស្រន់ជាហូរហែរ ហើយក៏បានសំរេចជាញឹកញាប់ ។

លោកតា ទី ម៉េង ដែលទៅបួងសួងទីនោះបានឱ្យដឹងថា គាត់មកបន់នេះដើម្បីលាបំណន់ពីព្រោះកាលពីលើកមុនលោកបានបន់សូមឱ្យលក់ដីដាច់ លុះពេលលក់ដាច់ហើយក៏យកសំណែនមកថ្វាយ ។ លោកបញ្ជាក់ថា ព្រះអង្គចេក ព្រះអង្គចម ស័ក្តិសិទ្ធខ្លាំងណាស់គ្រួសារគាត់ក៏ដូចអ្នកភូមិជឿអស់ពីពោះតែម្តង ៕

(តមកពីទំព័រទី១៧)
## រាត្រីស៊ុនគោឆ្លាំងដី...

ជាង២០ឆ្នាំ មិនដែលប្រទះភ្នែកឃើញយួន និងសៀមចូលហូងហាងខ្មែរយើងទេ ក្រៅតែពីខ្មែរគ្នាឯងអូតតែពីហាង យួន និងសៀមថាឆ្ងាញ់ ដែលចំណុចនេះហើយ ធ្វើឱ្យគាត់នឹកឃើញថា សង្គមខ្មែរគួរត្រូវបានបងប្អូនខ្មែរចេះជួយគាំទ្រសេដ្ឋកិច្ចគ្នាឱ្យបានរឹងមាំ ឬទេ ?

ភោជនីយដ្ឋានកោះឫស្សីតាមការអះអាងពីម្ចាស់ហាងនិយាយថា បើក៧ថ្ងៃ មួយសប្តាហ៍ ដែលចុងសប្តាហ៍បើកពីព្រឹករហូតដល់ម៉ោង២ភ្លឺ។

ចន ជាថៅកែនិយាយថា គាត់ និងប្រពន្ធធ្វើការជួយសហគមន៍ខ្មែរជាច្រើនឆ្នាំ មកហើយក្នុងសមាគម UCC និង CAA ប៉ុន្តែឥឡូវគាត់ជាប្តីប្រពន្ធបានងាកមករកស៊ីបន្ថែមអាជីពទៀត ដើម្បីចូលរួមពង្រីកសេដ្ឋកិច្ចទីផ្សារក្នុងតំបន់ខ្មែរ ។ ប៉ុន្តែអាជីពជំនួញជាម្ចាស់ភោជនីយដ្ឋានកោះឫស្សីនេះក៏កំពុងតែដំណើរការដោយរលូនជា បណ្តើរៗដែរ ក៏វាអាស្រ័យដោយមានការគាំទ្រពីបងប្អូនខ្មែរផងដែរ ។

នៅពេលដែលយើងដើរកាត់ស្របតាមបណ្តោយផ្លូវ Anaheim នាពេលរាត្រី ពិសេសចុងសប្តាហ៍ គ្មានអារម្មណ៍ណាដែលយើងមិនឮ សម្លេងច្រៀងខារ៉ាអូខេ និងមនុស្សម្នាទៅកាន់ទីនោះក្នុងគោលបំណងហូបស៊ុប, សាច់គោទឹក ប្រហុក ឬបបរស ក្លែមជាមួយស្រាចម្រុះនានានោះទេ នៅក្នុងភោជនីយដ្ឋានកោះឫស្សីដែលជាកន្លែងជំនួញមួយក្នុងចំណោមអ្នកជំនួញខ្មែរ ជាច្រើនរយកន្លែងទៀត ពីលិចទៅកើតចន្លោះផ្លូវ Atlantic ទៅ Junipero នោះ ៕


# ការិយាល័យមេធាវី លិនហ្សេ ដ៏រីង
# LAW OFFICE OF LINDSAY DOERING

**ទទួលការពារផលប្រយោជន៍លោកអ្នកករណីទូទៅតាមផ្លូវច្បាប់ដូចជា :**

- ករណីបើករបរពាណិជ្ជកម្ម នឹងផ្ទេរប្រាក់ក្នុងមុខជំនួញ
- ករណីទិញលក់អចលនវត្ថុ ដូចជា: ផ្ទះសម្បែង ដីធ្លីជាដើម ។
- ករណីគ្រោះថ្នាក់រថយន្ត ឬគ្រោះថ្នាក់នៅកន្លែងធ្វើការ
- ករណីអន្តោប្រវេសន៍
- ឬករណីឧក្រិដ្ឋកម្ម ។ល។



**ធ្លាប់មានបទពិសោធន៍ខ្ពស់ -ផ្តល់សេវាជូនតាមវិជ្ជាជីវៈ ហើយតម្លៃក៏សមរម្យទៀតផង -យើងអាចមានអ្នកបកប្រែភាសាជូនលោកអ្នកបាន ៗ**

General practice law office handling matters in :

Corporations and business transations
Read estate
Car Accidents
Work place injury
Immigration
Criminal fefense
Experienced, professional service and reasonable rate. translator available.

Office: (215) 667-8118 2301 Delancey place, Philadelphia PA 19103
Cell : (215) 840-1364 Email : lindsaydoering@yahoo.com

## (តមកពីទំព័រទី១៥) ជីវិតសេចក្ដីក្រោយរបស់ទ្រង់...

ក្នុងសន្ទរកថា កាលពីថ្ងៃទី០៥ ខែសីហា នៅខេត្តកំពង់ស្ពឺ នាយករដ្ឋមន្ត្រីខ្មែរ ហ៊ុន សែន បន្ទាប់ពីធ្វើការរិះគន់ចំពោះគណបក្សហ៊្វុនស៊ិនប៉ិច ដែលជាដៃគូចំរុះនោះ ក៏បានបញ្ជាក់ថា លោកនឹងស្នើឱ្យព្រះមហាក្សត្រនរោត្តម សីហមុនី ផ្ដល់ការប្រទានទោសដល់សម្ដេចក្រុមព្រះនរោត្តម រណឫទ្ធិ នៅពេលដែលព្រះអង្គវិលមកទទួលទោសរយៈពេល១២ខែសិន ។

ហ៊ុន សែន បានបញ្ជាក់ថា អ្នកដែលបានកាត់ទោសជាប់គុក ពួកគេត្រូវតែចំណាយពេល ២/៣ នៃពេលវេលាជាប់ពន្ធធាគារសិន ចំពោះព្រះអង្គមិនទាន់ជាប់គុកផងនោះ ។

បើផ្អែកទៅតាមប្រសាសន៍របស់ ហ៊ុន សែន គឺសម្ដេចក្រុមព្រះប្រហែលជាត្រូវរាំងស្ទះក្នុងការយាងវិលត្រឡប់មកមាតុប្រទេសវិញ ហើយបេក្ខភាពតំណាងរាស្ត្ររបស់ព្រះអង្គក៏អាចបាត់បង់ដែរ ប្រសិនបើព្រះអង្គមិនមានការលើកលែងទោសឱ្យទាន់ពេលវេលានោះ ។

គួរបញ្ជាក់ថា តួអង្គដ៏សំខាន់នៃសៃរាជ្យវង្សក្នុងឆាកនយោបាយ គឺមានតែសម្ដេចក្រុមព្រះនរោត្តម រណឫទ្ធិ តែប៉ុណ្ណោះ ដែលត្រូវបានមតិ



ព្រះមហាក្សត្រនរោត្តម សីហមុនី



ហ៊ុន សែន

ជាតិ-អន្តរជាតិ ទទួលស្គាល់ ។ ចំណែកឯតួអង្គមួយចំនួនទៀត ក៏បានលាឈប់ធ្វើនយោបាយជាបន្តបន្ទាប់ គឺសម្ដេចក្រុមឃុន នរោត្តម សិរីវឌ្ឍ.ម្ចាស់ក្សត្រី វឌ្ឍរ៉ា និងនរោត្តម ច័ក្រពង្ស ។ រីឯទ្រង់នរោត្តម អារុណរស្មី ស៊ីសុវត្ថិ សិរីរ័ត្ន និងសមាជិករាជវង្សមួយចំនួនទៀតក៏កំពុងតែប្រឈមមុខនឹងបាត់បង់តំណែងក្នុងឆាកនយោបាយដែរ ។

អ្នកវិភាគនយោបាយបានបញ្ចេញទស្សនៈប្រហាក់ប្រហែលគ្នាថា សៃរាជវង្សនឹងឃ្លាតឆ្ងាយពីឆាកនយោបាយនៅពេលដ៏ខ្លីខាងមុខ ហើយមិនអាចស្ដាប្រជាប្រិយភាពបានទេ កាលពីថ្ងៃទី១២ សីហា កន្លងទៅនេះ សម្ដេចក្រុមព្រះនរោត្តម រណឫទ្ធិ បានចេញសេចក្ដីថ្លែងការណ៍មួយពីប្រទេសបារាំង ដោយសរសេរថា "គណបក្សនរោត្តម រណឫទ្ធិ សូមទទួលស្គាល់លទ្ធផលបោះឆ្នោតជាផ្លូវការ ដែលរៀបចំដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

កាលពីថ្ងៃទី២៧ កក្កដា ពិតជាមានតម្លាភាពដោយសេរី និងដំណើរការតាមបែបប្រជាធិបតេយ្យ ។

ក្នុងសេចក្ដីថ្លែងការណ៍បានបញ្ជាក់ថា គណបក្សនរោត្តម រណឫទ្ធិ សូមប្រកាសថា ខ្លួននឹងមិនបង្កើតសម្ព័ន្ធភាពជាមួយគណបក្ស សម រង្ស៊ី ទេ ។ សេចក្ដីថ្លែងការណ៍នេះ បានធ្វើឱ្យមន្ត្រីរបស់គណបក្ស និងអ្នកគាំទ្រមួយចំនួនមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ។

លោក សម រង្ស៊ី ប្រធានគណបក្ស សម រង្ស៊ី និងលោក អ៊ូ ច័ន្ទរ័ត្ន អគ្គលេខាគណបក្សសិទ្ធិមនុស្ស បានថ្លែងក្នុងសន្និសីទកាសែត កាលពីថ្ងៃទី១២ថា លោកមិនខ្វល់ពីការដកខ្លួនរបស់គណបក្សនរោត្តម រណឫទ្ធិ ពីសម្ព័ន្ធភាពគណបក្សប្រឆាំងនោះទេ ។ ជាច្រើនលើកមកហើយព្រះអង្គតែងមករួបរួម ហើយក្រោយមកក៏ដកខ្លួនចេញ ដោយមានល្បិចកលផ្សេងៗ ហើយការដកខ្លួននេះ ពិតជាមានអ្វីលាក់បាំង និងទទួលផលប្រយោជន៍អ្វីមិនខានឡើយ ។

ការផ្ដាច់ចេញពីសម្ព័ន្ធភាពរបស់ទ្រង់រណឫទ្ធិនេះ អ្នកវិភាគនយោបាយមួយចំនួន បានលើកហេតុផលថា អាចធ្វើឱ្យ ហ៊ុន សែន ទន់ចិត្ត ហើយយល់ព្រមធ្វើការស្នើសុំទៅព្រះមហាក្សត្រ ដើម្បីព្រះរាជទានទោសដល់ទ្រង់ ដែលត្រូវតុលាការផ្ដន្ទាទោសឱ្យជាប់ពន្ធនាគារ ១៨ខែ និងសងជំងឺចិត្ត១៥ម៉ឺនដុល្លារ ឱ្យគណបក្សហ៊្វុនស៊ិនប៉ិច ។

រហូតមកដល់ថ្ងៃទី១៣ សីហានេះ គេមិនទាន់ឃើញព្រះរាជក្រឹត្យរបស់ព្រះមហាក្សត្រ ដែលគង់នៅទីក្រុងប៉េកាំង ធ្វើការលើកលែងទោសនៅឡើយទេ ។ តែទោះជាយ៉ាងណាតាមប្រភពក្រៅផ្លូវការសម្ដេចក្រុមព្រះនឹងយាងត្រលប់មកកាន់មាតុប្រទេសវិញ ដើម្បីបង្កើតរដ្ឋាភិបាលចំរុះជាមួយគណបក្សប្រជាជនកម្ពុជា នៅពេលខាងមុខនេះ ។

ទ្រង់រណឫទ្ធិ កាលពីអតីតកាល ក្នុងឆ្នាំ ១៩៩៨ និង ២០០៣ បានដឹកនាំគណបក្សរបស់ទ្រង់ចូលរួមជាមួយគណបក្ស សម រង្ស៊ី ក្រោយមកក៏បានដកខ្លួនចេញទៅបង្កើតរដ្ឋាភិបាលចំរុះជាមួយគណបក្សប្រជាជន ។

នៅពេលនិរទេសខ្លួន ឯក្រៅប្រទេសទ្រង់រណឫទ្ធិ បានផ្ដួចផ្ដើមឱ្យមានការរួបរួមរវាងអ្នកប្រជាធិបតេយ្យមុនការបោះឆ្នោតថ្ងៃទី២៧ កក្កដា បន្ទាប់ពីគណបក្សរបស់ទ្រង់ចាញ់ឆ្នោត ក៏បានមកចងសម្ព័ន្ធជាមួយគណបក្ស សម រង្ស៊ី ។ ប៉ុន្តែចំណងមិត្តភាពនេះ ក៏បានរលាយទៅវិញ ដែលធ្វើឱ្យអ្នកតាមដាននយោបាយ និងប្រជាពលរដ្ឋខ្មែរមានការខកចិត្តយ៉ាងខ្លាំងពីនយោបាយវិលវល់របស់ទ្រង់រណឫទ្ធិ ៕

## (តមកពីទំព័រទី០៤) គ្រូ និងសិស្សនិយាយរឿងប្រលង...

សិស្សរៃអង្គាសលុយឱ្យគ្រូ ហើយនៅមណ្ឌលវិទ្យាល័យ ហ៊ុន សែន ដើមថ្កូវ ក្រុងភ្នំពេញ និងមណ្ឌលវិទ្យាល័យកុសុមៈ ខេត្តក្រចេះ ដែលមានបញ្ហា គឺគ្រូទាំងនោះយកលុយសិស្ស ហើយមិនព្រមធ្វើចំលើយឱ្យសិស្ស ទើបមានរឿងអាស្រូវកើតឡើង ។

***បេក្ខជនចង់ចាំទិញព្រីយ៉ុង :**

លោក លី ម៉េងហុង អ្នកប្រកបមុខរបរថតចំលងដែលមានទីតាំងនៅក្បែរវិទ្យាល័យសន្ធរម៉ុកឱ្យដឹងថា ការប្រកបរបរថតចំលងនៅពេលសិស្សប្រលងម្ដងៗ គឺមមាញឹកខ្លាំងណាស់ ដោយបេក្ខជនមករង់ចាំទិញវិញ្ញាសារ និងឱ្យថតចំលងឯកសារផ្សេងៗសំរាប់ដាក់តាមខ្លួន ងាយស្រួលយកទៅបើកមើល ។



បេក្ខជនកំពុងមើលឈ្មោះប្រលង

សិស្សនៅតាមអនុវិទ្យាល័យ និងវិទ្យាល័យទូទាំងប្រទេសភាគច្រើនមិនសូវយកចិត្តទុកដាក់លើការសិក្សារៀនសូត្រទេ ហើយឈប់រៀនគ្មានច្បាប់ទំលាប់ ដោយសារពួកគេអាងថា គ្រូបន្ទុកថ្នាក់ និងអ្នកគ្រប់គ្រងមួយចំនួនគ្រាន់តែឱ្យលុយពី៣០ទៅ ៥០ដុល្លារ អាចទិញដូរពិន្ទុបានយ៉ាងងាយស្រួល ។ ខេត្តក្រុងដែលមានមណ្ឌលប្រលងគេសង្កេតឃើញនៅតាមកន្លែងតូបហ្វូតូកូពីមានបេក្ខជនយ៉ាងច្រើនបានទៅថតចំលងឯកសារ ដែលគេផ្ញើមកពីភ្នំពេញ ដែលឯកសារខ្លះត្រូវមួយសំណួរ ឬពីរសំណួរ ហើយខ្លះទៀត មានត្រូវសំណួរដល់ទៅ៤សំណួរ ក៏មានដែរ ។ ការបែកធ្លាយឯកសារនេះ គឺកើតមានជារៀងរាល់ឆ្នាំធ្វើឱ្យបេក្ខជនលែងមានជំនឿលើខ្លួនឯង ក្នុងការរៀនសូត្រ ហើយចាំទិញព្រីយ៉ុង តាំងពីព្រលប់រហូតដល់ម៉ោង១១យប់ក៏មានដែរ ។

លោក លី ម៉េងហុង បន្តថា នៅកន្លែងរបស់គាត់មានឯកសារមួយចំនួនដែលគេផ្ញើឱ្យតាម Fax ឬ E-mail ក្នុងមួយវិញ្ញាសារតំលៃពី ១០០ ទៅ ២០០ ដុល្លារ ហើយគាត់លក់បន្តឱ្យបេក្ខជន ក្នុងមួយច្បាប់ ពី១០០០ ទៅ២០០០រៀល ។ នៅថ្ងៃប្រលង High School ឬ Secondary School គឺបេក្ខជនមកថតចំលង និងចាំទិញវិញ្ញាសារដល់ម៉ោង១១យប់ ក៏មានដែរ ។

បេក្ខជន សឿន សុណា ប្រលងនៅមណ្ឌលបាក់ទូក បានឱ្យដឹងថា មុនពេលប្រលង គាត់តែងក្រោកពីព្រឹកវេលាម៉ោង៣ជិតភ្លឺរៀងរាល់ព្រឹក ដើម្បីទៅទិញព្រីយ៉ុងនៅក្បែរសាលាចតុមុខ ដែលព្រីយ៉ុងនោះមានត្រូវចំលើយតិចណាស់ ។ ចំណែកឯព្រីយ៉ុងដែលទិញនៅតាមកន្លែងថតចំលងនានាពេលល្ងាចមានត្រូវចំលើយច្រើនជាង ហើយពួកយើងមានរៃអង្គាសទិញព្រីយ៉ុង (តទៅទំព័រទី២១)


# WORC

**Women's Opportunities Resource Center**

**លើកដំកើងសង្គម និងសេដ្ឋកិច្ចឱ្យរស់គ្រប់គ្រាន់ខ្លួនឯងបាន**

*ជនភៀសខ្លួន
*ជនសុំសិទ្ធិជ្រកកោន

**សូមសួររកឈ្មោះ : សុបិន**




មជ្ឈមណ្ឌលផ្ដល់ឱកាស
ឱ្យមានធនធានរបស់ស្ត្រី
**(267) 253-3947** និយាយខ្មែរ

**ជួយដល់ជនភៀសខ្លួន / ជនសុំសិទ្ធិជ្រកកោន**

**គណនីសន្សំប្រាក់ក្នុងគ្រួសារ**

| | |
|---|---|
| ✔ អ្នកសន្សំបាន | $ 2,000 |
| ✔ WORC នឹងជួយអ្នក | $ 2,000 |
| | $ 4,000 |

**អ្នកត្រូវធ្វើ :**

**ទី១**- ហៅរក **(267) 253 3947** ដើម្បីផ្ដើម
**ទី២**- សន្សំប្រាក់ **$10**ដុល្លារមួយសប្ដាហ៍ពី ៦-១២ ខែ
**ទី៣**- ទៅសិក្សាពីគណនីថ្នាក់បង្រៀនឥតយកកំរៃ
**ទី៤**- **WORC** បង្គ្រប់ជួយស្មើប្រាក់សន្សំបាន

**អាចប្រើប្រាក់សំរាប់ :**

-ការសិក្សា
-ទិញផ្ទះ
-ផ្ដើម ឬពង្រីកមុខរបរ

***តម្លៃចុះឈ្មោះ = $40 / តម្លៃប្រឡងជាប់ = $50**

**-គ្មានកំរៃអ្វីទៀតទេ**

**ហានី (215) 564 5500 និយាយភាសាអង់គ្លេស**

2010 Chestnut Street
Philadelphia, PA 19103
Telephone: (215) 564-5500 • Facsimile: 215-564-0933
Website: www.worc-pa.com

## (តមកទំព័រទី២០) គ្រូ និងសិស្សនិយាយរឿងប្រលង...

គឺមិនបានគិតគូររឿងរៀនសូត្រនោះទេ ។

ស៊ឿ សុណា បន្តថា នៅពេលបានព្រីយ៉ុង ហើយពួកយើងត្រូវមានមេខ្យល់ម្នាក់ទៀត ដើម្បីដើររៃលុយក្នុងម្នាក់ពី៥០០០ទៅ១០០០០រៀលឱ្យទៅអនុរក្សកុំឱ្យគាត់ចាប់ ។ រយៈពេល២ថ្ងៃកន្លះនេះ គ្រាន់តែចំណាយទៅលើអនុរក្សសំរាប់គាត់ម្នាក់អស់ជិត១០ម៉ឺនរៀល នេះមិនទាន់គិតដល់ថ្លៃទិញព្រីយ៉ុងផង ។

**✻ សកម្មភាពពេលប្រលងនៅតាមមណ្ឌល :**

នៅពេលប្រលងម្តងៗ ក្រសួងបានធ្វើការណែនាំ និងដាក់ច្បាប់យ៉ាងតឹងតែង ដើម្បីត្រួតពិនិត្យលើការងារប្រលងបញ្ចប់លង High School នេះ ប៉ុន្តែ ដោយសារតែប្រាក់ខែតិចតួចស្តួចស្តើង ពួកគាត់ដែលជាគ្រូបង្រៀនក៏បាលះបង់នូវឧត្តមគតិនេះចោល ហើយទទួលយកលាភសក្ការៈបន្តិចបន្តួច ដើម្បីចំអែតក្រពះ ។

បេក្ខចនម្នាក់ ឈ្មោះ ឃុន សុខេន ដែលប្រលងនៅមណ្ឌលវិទ្យាល័យវត្តភ្នំ ក្រុងភ្នំពេញ បានឱ្យដឹងថា គាត់ជាសិស្សបំពេញធ្លាប់ប្រលង៣លើកហើយ តែមិនជាប់សោះលើកនេះ គាត់ព្រមទាំងបេក្ខជនក្នុងថ្នាក់បានរៃលុយគ្នាឱ្យអនុរក្សក្នុងម៉ោងពី៥០០០ ទៅ ១០០០០រៀល ដើម្បីឱ្យគាត់ជាថ្នូរនឹងការបិទភ្នែកចាប់ព្រីយ៉ុង ។

បេក្ខជន ឃុន សុខេន អាយុ ៤៨ឆ្នាំ រូបនេះ បានបន្តថា ចំពោះមុខវិជ្ជារូបវិទ្យា និងគណិតវិទ្យា ពួកគាត់ត្រូវរៃគ្នាឱ្យអនុរក្សក្នុងម្នាក់ប្រមាណពី១៥០០០ ទៅ ២០០០០ រៀល ពីមុខវិជ្ជានេះ ពិន្ទុច្រើន ហើយពួកគាត់ពុំសូវចេះទើបត្រូវធ្វើបែបនេះ ។ បេក្ខជនដែលចូលប្រលងបញ្ចប់ High School នោះ គ្មានអ្នកណាមិនចំណាយលុយទេ គឺគ្រាន់តែតិច និងច្រើនប៉ុណ្ណោះ ទៅតាមខេត្ត-ក្រុង ដែលគេចាយលុយប៉ុណ្ណោះ ។

ដោយឡែកនៅតាមមណ្ឌលប្រលងទូទាំងប្រទេសផ្នែកខាងក្រៅរបងវិញ គេសង្កេតឃើញមានមនុស្សអង្គុយត្រៀមត្រា ខ្លះទៀតតោងរបងបំរុងផ្លោះចូល ដើម្បីយកព្រីយ៉ុងចូល ប៉ុន្តែត្រូវសមត្ថកិច្ចឃាត់គឺបានត្រឹមតែឈររេរាប៉ុណ្ណោះ ។

នៅមណ្ឌលវិទ្យាល័យវត្តកោះក្រុងភ្នំពេញ និងមណ្ឌលត្បែងមានជ័យ ខេត្តឧត្តរមានជ័យ បេក្ខភាគច្រើនបាននិយាយថា គណៈមេប្រយោគមួយចំនួនធ្វើព្រីយ៉ុងលក់ឱ្យបេក្ខជនក្នុងមួយវិញ្ញាប្រមាណ១០០ដុល្លារ ដែលក្នុងបន្ទប់ប្រលងគ្មានសណ្តាប់ធ្នាប់សោះ ។

ហ្វូងមនុស្សដែលឈរនៅខាងក្រោយរបងនោះ ស្ត្រីម្នាក់ឈ្មោះ សំ សុដានី អាយុប្រមាណ៥០ឆ្នាំ បាននិយាយទាំងញញឹមថា គាត់មករង់ចាំកូនប្រលង ដើម្បីផ្តល់កំលាំងចិត្តឱ្យវា គាត់ចាស់ហើយគ្មានលទ្ធភាពរត់ទៅបោះព្រីយ៉ុងក្នុងមណ្ឌលនោះទេ ។

អ្នកស្រី សំ សុដានី បន្តថា អ្នកដែលជូនដំណើរកូនមកប្រលងទាំងអស់មានគោលបំណងមិនសូវខុសគ្នាទេ គឺរង់ចាំមើលក្រែងគេលក់ព្រីយ៉ុងទិញទុកឱ្យកូន បន្ទាប់ពីកូនចេញពីបន្ទប់វិញ ។ ជាពិសេសនោះ គឺពួកគាត់ទុកព្រីយ៉ុងឱ្យកូន ពីព្រោះពួកគេមិនអាចដាក់ព្រីយ៉ុងតាមខ្លួនបានទេ ត្រូវសន្តិសុខឆែកយកអស់ ។

**✻ ប្រតិកម្មពីមជ្ឈដ្ឋាននានា:**

ការប្រលងគ្រប់ភូមិសិក្សាជារៀងរាល់ឆ្នាំ តែងកើតមានភាពមិនប្រក្រតីកើតឡើងជាហូរហែស្ទើរ គ្រប់ខេត្ត-ក្រុង គឺជុំវិញគ្រូដែលទៅធ្វើអនុរក្សតំរូវឱ្យបេក្ខជនប្រមូលលុយជាថ្នូរនឹងការផ្តល់ឱកាសបើកចំលង ក៏ដូចជាជួយប្រាប់ចំលើយខ្លះៗដល់បេក្ខជនផងដែរ ។

អ្វីដែលគួរឱ្យកត់សំគាល់ និងធ្វើឱ្យប៉ះពាល់ដល់វិស័យអប់រំ និងអនាគតរបស់យុវជននោះ គឺការប្រលងហាក់ដូចជាទៅចំលងគ្នា ដោយសារវិញ្ញាសារផ្នែកសីលធម៌ពលរដ្ឋ ផែនដីវិទ្យា ប្រវត្តិវិទ្យា បានបែកធ្លាយឱ្យបេក្ខជនដឹងមុននៅតាមកន្លែងថតចំលងពាសពេញផ្ទៃប្រទេស ។

ក្លិនស្អុយដែលភាយចេញពីការប្រលងបញ្ចប់ នៅ High School នេះ ខ្មែរប៉ុស្តិ៍បានព្យាយាមជួប លោក កុល ផេង រដ្ឋមន្ត្រីក្រសួងអប់រំដែរ ប៉ុន្តែមិនអាចទំនាក់ទំនងបានដើម្បីសុំការបំភ្លឺ ។

ចំណែកលោក ច្រឹង លីមស្រ៊ី ប្រធាននាយកដ្ឋានមធ្យមសិក្សា ដែលទទួលបន្ទុកកិច្ចការនេះ បានប្រាប់អ្នកកាសែតថា នៅតាមមណ្ឌលប្រលងយើងមាន អនុរក្ស អគ្គានុរក្ស ប្រធានពួក និងអប្បមាទដាក់ នៅគ្រប់បន្ទប់ ដើម្បីឃ្លាំមើលដំណើរការប្រលង គឺមានអ្វីកើតឡើងដូចការចោទប្រកាន់របស់មជ្ឈដ្ឋានខាងក្រៅទេ។

លោក ច្រឹង លីមស្រ៊ី បានបន្តថា ចំណែកអនុរក្សដែលប្រព្រឹត្តខុសប្រមូលលុយពីសិស្សនោះ ត្រូវបាន ប្រធានមណ្ឌលវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ផ្សារដើមថ្កូវ ដាក់ពិន័យតាមច្បាប់ ហើយពួកគាត់អាចនឹងត្រូវផ្អាកមិនធ្វើមេប្រយោគរយៈពេល៣ឆ្នាំផងដែរ ។

លោកច្រឹង លីមស្រ៊ី បានបន្តថា ការប្រលងលើកនេះមានភាពល្អប្រសើរជាងឆ្នាំមុនៗ ហើយមិនសូវមានបញ្ហានោះទេ ។

ជាមួយគ្នានេះដែរ លោក រ៉ុង ឈុន ប្រធានសមាគមគ្រូបង្រៀនឯករាជ្យកម្ពុជាបានឱ្យដឹងថា ភាពមិនប្រក្រតីនៅពេលប្រលងបញ្ចប់ High School នេះបណ្តាលមកពីប្រាក់ខែរបស់ពួកគាត់តិចតួច មិនមានតុល្យភាពនៃទំនិញលើទីផ្សារ ធ្វើឱ្យគ្រូៗមួយចំនួនទំលាក់ចុះនូវ មនសិការចោល ហើយចាប់យកលាភសក្ការៈបន្តិចបន្តួច ដើម្បីចំអែតក្រពះ។

លោក រ៉ុង ឈុន បន្តថា អំពីពុករលួយក្នុងប្រព័ន្ធអប់រំតាំងពីថ្នាក់លើដល់ថ្នាក់ក្រោមនេះ បានជះឥទ្ធិពលអាក្រក់យ៉ាងខ្លាំងដល់សង្គមខ្មែរ ហើយយើងពិបាកនឹងធ្វើឱ្យមានគុណភាពក្នុងវិស័យអប់រំខ្លាំងណាស់ ពីព្រោះយុវជនទាំងអស់មុននឹងទៅបំរើការតាមក្រសួងមន្ទីរផ្សេងៗ សុទ្ធតែបានឆ្លងកាត់វិស័យអប់រំ ។

លោកប្រធានសមាគមរូបនេះបន្តថា បញ្ហានេះ វាអយុត្តិធម៌ខ្លាំងណាស់សំរាប់បេក្ខជនមួយចំនួន ដែលមានជីវភាពក្រីក្រត្រូវបានអនុរក្សមួយចំនួនបង្ខំឱ្យរៃលុយនោះ ។ ជាពិសេសនោះ ការដាក់ទណ្ឌកម្មតែអនុរក្សពីរនាក់ក្នុងរឿងប្រមូលលុយនេះ ក៏វាមិនយុត្តិធម៌ទេ ពីព្រោះរឿងនេះ វាកើតមានស្ទើរពេញផ្ទៃប្រទេស ។

ចំណែក ហ៊ីម យន់ ប្រធានសមាគមយុវជនខ្មែរស៊ីវិល ទីក៏បានបញ្ចេញ ប្រតិកម្មប្រហាក់ប្រហែលលោក រ៉ុង ឈុន ដែរថា ការដែលបេក្ខជន ប្រមូលលុយគ្នាឱ្យអនុរក្សនៅពេលប្រលងនេះ វាជាសញ្ញាណមួយអាក្រក់ខ្លាំងណាស់សំរាប់សង្គមខ្មែរ ជាពិសេសវាជះឥទ្ធិពលដល់ផ្នត់គំនិតរបស់យុវជន ដោយពួកគេសំអាងថា អាចប្រើប្រាស់លុយចាប់ពីពេលនេះតទៅ ។

លោកប្រធានសមាគមយុវជនខ្មែរស៊ីវិលទីរូបនេះ បានបញ្ជាក់ថា នៅពេលពួកគេចេញទៅបំរើការងារ នៅតាមក្រសួងមន្ទីរផ្សេងៗ គឺគេមានគំនិតសូកលុយកាក់បន្តទៅទៀត ដែលសញ្ញាណនៃការប្រព្រឹត្តអំពើពុករលួយ ។ លោកក៏បានសំណូមពរឱ្យក្រសួងអប់រំយុវជន និងកីឡា រដ្ឋាភិបាលគួរតែគិតគូរបញ្ហានេះឡើងវិញ ដោយបង្កើននូវថវិកាជាតិសំរាប់វិស័យអប់រំឱ្យត្រូវតាមស្តង់ដា ។

ភាពមិនប្រក្រតីនៅពេលប្រលងបញ្ចប់ភូមិសិក្សាម្តងៗនេះ បានដក់ជាប់ក្នុងផ្នត់គំនិតរបស់យុវជនខ្មែរមួយចំនួនហើយ គឺពួកគេមិនចូលសាលារៀន មិនសូវស្តាប់គ្រូ មិនសូវខ្វល់ខ្វាយរឿងពិន្ទុខ្ពស់ទាបក្នុងថ្នាក់នោះទេ ។ ពួកសិស្សទាំងនោះបានប្រើប្រាស់ទឹកលុយរបស់ខ្លួនទាំងនៅក្នុងសាលារៀន និងពេលប្រលងយ៉ាងគគ្រឹកគគ្រេងដែលធ្វើតែក្លាយទៅជាទំលាប់ទៅហើយ ។

ទំលាប់អាក្រក់នេះ ធ្វើឱ្យយុវជនខ្មែរនឹងជួបប្រទះកាន់តែខ្លាំងនៅពេលអនាគត ហើយលោកបណ្ឌិត ឡៅ ម៉ុងហៃ អ្នកស្រាវជ្រាវជាន់ខ្ពស់សិទ្ធិមនុស្សអាស៊ីបានបញ្ចេញទស្សនៈថា"ទំពាំងស្នងឫស្សី ចុះបើឫស្សីពុក ហើយយកឫស្សីពុកទៅជំនួសនោះ" គឺវាកាន់តែពុកទៅទៀត ។

លោកបណ្ឌិតក៏បានសំដែងនូវអារម្មណ៍សោកស្តាយថា សមាជិកសភានាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីពេលស្បថមុខព្រះមហាក្សត្រត្រង់មាត្រា ទី៥, ៦ និង ៧ ថា ទូលបង្គំយើងខ្ញុំទាំងអស់គ្នា សូមប្តេជ្ញាតស៊ូប្រឆាំងអំពើពុករលួយគ្រប់បែបយ៉ាងប្រឆាំងនឹងភាពអយុត្តិធម៌ក្នុងសង្គមតស៊ូដោះស្រាយគ្រប់បញ្ហាទំនាស់ ។ ប៉ុន្តែអ្វីដែលអស់លោកទាំងអស់នេះបានស្បថស្បែ ហាក់ដូចជាធ្វើមិនទាន់បានទាល់តែសោះ ដែលទង្វើនេះ វាកំពុងតែជះឥទ្ធិពលកាន់តែអាក្រក់ដល់កូនខ្មែរគ្រប់រូបនោះ ។

គួរបញ្ជាក់ថា មានពាក្យចចាមអារាមមួយចំនួនថា សិស្សានុសិស្សដែលឈប់ច្រើន ឬបានពិន្ទុតិចហើយ ចង់ឡើងថ្នាក់ និងចង់ទៅប្រលងបញ្ចប់ High School គឺត្រូវតែសូកប៉ាន់គ្រូបន្ទុកថ្នាក់ ឬគ្រូនាយកពី២០ទៅ៣០ដុល្លារ ទើបឡើងថ្នាក់បាន ។ ចំណែកសិស្សថ្នាក់ទី៩ ដែលត្រូវប្រលងបញ្ចប់ Secondary School នោះ ពួកគេមួយចំនួនក៏ត្រូវសូកប៉ាន់ដែរ គឺនៅទីក្រុងម្នាក់ពី៤០ទៅ៥០ដុល្លារ រីឯនៅ តាមស្រុកស្រែចំការក្នុងម្នាក់ត្រូវសូកប៉ាន់ទៅថ្នាក់លើពី ២០ទៅ៣០ដុល្លារ ដែលទង្វើនេះបានក្លាយទៅជាទំលាប់ទៅហើយ ៕

## (តមកទំព័រទី១១) ប្រាសាទភ្នំជីសូរជាកេរដំណែល...

៤ និងផ្នែកខាងជើងមានប្រាសាទ៣ ប៉ុន្តែប្រាសាទទាំងនោះបានរង់នូវការបំផ្លិចបំផ្លាញអស់មួយចំនួនហើយ ។

លោកព្រឹទ្ធាចារ្យបានបន្តថា នៅក្នុងប្រាសាទ មានតម្កល់លិង្គព្រះឥសូរ និងយោនីព្រះនាងឧមា ចម្លាក់ក្បាច់រចនាផ្សេងៗ ។



នៅពេលសួរថា ហេតុអ្វីបានជាសំណង់ធ្លាក់បែកបាក់នោះ លោកព្រឹទ្ធាចារ្យបានរៀបរាប់ទាំងទឹកមុខស្ងួតថា បើតាមលោកដឹងក្នុងអំឡុងឆ្នាំ១៩៧០ មានការទម្លាក់គ្រាប់បែកពីសំណាក់ទាហានអាមេរិក រយៈពេល៣យប់ និងបួនថ្ងៃ ។ ដោយសារពួកទាហានអាមេរិកសង្ស័យថា មានទាហានយៀកណាម នៅលាក់ខ្លួន និងឆ្លងកាត់ទីនោះក៏ទម្លាក់គ្រាប់បែកយ៉ាងច្រើន បានបង្កឱ្យសំណង់ប្រាសាទ និងសមិទ្ធផលនានាទទួលរងនូវការខូចខាតយ៉ាងដំណំ ។

បន្ទាប់ពីនោះមកទៀត ពួកជនទុច្ចរិតបានលួចគាស់រូបចម្លាក់ កាត់ក្បាលអ្នកតាចំនួន៩លើកធ្វើឱ្យសម្បត្តិវប្បធម៌ជាតិត្រូវទទួលនូវការខូចខាតស្ទើរអស់ ។

ព្រះតេជគុណ សុខ ហ៊ុត អាយុ៧០ឆ្នាំ ជាគ្រូសូត្រស្តីទីវត្តភ្នំជីសូរ បានមានសង្ឃដីកាថា នៅបរិវេណប្រាសាទនេះ គណៈគម្មការវត្តបានចាត់ចែងឱ្យមនុស្សធ្វើការបោសសម្អាត និងថែទាំទីកន្លែងសក្ការបូជា ដើម្បីជួយសម្រួលដល់ភ្ញៀវទេសចរ ។

តាមការសង្កេតរបស់ព្រះសង្ឃនៅថ្ងៃសៅរ៍ និងអាទិត្យ មានភ្ញៀវមកមើលប្រាសាទដែរ ប៉ុន្តែមានចំនួនតិចតួចនោះទេ ។ ភ្ញៀវទេសចរ ដែលមកទស្សនាច្រើន គឺនៅពេលបុណ្យចូលឆ្នាំខ្មែរ កាន់បិណ្ឌ និងកឋិនទាន ដែលនៅពេលនោះ មានមនុស្សច្រើនខ្លាំងណាស់ រកកន្លែងអង្គុយស្ទើរតែពុំបាន ។

នៅលើកំពូលភ្នំជីសូរនេះ មានបារមីអ្នកតាក្រហម.ក យាយម៉ៅ ខ្លាំងពូកែណាស់កាលពីសម័យមុន ។ សព្វថ្ងៃនេះ អ្នកស្រុកនៅតែមានជំនឿ ហើយទៅធ្វើការបួងសួង បានសមប្រកបទៀតផង ដែលជាហេតុធ្វើឱ្យមានសមិទ្ធយ៉ាងច្រើននៅទីនេះ ៕

## (តមកពីទំព័រទី០៦) បទសម្ភាសន៍របស់ខ្មែរប៉ុស្តិ៍...

ដើម្បីយើងការពារសិទ្ធិអំណាច ការពារបូរណភាពទឹកដី ការពារអធិបតេយ្យភាពកម្ពុជាឱ្យបានពេញលេញ មានអ្នកទៅបោះឆ្នោតជូនគណបក្សសិទ្ធិមនុស្ស មានលេខរៀងទី១១ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ ខាងមុខនេះបាទ សូមអរគុណ ។

ក្នុងនាមវិទ្យុខ្មែរប៉ុស្តិ៍ ខ្ញុំសូមអរគុណលោកអតីតនាយករដ្ឋមន្ត្រី ប៉ែន សុវណ្ណ និងក៏ជាអនុប្រធានគណបក្សសិទ្ធិមនុស្ស ក្នុងនាមវិទ្យុខ្មែរប៉ុស្តិ៍សង្ឃឹមថា នៅថ្ងៃខាងមុខទៀត ខ្ញុំសុំការអនុញ្ញាតពីលោកអតីតនាយករដ្ឋមន្ត្រី ប៉ែន សុវណ្ណ ដើម្បីផ្តល់កិច្ចសម្ភាសន៍សំរាប់មិត្តអ្នកអានស្តាប់វិទ្យុខ្មែរប៉ុស្តិ៍ជាបន្តទៀត ខ្ញុំបាទសូមជំរាបលាលោកអតីតនាយករដ្ឋមន្ត្រី ប៉ែន សុវណ្ណ បាទ ។

លោក ប៉ែន សុវណ្ណ តបបញ្ចប់ បាទ បាទ ខ្ញុំសូមអរគុណ សូមប្រសិទ្ធិពរជ័យឱ្យលោក បានសម្រេចដូចសេចក្តី ប្រាថ្នាបាទ ៕

**បទសម្ភាសន៍របស់ មាជ សុវណ្ណារ៉ា**
**ផ្សាយក្នុងវិទ្យុខ្មែរប៉ុស្តិ៍កាលីហ្វ័រនីញ៉ា**
**ដកស្រង់ដោយ : ម៉ម យិន**

New World Travel II
New World Travel II
ញូវលត្រាវែលធូ
Specialized in Selling Flight Tickets
For National and International
ជំនាញខាងលក់សំបុត្រយន្តហោះសំរាប់ក្នុងប្រទេស និងអន្តរជាតិ យើងតំណាងឱ្យក្រុមហ៊ុន ចិន កូរ៉េ កាថៃ ។ល។ ធ្វើលិខិត Re-Entry Permit ប្រញាប់ជូនបាន ទិញសំបុត្រជិះនាវាសមុទ្រ-សណ្ឋាគារ ឬជួលឡាន សំបុត្រយន្តហោះទៅច្រើនប្រទេសក្នុងតម្លៃទាបបំផុត ។
Represented Several of Company such as China, Korea, Cathay etc.,
Offer Rush Re-Entry Permit
Reserve Cruise, Hotels and Car Rentals
Best Price Air Ticket for Many Destinations
600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036

## (តមកពីទំព័រទី០១) កីឡាអូឡាំពិក នៅបេយ៉ឹង

នៅលើទីលានកីឡាមែនទែននោះទេ ដូចជាជ័យលាភីមេដាយមាស តែត្រូវមានអាយុ១៦ឆ្នាំយ៉ាងតិច បែរជាអាយុមិនដល់១៦ឆ្នាំនៅឡើយ សំឡេងកុមារី ដែលច្រៀងបើកពិធីបែរជាច្រៀងត្រាប់ដោយសំឡេងអ្នកចំរៀងម្នាក់ទៀត ដែលគ្រាន់តែមុខមាត់ "មិនស៊ីកាមេរ៉ា" តែប៉ុណ្ណោះ ។ ដូចជាក្រុមមកទះដៃអបអរសាទរកីឡាករអន្តរជាតិសុទ្ធតែគេជួលឱ្យមកទះដៃទៅវិញ ។ ភាពក្លែងក្លាយនេះ បន្ថែមដោយសញ្ញាមិនគោរពសេរីភាពសារព័ត៌មាន ដែលអ្នកកាសែតម្នាក់ត្រូវបានចាប់ខ្លួនដកយករូបថតស្ដីពីការបាតុកម្មទាមទារឱ្យពិភពលោកដឹងឮពីការទាមទារឱ្យមានស្វ័យតភាពរបស់រដ្ឋទីបេ ll Bat ... ។ល ។

តែទោះជាយ៉ាងណាក៏ដោយសកម្មភាពប្រកួត បានប្រព្រឹត្តទៅជិតមួយអាទិត្យ ហើយកីឡាករហែលទឹកឈ្មោះ **ហ្វែល** បានរំលាយឯកទត្តកម្ម ដែលឈ្នះបានមេដាយមាសតែម្នាក់ឯង ៨-៩ នេះជាលទ្ធផលនៅថ្ងៃទី១៨ សីហា ២០០៨ ចំពោះប្រទេសបី ដែលបានមេដាយច្រើនជាងគេ :

- ចិន -មាស៣៩ -ប្រាក់១៤ -សំរិទ្ធ១៤ សរុប ៦៧
- សហរដ្ឋអាមេរិក -មាស២២ -ប្រាក់២៤ -សំរិទ្ធ២៦ សរុប៧២
- អង់គ្លេស -មាស១២ -ប្រាក់៧ -សំរិទ្ធ៨ សរុប ២៧ ៕

### THE EVENING OF CHAMPION 08.08.08

**Written by Sabane Thach**

For the first time in the history the Olympic Games is being held in Beijing, much of the international attention now is focusing on China. Part of the national pride efforts, the Chinese government






has put extensive effort to show to the world the beauty of its country by making sure throughout the city the grass are green, the trees are perfectly shaped, and the flowers are blooming everywhere.

On Friday August 8th, 2008, while the Olympic Opening Ceremonies was celebrating in China, the Philadelphians were also celebrating the "Evening of Champion" in the Chinatown. The evening was filled with exciting music, beautiful Chinese traditional performances, the games for the children, and the Mayor Michael Nutter also made his public appearance. From 10th & Arch streets to 10th & Race streets was overwhelmingly crowded by people because they wanted to get a glimpse of the excitement about the Beijing Olympic Games in China.

For such event like this one, it took China billions of dollars and seven years to prepare. Knowing that all eyes

*continua page 24*


ឱសថស្ថានខ្មែរ
Sav-Mor PHARMACY
Sam EA R.Ph.
2232 S. 7th St. (7th & Wolf) Philadelphia, Pa 19148
Tel: 215.467.1220 Fax: 215.467.1447
បំរើលោកអ្នកដោយមិត្តភាព និងទាន់ចិត្ត
Fast and Friendly Service



▸▸Sav-Mor គឺជាឱសថស្ថានបំរើ ការចែកចាយថ្នាំ ហើយអាចពន្យល់ពីរបៀបប្រើប្រាស់ថ្នាំ តាមវេជ្ជបញ្ជាជាភាសាខ្មែរបាន
▸▸យើងទទួលយកនូវ MEDICARE MEDICAID និង INSURANCES ជាច្រើនទៀតផង យើងមានលក់កាត សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ ឬទៅអន្តរជាតិ
*Accept most insurance plans including Medicare & Medicaid
*Easy Prescription transfer
*Inside. Prepaid phone card. Call Cambodia.






Buy now on DVD
award winning film about a Cambodian American family's story
www.NewYearBaby.net
Phone Order: 877-345-6222
Find out more about Socheata Poeuv's organization Khmer Legacies:
www.KhmerLegacies.org
ទិញនៅទីនេះ
"ទទួលពានរង្វាន់ខ្សែភាពយន្តស្ដីអំពីរឿងគ្រួសារខ្មែរ-អាមេរិកាំង
www.NewYearBaby.net លេខទូរស័ព្ទបញ្ជាទិញ (877) 345-6222
ចូលទៅមើលអង្គការ "ខ្មែរកេរ្តិ៍ដំណែល" របស់ សុជាតា ពៅ : www.KhmerLegacies.org



Nationwide
Insurance & Financial Service
សេវាធានារ៉ាប់រង និងហិរញ្ញវត្ថុ
We offer Cheap Price for Every Client
យើងធ្វើជូនគ្រប់ភ្ញៀវដោយតម្លៃថោក

| | |
|---|---|
| Business Liability Insurance | ធានារ៉ាប់រងជំនួញលោកអ្នក |
| Home Insurance | ធានារ៉ាប់រងផ្ទះសម្បែង |
| Health Insurance | ធានារ៉ាប់រង សុខភាព |
| Auto Insurance | ធានារ៉ាប់រងរថយន្ត |
| Life Insurance | ធានារ៉ាប់រងជីវិត |

Discount 30% when you purchase Home & Auto Insurance
ចុះតម្លៃ ៣០ % បន្ថែមបើលោកអ្នកទិញធានារ៉ាប់រង ផ្ទះ និងរថយន្តរួមគ្នា

South Philadelphia office:
600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036

North Philadelphia office:
6603 Bustleton Ave.
Philadelphia, Pa 19149
Tel: (215) 335-2140
Fax: (215) 335-2147

# បាតុកម្មខ្មែរនៅមុខស្ថានទូតថៃ នៅសហរដ្ឋអាមេរិក

ដោយ : ភឿន ដុល

•••ប្រជាពលរដ្ឋខ្មែរ-អាមេរិកាំងនៅជុំវិញ Washington D-C បាននាំគ្នាធ្វើបាតុកម្មនៅ ថ្ងៃទី១១ សីហា ឆ្នាំ២០០៨ កន្លងមកនេះ ដើម្បីប្រឆាំងនឹងប្រទេសថៃ ដែលកំពុងតែឈ្លានពានមកលើទឹកដីខ្មែរ នៅប៉ែកខាងជើងប្រទេសជាប់ព្រំដែនខ្មែរ-ថៃ នៅប្រាសាទព្រះវិហារ និងប្រាសាទតាមាន់ទាំងពីរ ដែលជាសម្បត្តិរបស់ប្រទេសខ្មែរ ។

បាតុកម្មនេះ មានអ្នកចូលរួមប្រហែល ១០០ នាក់ ដឹកនាំដោយសមាគមមនុស្សធម៌ ឈ្មោះ "អង្គរ" ដែលជាសមាគមឯករាជ្យមួយ ដែលបានបង្កើតពីឆ្នាំ ១៩៨៦ នេះបើតាមសម្តីរបស់លោក ថូម ម៉ាស កែវ ដែលជាអគ្គហេរញ្ញិក លោកបានប្រាប់ខ្មែរប៉ុស្តិ៍ ឱ្យដឹងពីគោលបំណងនៃការធ្វើបាតុកម្មនេះថា :

- ឱ្យរដ្ឋាភិបាលថៃ គោរពសិទ្ធិសញ្ញាអន្តរជាតិ យូនីហ្គូ ដែលរដ្ឋមន្ត្រីការបរទេសថៃ ចុះហត្ថលេខាទទួលស្គាល់ និងពិភពលោកក៏បានទទួលស្គាល់ដែរ ។

-ឱ្យរដ្ឋាភិបាលថៃដកកងទ័ពចេញពីប្រាសាទព្រះវិហារ និងប្រាសាទតាមាន់ ។

-សូមឱ្យថៃបញ្ឈប់ធ្វើការឈ្លានពានមកលើបូរណភាពទឹកដីខ្មែរតទៅទៀត ។

**រីឯលោក ឯក ឯម បាននិយាយថា :**

-ឱ្យថៃគោរពច្បាប់អន្តរជាតិ ដែលតុលាការក្រុងឡាអេ កាត់ក្តីឱ្យប្រទេសខ្មែរ ជាអ្នកឈ្នះក្នុងរឿងក្តីប្រាសាទព្រះវិហារ តាំងពីឆ្នាំ ១៩៦២ ។

- សូមឱ្យថៃទទួលស្គាល់បូរណភាពទឹកដី ខ្មែរ ដែលថៃបានចុះហត្ថលេខាទទួលស្គាល់ នាទីក្រុងប៉ារីស ស្តីពីសន្តិភាពនៅកម្ពុជា ៕

## (តមកទំព័រទី២៣) កីឡាអូឡាំពិក នៅបេយ៉ឹង

around the globe is on them, making sure to produce perfect public image for the international television was crucial. Unfortunately, according to the AP report, while everyone was looking forward to the Olympic kicks off, thousands of people demonstrated to demand China to end its brutal ruling in Tibet and thousands more of Tibetan exiles demonstrated at the Chinese Embassy in Nepal's capital, Kat-mandu, shouting, "China thief, leave our country. Stop killing in Tibet." 1,000 of Tibetans were detained in a single that was more than it has ever done.

President George W. Bush also stated prior his arrival to China, that Chinese government still has serious problems with regarding the human rights issues.

Despite the political tension, the Olympic Games proceed its normal routine. As of 08/18/2008, the leading winners are including:

| | Gold | Silver | Bronze | Total |
|---|---|---|---|---|
| 1.China | 39 | 14 | 14 | 67 |
| 2.United States | 22 | 24 | 26 | 72 |
| 3.Great Britain | 12 | 7 | 8 | 27 |

## (តមកទំព័រទី០១) ពិធីបុណ្យអុំទូកនៅឡូវែល

មនុស្សជាច្រើន ដែលមកពីរដ្ឋផ្សេងៗ ដើម្បីទៅចូលរួមពិធីនោះ ។ លោក វ៉ាឌី ម៉ុម អ្នករៀបចំនៅទីនោះ បានឱ្យដឹងថា ទូកមានពីរសំរាប់អុំប្រណាំងគ្នាលើដៃទន្លេឡូវែលនោះ គួរប្រគួតមានតែពីរក្រុម គឺថៃ និងឡាវ ពុំមានខ្មែរចូលរួមទេ ។

ពិធីរបៀបបានកើតឡើងនៅ ឡូវែល ជាច្រើនឆ្នាំណាស់មកហើយ ដោយការខិតខំប្រឹងប្រែងរបស់សហគមន៍ខ្មែរ ។ នៅបីឆ្នាំចុងក្រោយនេះ បុណ្យអុំទូកខ្មែរ បានបំបែកទៅជាពីរក្រុមនាំគ្នាអុំនៅទីដៃសមុទ្រដដែល ក៏ប៉ុន្តែខុសថ្ងៃគ្នា ១ខែ ហើយឆ្នាំនេះ បែរជាអត់មានខ្មែរចូលរួមសោះតែម្តង ។

ថ្ងៃសៅរ៍ ទី១៦ សីហា ខែសីហានេះ ភ្ញៀវច្រើនពាន់នាក់ បាននាំក្រុមគ្រួសារដើរមើលការតាំងទំនិញវត្ថុអនុស្សាវរីយ៍យ៉ាងខ្សៀវខ្សារ ក្រុមតន្ត្រីប្រគុំនៅលើឆាកគ្មានដាច់ ៕





Hosted by: Mt Enon Community Outreach (MECO)

FREE!

ពិពណ៌សុខភាពឆ្នាំ ២០០៨ របស់ពហុវប្បធម៌

MULTI-CULTURAL HEALTH FAIR 2008





SATURDAY, AUGUST 23, 2008
12:00 PM-5:00 PM
5TH STREET & SNYDER AVENUE
PHILADELPHIA, PA 19148
Rain Date: Sunday, August 24, 2008
1:00 PM-6:00 PM
For more info: 215-334-1074

HEALTH SCREENINGS AND MEDICAL INFORMATION FOR THE ENTIRE FAMILY!
FREE FOOD, MUSIC, ENTERTAINMENT AND PRIZES.
*Special performance by Chaz Shepherd, from Oprah's *The Color Purple**

សូមអញ្ជើញមកចូលរួមដោយឥតគិតថ្លៃ

ថ្ងៃសៅរ៍ទី ២៣ ខែ សីហា ឆ្នាំ ២០០៨ ពីម៉ោង ១២:០០ ដល់ ម៉ោង ៥ រសៀល នៅផ្លូវលេខ៥ នឹង SNYDER Ave. ហ្វីឡាដែលហ្វីយ៉ាខាងត្បូង ពិនិត្យសុខភាព នឹងផ្តល់ពត៌មានសំរាប់ព្យាបាលជូនដល់ក្រុមគ្រួសារទាំងអស់ ជូនម្ហូបអាហារ មានភ្លេងសិល្បៈ និងរង្វាន់ សំដែងសិល្បៈ ពិសេសដោយក្រុមរបស់ OPRAH'S

SCREENINGS FOR:
Blood Pressure
Cholesterol
Diabetes
Prostate Cancer
HIV
Asthma
COPD
Body Fat
Vision

INFORMATION ON:
Nutrition & Exercise
HPV Vaccine (Gardasil)
Family Planning
Breast Cancer
Dental Care
HIV/AIDS
Smoking Cessation
Hepatitis B & C
Depression

ពិនិត្យសុខភាព
លើសឈាម
ខ្លាញ់ក្នុងឈាម
ទឹកនោមផ្អែម
កង់សែប្រូស្តាត
HIV , ហឺត
ធាត់ឡើងទម្ងន់
ភ្នែក

ពត៌មានពី :
ម្ហូបអាហារ និងហាត់ប្រាណ
HPV (ចាក់ថ្នាំបង្ការ)
គម្រោងគ្រួសារ
មហារីកដោះ
ថែធ្មេញ
HIV / AIDS
ឈប់ជក់បារី
អេប៉ាតាយទីស B&C
អារម្មណ៍មិនល្អ

SUPPORTERS

ORGANIZATIONS
AmeriChoice
Bristol-Myers Squibb
Eli Lilly
Evercare
Novo Nordisk
GlaxoSmithKline
Grays Ferry Medical Center
Keystone Mercy
Merck
Mt. Enon Community Outreach
Pfizer
Young's Medical Equipment
AstraZeneca
Health Partners
Bayer
Shop Rite
Southeastern Asian Mutual Assistance Associations Coalition (SEAMAAC)
Mexican Consulate
Quest Diagnostics
Boehringer Ingelheim

PROVIDERS
Dr. Donna Carstens
Dr. Nanidia Oviedo
Dr. Ngoc Phan
Dr. Clement Au
Sandy McCarthy, PA
Dr. Jacque Curtis
Dr. Carver Hillis
Dr. Lisa Schaffer
Audrey Fisher, PA
Dr. Malone
Sharon Katzenbach, NP
Dr. Cheung Trah
Dr. Joseph Cavuto
Dr. David Yuan
Paula Larsen, NP
Dr. James Smith
Dr. Kiet Thai
Dr. Phuong Trah
Dr. Donna Jones
Dr. George Fisher
Dr. Anthony Luisito

Novo Nordisk · Bayer HealthCare Diabetes Care · Bristol-Myers Squibb · Boehringer Ingelheim · MERCK SERVICES. · Evercare · SEAMAAC · AmeriChoice · Pfizer · KEYSTONE MERCY HEALTH PLAN · gsk GlaxoSmithKline · Lilly · AstraZeneca